# កែវព្រះភ្លើង

គុយ ឡូត



93

ATB Center

បដិវត្តន៍ ឆ្នាំ១៨៩៧

PB.2008
895.9323
ឡូត
គុ.4

គុយ-ឡូត

# កែវព្រះភ្លើង

ប្រលោមលោកប្រវត្តិសាស្ត្រ

បដិវត្តន៍ឆ្នាំ ១៥៩៧

ផ្សាយចេញពី
គេហដ្ឋានលេខ ៥ វិថីភាគបានក្រហមខ្មែរ
ភ្នំពេញ

00019849
បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ព.ស ២៥១៥ គ.ស ១៩៧១

រក្សាសិទ្ធិ

បោះពុម្ពផ្សាយឡើងវិញដោយបណ្ណាគារ "**អង្គរធំ**"
អាសយដ្ឋាន: អគារលេខ ២៦១, មហាវិថីកម្ពុជាក្រោម, ភ្នំពេញ
ទូរស័ព្ទលេខ: (០២៣) ៨៨-៨៨-៨៦
ឆ្នាំ ២០០២
(បោះពុម្ពក្នុងខ្នាត: ១៥ × ២១ សង់ទីម៉ែត្រ)
គូរូបក្របឡើងវិញដោយលោក **សែន សាមន្តតារា**
វាយអត្ថបទដោយអ្នកស្រី **មុត សោវ័ត្ថ**
រចនាជាសៀវភៅដោយលោក **ហាក់ ម៉ាន់ដារា**
ម៉ូតអក្សរ Apsara, ទំហំ ២២
កែអក្ខរាវិរុទ្ធដោយកញ្ញា **ម៉ែន និត្យធីតា**

ឯកសារដើមបានមកពី គម្រោងស្រាវជ្រាវ
***"វិវត្តន៍អក្សរសិល្ប៍ខ្មែរនាសតវត្សទី២០"***

# បណ្ណាគារ អង្គរធំ
ANGKOR THOM BOOK CENTER
www.angkor-thom

# ឧបរិមបរិច្ឆេទ

ខ្ញុំសរសេររឿងនេះ ត្រូវចំលើវេលាដែលប្រទេសខ្មែរយើងចាប់ផ្ដើម មានសង្គ្រាមដោយស្ដេចសីហនុ ដែលផ្ដួងខ្លួនទៅប៉េកាំង បង្កើតការសងសឹកមកលើប្រជាជនខ្មែរ ដែលទម្លាក់ខ្លួនពីតំណែងប្រមុខរដ្ឋ កាលពីថ្ងៃ ១៨មីនា ១៩៧០ ដោយបើកដៃឱ្យទ័ពយួនយៀកកុង យៀកណាម ខាងជើងចូលមកវាយប្រជាជន ខ្មែរយ៉ាងកោលាហល។

ទ័ពសត្រូវគ្រានោះមានគ្នាជាង ៦ម៉ឺននាក់ មានអាវុធគ្រប់គ្រាន់ ហាត់រៀនស្ទាត់, បានចូលព្រួត មកវាយទ័ពយើងដែលមានគ្នាតែជាង ៣ ម៉ឺន គ្មានអាវុធ ឥតបានហាត់រៀនសោះ នាំឱ្យទ័ពជាតិយើងទន់ដៃគ្រប់ទី។

ព្រឹត្តិការណ៍នោះ នាំឱ្យខ្ញុំនឹកព្រួយបារម្ភយ៉ាងខ្លាំង ខ្លាចតែស្រុកទេសដែលនៅសល់តែមួយប្រទ្បង់នេះ ត្រូវរួញរួមតូចមកទៀត ។ អ្នកនិពន្ធច្រើនគ្នាក៏គិតព្រួយយ៉ាងនេះដែរ ជាពិសេសអ្នកនិពន្ធសារពត៌មានជាតិ ខំតាំងសរសេរ ពង្រឹងស្មារតីខ្មែររាល់ថ្ងៃ ហើយគ្រប់ៗគ្នា។

ខ្ញុំបានសរសេររឿងនេះមួយថ្ងៃបន្តិច ៗ យកទៅចុះផ្សាយតាមរយៈសារពត៌មាន "កោះសន្តិភាព" ។ ការសរសេរនោះ កញ្ចក់កណ្តៀតណាស់ គ្មានបានកាត់ដំពូករៀបពាក្យពេជន៏ឱ្យស្រួលសមរម្យទេ ។

ប៉ុន្តែទោះបីរឿងនេះរៀបពុំសូវល្អសមរម្យដូច្នោះក៏ដោយ ការសរសេររឿងនេះទាល់តែចប់ ក៏សន្មត់ទុកដូចជាជោគជ័យនៃគំនិតរបស់អ្នកនិពន្ធផងដែរ ដែលខំព្យាយាមបញ្ចេញ "គំនិតសាធារណរដ្ឋ" នៅក្នុងរឿងនេះទាល់តែចប់ ទោះបីមានសូរកាំភ្លើងល្វើយៗ យូរៗម្តងក្នុងឱកាសស្ងាត់នៃរាត្រី មកគម្រាមកំហែងយ៉ាងណាក៏ដោយ។

គ្រានេះដែលសេរីបោះពុម្ពជាសៀវភៅ ខ្ញុំបានកែប្រែ និង រៀបរៀង ឡើងវិញតាមទំនងប្រលោមលោកសមរម្យហើយ។

ខ្ញុំសូមឧទ្ទិសរឿងនេះ ចំពោះសាធារណរដ្ឋខ្មែរទាំងមូលជាទីស្នេហារបស់ខ្ញុំ និង របស់ខ្មែរទាំងអស់គ្នា !

ភ្នំពេញ ថ្ងៃទី ១០ ខែមិថុនា ព.ស ២៥១៥ គ.ស ១៩៧១

**គុយ_ឡូត**

# អារម្ភកថា[១]

ប្រទេសកម្ពុជា តាំងពីបាក់បែកបាត់បង់ក្រុងលង្វែកទៅ ក៏ទៅជាប្រទេសមួយតូចទន់ខ្សោយគួរឱ្យស្ដាយ និង ឈឺចាប់ពន់ពេក ។ ការដែលនាំឱ្យប្រទេសកម្ពុជា ដែលធ្លាប់មានកិត្តិស័ព្ទខ្ទរខ្ទារពីសម័យនគរធំ ក្លាយមកជាប្រទេសតូច ចុះអន់អាប់ដុនដាបនេះ គឺមកតែពីអ្នកគ្រប់គ្រងផែនដី ពោលគឺ "ស្ដេចខ្មែរ" នេះតែម្ដង ។

ស្ដេចខ្មែរច្រើនណាស់ដែលសប្បាយភ្លេចខ្លួន ហើយរវល់តែនឹងការពារសិរីរាជសម្បត្តិសម្រាប់ខ្លួន និង គ្រួសារខ្លួន ពុំរវល់ពីរឿងបូរណភាពទឹកដី អធិបតេយ្យជាតិសម្រាប់អនាគតប្រទេសសោះ ។

ការសប្បាយភ្លេចខ្លួននោះ គឺសប្បាយជាពិសេសខាងកាមតណ្ហា ស្រីស្នំ ស្រីង្គារច្រៀង ស្ដាំ រាប់មិនអស់ ។ មិនតែប៉ុណ្ណោះទេ ស្ដេចខ្លះថែមទាំងចូលចិត្តប្រព្រឹត្តអានាចារ្យព្រៃផ្សៃ ទៅលើប្រជាពលរដ្ឋរបស់ខ្លួនទៀតផង ដូចជាឱ្យចាប់យកប្រពន្ធកូនអ្នកស្រុក មកបំពេញតម្រេកត្រេកត្រអាលរបស់ខ្លួន អាងតែខ្លួនជាស្ដេចម្ចាស់ផែនដី ។

ការរំលោភជិះជាន់ញាំញី ជាតិឯងយ៉ាងព្រៃផ្សៃរបស់ស្ដេចនោះ

---

[១] អារម្ភកថានេះ ចម្លងចេញពីកាសែតកោះសន្តិភាព។

មានច្រើនបែបច្រើនយ៉ាងណាស់។

ហេតុនេះហើយ ទើបស្តេចខ្លះត្រូវប្រជាជនក្តៅក្រហាយដល់កម្រិត បះបោរឡើងប្រឆាំងយ៉ាងខ្លូរខ្លារ ហើយស្តេចខ្លះ ក៏ត្រូវគេធ្វើគត់ទៅយ៉ាងអាម៉ាស់។

ក្នុងរឿងមួយដែលយើងនឹងនាំយកមកអធិប្បាយតទៅនេះ គឺជារឿងដែលនិយាយអំពីអំពើពាលអាក្រក់របស់ស្តេចមួយអង្គ ក្នុងបណ្តាស្តេចទុរយស យង់ឃ្នងទាំងឡាយ កាលពីក្នុងសតវត្សទី ១៦ នៃគ.ស។

យើងមិនក្លែងសោះឡើយ រឿងនេះជារឿងពិតដែលយើងបានស្រាវជ្រាវឃើញនៅក្នុងទំព័រនៃព្រះរាជពង្សាវតារ ដែលគេរក្សាជាសម្ងាត់តាំងពីរជ្ជកាលមុនៗមក គេមិនដែលបង្ហាញឱ្យនរណាដឹងឡើយ ។

ឯឈ្មោះ "កែវព្រះភ្លើង" គឺជាឈ្មោះពលរដ្ឋម្នាក់ ដែលបានងើបឡើង នាំមុខគេប្រឆាំងនឹងស្តេចទុរយសនោះដរាបបានជោគជ័យផង។

យើងសង្ឃឹមថា រឿង " កែវព្រះភ្លើង" នេះនឹងបានជាទីពេញចិត្តចំពោះ អស់លោកអ្នកអានសម័យថ្មី គឺសម័យសារធារណរដ្ឋរបស់យើងនេះពុំខាន ឡើយ។

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២០ ខែឧសភា ១៩៧០

**គុយ_ឡុត**

# ១

ទួលតាឯក ជាឈ្មោះភូមិមួយ នៅក្នុងតំបន់ខាងត្បូងនៃរាជធានី ទួល បាសាន[២]។

ទួលតាឯក ជាភូមិមួយមានប្រជាជនរស់នៅសុខក្សេមក្សាន្ត ជាភូមិសម្បូរដោយភោគផលគ្រប់មុខ ផ្តល់សុខសម្បូរសប្បាយដល់ប្រជាពលរដ្ឋដែលអាស្រ័យនៅ។ ទាំងប្រជាពលរដ្ឋ ក៏មានរូបសម្បុរស្អាតបាត ជាទីរាប់អានផងទៀត ។ ទឹកទន្លេមេគង្គ តែងតែមានរលកបោកបក់រឿយៗលើច្រាំងទួលតាឯក បំពេអារម្មណ៍យុវជនយុវតីឱ្យសប្បាយក្សេមក្សេមភិរម្យ។

ក្នុងចំណោមបណ្តាជនរស់នៅដោយសប្បាយនោះ ស្វាមីភរិយាមួយគូកំពុងតែបានទទួលសុភមង្គលដែរ ។ ហើយចំពោះខ្លួនគេផ្ទាល់ គេជឿថា ខ្លួនគេកំពុងតែមានសុភមង្គលវិបុលសុខ ដ៏សែនធំធេងលើសលែងអ្នកឯទៀតផង ។ គូស្វាមីភរិយានេះ គឺនាយថី និង នាងទាវ ។ នាយថី ជាមន្ត្រីរាជការថ្នាក់តូចម្នាក់ នៅក្នុងតំបន់ទួលតាឯកនេះ ។ គេហៅថា ពញាថី ។

---

[២] ទួលបាសាននៅក្នុងតំបន់ស្រីសឈរ សព្វថ្ងៃគឺស្រីសន្ធរខេត្តកំពង់ចាម។

ពញ្ញាថី និង នាងទាវ បានស្គាល់ចិត្តស្គាល់ថ្លើមគ្នាមកដែរហើយ តាំងពីមុនរៀបអាពាហ៍ពិពាហ៍មកម្ល៉េះ ។ មាតាបីតានៃយុវជនយុវតីយល់ចិត្តកូនច្បាស់ ក៏បានព្រមព្រៀងរៀបចំអ្នកទាំងពីរឱ្យបានគ្នាជាគូស្វាមីភរិយា សមតាមគោលបំណងគូសង្សារនេះដោយរីករាយ។

គូស្រករថ្មីនេះស្រឡាញ់គ្នាណាស់ ។ ជីវិតគេទាំងពីរជាជីវិតប្រមូលចូលគ្នាតែមួយ ដង្ហើមរបស់គេទាំងពីរជាដង្ហើមស្របគ្នាតែមួយ ។ គេយល់ចិត្តគ្នាណាស់ គេថ្នាក់ថ្នមគ្នាណាស់ លើសលែងគូស្វាមីភរិយាទាំងឡាយ។

ស័ព្ទទឹករលកដែលបោកច្រាំងខ្សាច់ឮសូរផាៗ បីដូចជាសំណើចក្អាកក្អាយយ៉ាងណា ភាពញញឹមរីករាយគ្មានដាច់របស់គូស្វាមីភរិយានោះក៏លាស់ឡើងខ្ពស់យ៉ាងនោះដែរ ។ គេគ្មានមនោសញ្ចេតនាស្មិតស្រពោនសោះឡើយ។ គេរីករាយជរាប។

ពេលរសៀលនេះ ព្រះអាទិត្យបង្អួន់កំដៅហើយ គេឃើញបុរសស្ត្រី ប្តីប្រពន្ធនេះអង្គុយលំហែកំសាន្តក្រោមម្លប់កខុបមួយដើមនាមុខផ្ទះ។ នៅដើមអំពិលទឹកមួយដើមនាឆ្លាខាងមុខផ្ទះ សារីកាកែវ និង គ្រលីងគ្រលោងស្រែកច្រៀងសប្បាយខ្ញៀវខ្ញារ ។ ឯដើមដូងពីរ បីដើមនៅខាងត្បូងផ្ទះនោះ កំប្រុកមួយកំពុងលោតប្រដេញគ្នា ស្រែកខ្ពតៗ បង្អួតមក

មនុស្សដែលនៅឯដី។

សព្វសត្វទាំងនេះហាក់សប្បាយណាស់។

បរិយាកាសពេលនេះកាន់តែរីករាយភិរម្យខ្លាំងឡើង ។ សារិកាកែវមួយគូកំពុងចចឹកផ្លែអំពិលទឹក ដែលធ្លាក់សំយាកមកក្រោមបណ្ដើរសាសងគ្នាបណ្ដើរ ។ នាងទាវ ក៏ញញឹមនិយាយទៅកាន់ប្ដី ដោយចង្អុលទៅសត្វនោះផង :

-បងនែ៎ , មើលន៎ , សារិកាកែវមួយគូនោះ ពិតជាគូសង្សានឹងគ្នាហើយ ! ន៎ វាចឹកផ្លែអំពិលទឹកបណ្ដើរ ជជែកគ្នាលេងបណ្ដើរ, ឱហ្ន៎ វាសប្បាយណាស់ !

នាយចឺមើលតាមការចង្អុលដ៏ទន់ភ្លន់របស់ស្រី ហើយគេញញឹមតបនាងវិញ :

-ពិតហើយទាវអូន, វាជាគូសង្សារនឹងគ្នា, វាស្រឡាញ់គ្នា វាថ្នាក់ថ្នមគ្នា វាយល់ចិត្តគ្នាណាស់ វាសប្បាយណាស់ សប្បាយដូចយើងដែរ !

-មែនបង, ឱគិតទៅមិនថាមនុស្ស ថាសត្វទេ តែងតែមានគូប្រចាំជីវិតទាំងអស់ ហើយតែងតែស្រឡាញ់ថ្នាក់ថ្នមគូទាំងអស់ ឱ ដូច្នេះហើយតើបានជាចាស់ៗតែងតែប្រដៅយើងជាកូនចៅថា : កុំឱ្យពង្រាត់គូសត្វ ខ្លាចមាន ពៀរវេរា.....

_មែនហើយអូន, ព្រោះការបែកនិរាសប្រាស់ព្រាត់គ្នានោះ នាំឱ្យគូសង្សារកើតទុក្ខខ្លាំងណាស់ ដូចជាសត្វអកដែលចាស់ៗធ្លាប់ដឹងរឿងទុក្ខសោករបស់វាដែលព្រាត់គូនោះ គាត់និយាយថា វាស្រែកយំគ្រលួច ដង្ហោយហៅគូនោះ គួរឱ្យអាណោចអធ័មណាស់ ជួនណាវាមិនទៅរកស៊ីឯណាទេ វាយំទាល់តែស្គមខ្លួន រួចទីបំផុតក៏ស្លាប់ទៅដោយអត់អាហារ ហ៊ឺ.......គួរឱ្យខ្លោចផ្សា ណាស់!

_ ហ៊ឺ, អ៊ីចឹងមែនហើយបង, ទាំងរូបយើងនេះ ក៏ដែរ ឧបមាថា, បើមានគ្រោះកម្មនាំឱ្យបែកគ្នាទៅនោះ យើងមិនដឹងថានឹងកើតទុក្ខយ៉ាងណាទេ, ខ្ញុំ ប្រហែលជាស្លាប់ហើយ ស្លាប់ដូចអកញីហើយបង!

_អ៊ីចឹងហើយអូន, បងវិញ បើព្រាត់អូន, ក៏មុខជានឹងស្លាប់ដូចអកឈ្មោលដែរ.... ប៉ុន្តែយើងមិនត្រូវនាំឧបមាអាក្រក់ អពមង្គលមកនិយាយទេ, យើងគ្មានបែកគ្នាទៅណាទេ, យើងនៅជិតគ្នាដរាប!

នាយឋីប្រញាប់កាត់ដូច្នេះ រួចទាញកាយភរិយាមកនែបខ្លួនដោយស្នេហា ។ រូបគេទាំងពីរហាក់មានស្រមោលតែមួយ គ្មានអ្វីមករំខានបំបែកគេឱ្យឃ្លាតពីគ្នាបានឡើយ។

ប៉ុន្តែគ្រាដែលគេកំពុងអង្គុយកៀកគ្នានេះ ស្រាប់តែស្នូរកុបៗបានលាន់ឡើងមកពីផ្លូវថ្លា ។ គេងាកទៅក៏ឃើញអ្នកជិះសេះជាង ១០នាក់

បរសេះតម្រង់មក ។ គឺជាទាហានហ្លួង ។ អារម្មណ៍រីករាយរបស់គេត្រូវដាច់ភ្លាម, គេបែរជានឹកភ័យម្តងវិញ ។ ទាំងពីរនាក់ឃ្លាតពីគ្នាបន្តិច ។ ពញ្ញាថី ចង់ប្រើភរិយាឱ្យរហ័សរត់ឡើងផ្ទះ ប៉ុន្តែហួសពេលហើយ ដ្បិតពួកទាំងនោះមកដល់ស្រេច, គេទាំងពីរនាក់ប្តីប្រពន្ធ ក៏បែរជានៅស្ងៀមមួយកន្លែងវិញ ។ ទាហានជាន់ខ្ពស់ម្នាក់នៅមុខគេ មានចំណាស់បន្តិចហើយ ពុកមាត់ងខ្វង់ ចិញ្ចើមក្រាស់ ភ្នែកក្រឡោត ទំនងជាមនុស្សកាចគឺលោក កោធា ងារជាអគ្គមហាសេនា ។ លោកនេះបានបញ្ឈប់សេះហើយលើកដៃបន្តិច ប្រាប់ឱ្យអស្សានិកឯទៀតឈប់ផងដែរ ។ ពញ្ញថីស្គាល់ថាន:ឥស្សរជននេះ ហើយគេឱនក្បាលគោរពដោយកោតខ្លាចទាំងនាងទាវ ក៏ដូច្នេះដែរ ។ ពញ្ញាថី ប្រញាប់ពោលយកគួរសម:

- ព្រះតេជគុណទើបតែអញ្ជើញមកពីព្រះរាជធានី ឬ ទាន? ព្រះតេជ គុណអញ្ជើញមកលេងនឹងភូមិទួលតាឯកនេះឬទាន?

លោកកោធា ចោលភ្នែកបន្តិចទៅលើនាងទាវដែលកំពុងឱនមុខរួច ប្រញាប់ញញឹមតបនឹងពញ្ញាថីវិញ:

-អើ, ខ្ញុំពុំមែនមកលេងនឹងភូមិនេះទេ, គឺព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចសព្វព្រះរាជឫទ័យយាងមកក្រសាលនៅទីនេះ, ដោយឮថាស្រុកនេះ សម្បូរសប្បាយណាស់!

ពញ្ញាថីភ្ញាក់ព្រឺត:

-យី, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចសព្វព្រះទ័យយាង មកកន្លែងនេះ?

- អើ, ព្រះអង្គកំពុងទតបំការបេក អំពៅនៅភូមិខាងកើត ឯណោះ បន្តិចទៀតយាងមកដល់ហើយ, ខ្ញុំមកនេះប្រាប់ពញ្ញាឯងឱ្យដឹង មុន ដើម្បីរៀបចំពន្លាសម្រាប់ព្រះអង្គសម្រាកនៅទីនេះ!

- លោកជុំនៅនេះ ឬទាន?

-ទេ, លោកគ្រាន់តែសម្រាកលំហែបន្តិចទេ រួចស្តេចប្រញាប់ ទៅព្រះរាជធានីវិញហើយ!

ពញ្ញាថីបានស្រែកហៅអ្នកស្រុកក្បែរខាងឱ្យមកជួបជុំ ជួយសែង គ្រែ រៀបចំកន្លែងស្តេចគង់ ចងវាំងននបិទបាំងបានភ្លាមៗ ។ ពញ្ញថីនឹក ឃើញដល់ភេសជ្ជៈ ក៏ឱ្យអ្នកស្រុកឡើងដើមដូង កាប់សម្រូតដូងខ្ចីច្រើន ធ្លាយយកមកកាប់ រង់ចាំស្តេច ។ ឯនាងទាវក៏ខ្វល់ខ្វាយជូតកែវ សំអាត ផ្តិលយ៉ាងប្រញាប់ប្រញាល់ជាមួយនឹងស្រីៗ អ្នកស្រុកពីរបីនាក់ទៀត។

ខណ:នោះ សូរគគ្រឹកមកពីខាងកើត រាល់គ្នាក្រឡេកទៅក៏ ឃើញក្បួនរទេះ និង សេះចរតម្រង់មក ។ នៅរទេះកណ្តាលនោះ មាន បិទដំបូលផង ហើយមានអ្នកជិះសេះពាក់អាវក្រហម ដ៏ច្រើននាក់បរ

សេះអមទាំងពីរខាង នៅដៃមានកាន់លំពែងសស្ងាច ចាំងផ្លេកៗទៅនឹងពន្លឺថ្ងៃរសៀល ។ ខណៈនោះ លោកអគ្គមហាសេនាក៏និយាយខ្លាំងៗប្រាប់ទៅរាស្ត្រទាំងអស់គ្នាថា:

- ហ្ន៎! ក្បួនព្រះរាជដំណើរមកដល់ហើយ!

ក្បួនរទេះមកដល់ លោកកោធាក៏ស្ទុះទៅកាន់រទេះកណ្ដាល ឱនក្បាលគោរពទៅក្នុងរទេះនោះ។ បានបន្តិចបុរសម្នាក់ទ្រង់គ្រឿងមាសចិញ្ចែងចិញ្ចាចចេញមុខមក រួចចុះពីរទេះដោយកិរិយារវើកៗថ្នាក់ថ្នមខ្លួនសម្បើម ។ ទាហានទាំងអស់ឱនក្បាលគោរពស្ទើរដល់ដី ។ នេះហើយគឺជាព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ។ ស្ដេចនេះបោះជំហានមកកាន់ពន្លាតាមការណែនាំរបស់លោកអគ្គមហាសេនា ។ ហើយនៅចំពោះមុខស្ដេចនេះ បុរស ៤_៥នាក់ទៀតរំពាត់ខ្សែតីនៅដៃ ស្ទុះរត់មកមុខប្រាប់រាស្ត្រដែលឈរនៅម្ដុំពន្លានោះថា:

_វ៉ែន ប្រញាប់លុតជង្គង់ចុះភ្លាម ។ ព្រះករុណាយាងមកដល់ហើយ... កុំងើបមុខសោះ!

ទាំងអស់គ្នា រាស្ត្រដែលមកធ្វើពន្លានោះ ក៏លុតជង្គង់គ្រឹបៗក្រាបក្បាលឱនចុះ មុខឈ្ងោកដី ដៃប្រណម្យ ។ ឯពញាថី និងនាងទាវដែលនៅអង្គុយចាំគាល់ក្នុងពន្លានោះ ក៏តាំងវង់ចាំប្រតិបត្តិតាមដែរ។

នេះជារបៀបដែលគេទទួលដឹងឮគ្រប់ទិសទី គឺឱ្យតែស្ដេចទ្រង់យាងទៅកាន់កន្លែងណា, រាស្ត្រដែលនៅតាមដងផ្លូវនោះ ត្រូវប្រញាប់លុតជង្គង់ លើកដៃប្រណម្យ ឈ្ងោកមុខចុះដាដរាប គ្មាននរណាហ៊ានងើបមុខ មើលមុខហ្លួងទេ អ្នកណាហ៊ានបង្ហើបក្បាលមើលមុខហ្លួងឱ្យតែទាហានក្រុមវាំងឃើញទាន់ គេនឹងស្ទុះទៅវាយឱ្យក្រាបទៅវិញភ្លាម ឬចាប់យកទៅវាយផ្ដើចាបនៅក្រោយដំណើរហ្លួននោះទៀតផង។ ដូច្នេះឱ្យតែឮថាហ្លួងយាងមកដល់ហើយ គេប្រាប់ឱ្យលុតជង្គង់ក្រាមមុខនោះ រាស្ត្រទាំងអស់គ្នាត្រូវតែប្រញាប់លុតជង្គង់គ្រឹបៗ ក្នុងបន្ទាក៏ដោយ ក្នុងភក់ក៏ដោយ ។ ហេតុអ្វីក៏ដូច្នេះ? បានជាដូច្នេះ ពីព្រោះគេទុកហ្លួងជាទេវតា ព្រះឥន្ទ្រ ព្រះព្រហ្ម ឯរាស្ត្រគឺជាមនុស្សថោកទាប ថ្លោះថ្លាប ។ មនុស្សថោកទាបថ្លោះថ្លាបមិនត្រូវហ៊ានមើលមុខទេវតា ព្រះឥន្ទ្រ ព្រះព្រហ្មទេ ។

ពេលនោះ ព្រះរាជាបានយាងកាត់មនុស្សជាច្រើននាក់ដែលក្រាបប្រណម្យក្រាបមុខ ចូលមកក្នុងពន្លា ។ ឯពញាឋី និង នាងទាវ ក៏ប្រញាប់ថ្វាយបង្គំដោយគោរព ។ លោកអគ្គមហាសេនាប្រញាប់សុំស្ដេចយាងគង់លើអាសនៈរួចក្រាបបង្គំថា:

-សូមទ្រង់ព្រះមេត្តាប្រោស, ប្រជាជនកូនចៅក្រោមល្អងធូលី

ព្រះបាទ បានរៀបចំពន្លាត្រង់នេះសមរម្យណាស់ ទីនេះមានធាតុអាកាសត្រជាក់ក្សេមក្សាន្តណាស់ ដ្បិតនៅជិតមាត់ទន្លេ មានខ្យល់បក់មកត្រជាក់ស្រួល!

សូមទ្រង់ព្រះមេត្តាប្រោស កន្លែងនេះជាតំបន់របស់ពញ្ញានេះនិង ភរិយាគេនេះឯង កន្លែងនេះគេរៀបចំស្រួលក្រាបទូល!

ព្រះរាជានេះងក់ព្រះកេសទទួល រួចទតទៅនាងទាវដែលកំពុងប្រណម្យ។ លោកអគ្គមហាសេនាក៏ប្រញាប់ប្រាប់នាង:

- នែនាង, ថ្វាយព្រះរាជភេសជ្ជៈទឹកដូងចំពោះព្រះករុណាទៅ!

នាងទាវ ក៏បានរំកិលខ្លួនទៅលើកដ្ដិលទឹកដូងថ្វាយទៅព្រះរាជា រួចថយមកអង្គុយទីមនឹងប្ដីនាងវិញ មុខដាក់ចុះដដែលដោយគោរពខ្លបខ្លាចដ៏ខ្លាំង។

ឯលោកគោធា ក៏ថយចេញទៅវិញ អ្នកស្រុកក៏ជូនទឹកដូងយ៉ាងប្រញាប់ ។ ទាហានទាំងអស់គ្នា ក៏កាប់ដូងផឹកទឹកអាស្រ័យសាច់យ៉ាងសប្បាយ។

ស្ដេចនេះវិញ មើលទៅរូបនាងទាវដោយពិនិត្យយកចិត្តទុកដាក់ជាទីបំផុត។

សម្ផស្សធម្មជាតិរបស់នាងទាវ ធ្វើឱ្យដួងហឫទ័យនៃស្ដេចនេះ

រំភើបប្លែកអស្ចារ្យ ។ ហើយដោយចង់គយគន់វង្សភក្ត្រឱ្យបានសព្វគ្រប់ ថែមទៀតនោះ ស្តេចនេះក៏ធ្វើជាមានបន្ទូលទៅកាន់ពញាថី និង នាង ដោយសម្លេងស្រាល:

-នែពញា និង នាង ងើបមុខឡើង, ខ្ញុំអនុញ្ញាតឱ្យហើយ!

ទាំងពីរនាក់ភរិយាស្វាមី ក៏ហ៊ានងើបមុខឡើងបន្តិច តែភ្នែកនៅតែដាក់ចុះដដែល ឥតហ៊ានមើលព្រះភក្ត្រស្តេចសោះឡើយ ដៃក៏នៅតែសំពះជាប់។

ស្តេចសម្លឹងភក្ត្រនាងទាវ ដោយឥតដកខ្សែនេត្រាសោះឡើយ ហាក់ដូចជាប់ដោយវេទមន្តអ្វីមួយតែម្តង ។ នាងទាវលបចោលភ្នែកមើលទៅស្តេច ឃើញស្តេចសម្លឹងនាង នាងក៏ប្រញាប់ដាក់ភ្នែកចុះដោយភ័យ។

ស្តេចអង្គនេះ គ្រាន់តែបានគយគន់រូបសម្បត្តិនាងទាវមួយរយៈប៉ុណ្ណោះ ក៏ចាប់ចិត្តប្រតិព័ទ្ធភ្លាម រំជើបរំជួលណាស់ នឹកសរសើរតែក្នុងពោះថា: យីនាងនេះស្អាតបវរណាស់!

មែនពិតនាងទាវមានលំអគួរពិសម័យពេកណាស់ ។ មើលចុះ ! ថ្ពាល់នាងឡើងកំពុងរលីងផូរផង់ ពណ៌ជំពូទុំ សមនឹងចិញ្ចើមខ្មៅស្ទើងកោងចុះដូចដងធ្នូមួយគូដែលដាក់ផ្កាប់គ្របពីលើដួងនេត្រា ។ គ្រាប់ភ្នែកនាងខ្មៅថ្លាដូចត្បូងនិល ដែលគេបង្កប់នៅក្នុងស្រទាប់ផ្កាកូលាប ។

ប្រមុះនាងរាងស្រួច គោងខុបខាងចុង បង្អួតសំយុងមកលើប្រអប់មាត់ដែលតូចសម ។ បបូរមាត់នាងរាងស្តើង ពណ៌ក្រហមដិតស្លា សមនឹងចង្កាដែលទាលខ្ចី គួរឱ្យចង់អង្អែលលេង ។ សក់នាងខ្មៅរលោងដូចស្លាបកន្ធង់ វែងអន្លាយ ញែកជាពីរសំយុងកាត់តាមទងត្រចៀក ធ្លាក់មកអង្អែលនទៀលលើដើមទ្រូងដែលពើងចចើលដោយថនាដ៏ក្បុំ។

គួរឱ្យចាប់អារម្មណ៍ណាស់ នាងមានផ្ចិតកសម៉ដ្ឋខៃ វិស័យដូចគេយកលំអងផ្កាទៅសោមស្រឡាច ។ គន់មើលទៅដើមដៃទាំងគូដែលនាងប្រណម្យ ក៏ណែនត្រសូលមូលត្រសាយដូចភ្លុករគជសីហ៍ គួរឱ្យចង់កាន់ប៉ះពាល់បរបោសអង្អែលណាស់ ។ ត្រគាកនាងរាលរីកសាយទូលាយដល់ផ្ចិតក្លៅ មើលទៅគួរឱ្យស្រើបរំភើបចិត្តឥតបីបើថ្លែង ។ ចង្កេះនាងរាងរៀវសមរម្យ គន់យូរទៅកើតមានបំណងចង់បីពទ្រក្បាកាន់តែខ្លាំងឡើងៗ !

អ្ហ៎ , នាងទាវស្អាតណាស់ សមរម្យណាស់ , ល្អណាស់,

ស្តេចនេះមើលនាងទាវទាល់តែភ្លេចភ្លឹក បានបន្តិចទើបនឹកឃើញមានស្មារតី លើផ្តិលទឹកដូងក្រេបមួយក្អឹកពីរ រួចធ្វើជាសំណេះសំណាលនឹងពញាថា :

_ហ៊ឹះ, ពញាឯងនេះរៀបចំទទួលខ្ញុំសមរម្យណាស់ ទាំងទឹកដូង

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.

នេះក៏ផ្អែមណាស់ផង ខ្ញុំសប្បាយណាស់ ខ្ញុំពេញចិត្តនឹងពញ្ញាឯងណាស់!

- ព្រះករុណាវិសេស!

ពញ្ញាថីទទួលពាក្យសរសើរនេះ ដោយលើកដៃប្រណម្យខ្ពស់បន្តិចផង។

ស្តេចនេះក៏បន្តសំណួររឿងថ្មីទៀត:

- អើ, ពញ្ញាឯង និងភរិយា បានរៀបអាពាហ៍ពិពាហ៍យូរហើយឬ?

-ព្រះករុណាថ្លៃវិសេស, ទូលបង្គំ និង ភរិយាទូលបង្គំបានរៀបអាពាហ៍ ពិពាហ៍គ្នាប្រហែលជាកន្លះឆ្នាំហើយក្រាបទូល!

-អើ ទើបតែការគ្នាដែរ , អ៊ីចឹងបានជាខ្ញុំឃើញដូចជាគូស្រករថ្មីថ្មោងសោះ! អើ តើពញ្ញាឯងឈ្មោះអ្វី? ហើយនាងណោះឈ្មោះអ្វី?

-សូមទ្រង់ព្រះមេត្តាប្រោស ទូលព្រះបង្គំនាមថី ចំណែកភរិយាទូលបង្គំនាមទាវ! ក្រាបទូល!

ស្តេចនេះងក់ព្រះកេសញញឹម:

-យី ឈ្មោះក៏សមគ្នាទៀត ខ្ញុំសូមសរសើរឯងហើយ, ហើយខ្ញុំសង្កេតយូរទៅ រូបរាងសាច់ឈាមពញ្ញាឯង និង ភរិយានេះ មិនសមនឹងនៅដោយស្រុកស្រែចំការដូច្នេះទេ! សមតែទៅនឹងក្រុង ក្នុងវាំងឯណោះទេ!

[library stamp]

ពញ្ញាថី មើលមុខភរិយា រួចងាកមកទូលតប:

-សូមទ្រង់ព្រះមេត្តាប្រោស ឋាន:ទាបតូចរបស់ទូលបង្គំជាខ្ញុំបាន រស់នៅនឹងតំបន់ដ៏ឬច្នេះជាការសមរម្យហើយ, ទូលបង្គំជាខ្ញុំសប្បាយចិត្ត នឹងធ្វើការបំរើរាជការផែនដី ដែលមានល្អងធូលីព្រះបាទជាម្លប់ហើយ ក្រាបទូល!

-អើ ខំធ្វើការតទៅទៀតចុះ!

ពញ្ញាថី លើកដៃប្រណម្យទទួលព្រះបរមរាជឱង្ការដោយគោរព។

គ្រានោះ ព្រះអាទិត្យជិតអស្តង្គតហើយ ព្រះមហាក្សត្រក៏ល្មម នឹងយាងនិវត្តត្រឡប់ទៅព្រះរាជធានីវិញដែរ។

លោកអគ្គមហាសេនា និងនាម៉ឺនសព្វមុខមន្ត្រី ក៏បានរៀបចំក្បួន ដង្ហែព្រះមហាក្សត្រចេញពីពន្លា ។ ស្តេចនេះឆ្លៀតមើលមុខនាងទាវម្តង ទៀត មុននឹងចូលទៅក្នុងរទេះដំបូល។

ក្បួនរទេះរបស់ស្តេចបានចេញផុតទៅ រាស្ត្រទាសរាល់គ្នាក៏បាន ពេល ត្រឡប់ទៅផ្ទះវិញរៀងខ្លួនដែរ។

ឯពញ្ញាថីក៏នាំភរិយាឡើងផ្ទះវិញ ។ គេនិយាយនឹងនាងដូច ជាបានធូរទ្រូងបន្តិច:

-ហ៊ឺ អូន, បានព្រះរាជា និង អស់លោកនេះចេញទៅ បងដូចជា

ដកបន្ទាពីទ្រូង បងស្មានតែស្តេចលោកនៅក្រាញូនេះមួយយប់ទៀត បើនៅទីនេះ បងពិបាកចិត្តស្លាប់ហើយ !

នាងទាវចាប់តាំងពីឃើញអាកប្បកិរិយារបស់ព្រះរាជាដែលបានសង្កេតសំគាល់នាងនោះ នាងកើតបារម្ភជាប់ នាងនឹកភ័យមិនតិចឡើយ:

-ហ៊ឺ បង, បងមានសង្កេតទេ? ព្រះករុណាបេះតែសម្លឹងមុខខ្ញុំហើយ អាកប្បកិរិយាលោកដូចជាប្លែកណាស់ ! ខ្ញុំខ្លាចលោកណាស់បង !

នាយជី ក៏បានសង្កេតព្រះរាជាហើយឃើញថា ស្តេចនេះប្លែកមែន ក៏នឹកព្រួយដែរ ប៉ុន្តែគេនឹកថា មើលទៅព្រះរាជានេះមិនមានអាក្រក់ ចំពោះរូបគេទេ ក៏ថា :

-មែនអូន ប៉ុន្តែមើលទៅព្រះករុណាល្អលើយើងទេ លោកមើលអូនព្រោះតែឃើញរូបស្អាតប៉ុណ្ណោះ លោកគ្មានត្រូវការស្អីទេ ដ្បិតអូនជាប្រពន្ធបងទៅហើយ !

រួចគេឱ្យកិរិយានេះដណ្តាំបាយបរិភោគ ព្រោះពេលល្ងាចក៏មកដល់ហើយ។

ពេលអាស្រ័យបាយ គេអាស្រ័យទុលមុខគ្នា ។ នាងទាវបេះសាច់ត្រីដាក់ឱ្យប្តីដោយទឹកមុខញញឹម នាងផ្តាប់ប្តីណាស់ ។ ពញាជី ក៏ចូលចិត្តលេងនឹងប្រពន្ធណាស់ដែរ គេពូតបាយបញ្ចុកនាងជាកំប្លែង ហើយសើច

លេងយ៉ាងសប្បាយ។

គូស្រករនេះមានសុភមង្គលណាស់។

## ២

យើងក្រឡេកទៅមើលព្រះមហាក្សត្រ ឯណោះវិញម្តង។

ព្រះមហាក្សត្រ ដែលយើងបានឃើញនៅទួលតាឯកមកហើយនេះ មានព្រះនាមថា "ព្រះបាទពញាអន" ស្តេចនេះទើបនឹងឡើងសោយរាជ្យ (គ.ស ១៥៩៧)

ព្រះបាទពញាអន ជាក្សត្រត្រេកសប្បាយភ្លើតភ្លើននឹងកាមគុណពន់ពេកណាស់ ។ ស្រីៗគឺជាចំណីតណ្ហារបស់ព្រះអង្គ ។ ស្តេចសោយរាជ្យភ្លាម បានឱ្យគេរកស្រីក្រមុំកូនចៅអ្នកស្រុកយកមកបំប៉នតណ្ហាព្រះអង្គដោយសប្បាយ។

តើនរណានឹងហ៊ានប្រចាំង, បើព្រះបាទពញាអនគឺជា "អម្ចាស់ជីវិតលើត្បូង" ទៅហើយនោះ? អម្ចាស់ជីវិតលើត្បូង គឺអម្ចាស់ជីវិតលើក្បាលរបស់រាស្ត្រគ្រប់គ្នា ចង់ឱ្យជីវិតរាស្ត្ររស់, រស់ ! ចង់ឱ្យស្លាប់ជីវិតរាស្ត្រណាស្លាប់, ស្លាប់។

ដូច្នេះ បណ្តារាស្ត្រដែលផ្ញើជីវិត និងព្រះបាទពញាអននៅក្បែរៗព្រះរាជធានីនោះ បាក់បបខ្លបខ្លាចអំណាចស្តេចនេះពន់ប្រមាណ ។ បើស្តេចនេះត្រូវការកូនចៅហើយ ពុំហ៊ានជំទាស់តវ៉ាប្រកែកអ្វីឡើយ។ គេ

ត្រូវតែប្រគល់កូន ចៅទៅស្ដេចនេះទាំងទឹកភ្នែកទឹកសម្បោរទៅ។

ដូច្នេះ ស្រីៗដែលនៅភូមិក្បែរវាំងទាំងប៉ុន្មាន សុទ្ធតែជាស្រីដែល ព្រះបាទពញាអនទុកជាស្នំស្រីង្គារ សម្រាប់ត្រេកត្រអាលទាំងអស់។

ស្រីស្នំក្នុងរាប់មិនអស់ ហៀរចេញមកក្រៅវាំងទៀត តើចំនួននេះអាចបំប៉នតណ្ហាព្រះបាទពញាអនគ្រប់គ្រាន់ទេ ? តាមគិតឃើញគេយល់ថាប្រាកដជាគ្រប់គ្រាន់ហើយ ! ប៉ុន្តែ ព្រះពញាអន ដូចជានៅពុំទាន់ស្កប់ស្កល់សោះ ស្ដេចតែងតែសព្វព្រះទ័យឱ្យគេជ្រើសរើសស្រីៗថ្មីៗថែមទៀត ។ ហើយដើម្បីកុំឱ្យចង្អៀតវាំងអត់ប្រយោជន៍នោះ ស្ដេចសព្វព្រះទ័យឱ្យគេដោះលែងនាងណាដែលរូបមិនសូវបាន ឬក៏នាងណាដែលស្ដេចជិនណាយ ទៅហើយនោះ ឱ្យចេញទៅនៅក្រៅវាំង យកប្ដីសីចុះ ។

គិតទៅ, ទាល់តែឆ្អែតកំពុបហៀរហូរទើបគេសុខចិត្តដោះលែងឱ្យមានសេរីភាព ។

ឯលោកអគ្គមហាសេនា និង ឯកអាមាត្យជាបរិវារទាំងអស់ ក៏គ្មានដែលនឹកនាសោះថា យ៉ាងម៉េចដែលហៅថាកិច្ចការប្រទេសជាតិមាតុភូមិនោះ ។ ម្នាក់ៗគិតតែខំផ្គាប់ផ្គុនបំប៉នតណ្ហាព្រះចៅក្មេងយ៉ាងស្មោះស្ម័គ្រ ។ ស្ដេចមានបំណងចង់បានអ្វីៗ ក៏តាំងដាំក្បាលឈ្ងុចសម្រេចរកយកមកថ្វាយបានភ្លាម ជាពិសេសគឺរឿងស្រីញីនេះឯង ។

ដូចជាព្រះរាជទស្សនកិច្ចនៅតំបន់ទួលតាឯក ដែលយើងជួបមកហើយនេះ ពុំមែនជាទស្សនកិច្ចសាកសួរសុខទុក្ខប្រជារាស្ត្រអ្វីទេតាមពិត គឺស្តេចចង់សប្បាយនឹងមើលស្រុកភូមិ ជាពិសេសចង់ឃើញលំអស្រីៗដែលនៅឆ្ងាយអំពីព្រះរាជធានីនោះទៀតតែប៉ុណ្ណោះ ដោយសារពួកអាមាត្យឧស្សាហ៍ថ្វាយដំណឹងថា នៅទួលតាឯកនោះមានស្រីល្អ ៗ ហើយស្រុកនោះក៏សម្បូរសប្បាយផង ។

បើស្តេច និង ពួកបរិវារគិតតែពីសប្បាយមួយបែបដូច្នេះហើយ តើមានពេលឯណា និងគិតគូររឿងស្រុកទេស ? គ្មានទេ !

យើងតាមមើលរឿងស្តេចនេះតទៅទៀត ។

យប់មួយនោះ ប្រទីបផ្កាលាភ្លឺព្រោងព្រាត ឯភ្លេងក៏ចាប់ប្រគំពិរោះ កំដរពេលរាត្រីថ្វាយមនោរម្យចំពោះព្រះចៅក្មេងឱ្យក្សាន្តភិរម្យ ។

នៅក្នុងបន្ទប់ទែនសយនាដ៏មានកម្រាលទន់ល្មើយ ព្រះចៅទ្រង់ផ្ទំស្ងៀម ទតទៅពន្លឺចង្កៀងមួយដែលញ្ជូរក្បែរវាំងនននភ្លឺស្រទន់ដោយអារម្មណ៍ត្រជាក់ ។

ស្រមោលនារីពីររូបដែលតែងខ្លួនរលើបរលង់ បានវារឱនចូលមករកព្រះទែន ។ នៅពីក្រោយជាប់នឹងនាងពីររូបនេះ ស្រីកណ្តាលអាយុម្នាក់បានរំកិលចូលមកដែរ ។ ជិតដល់ព្រះទែន ទើបព្រះចៅងាកទតទៅ

ស្រីទាំងញញឹមបន្តិច ទើបសួរស្រីចាស់នោះថា:

-ម៉េចម៉ែវីន, ល្ងាចនេះត្រូវវេននាងទាំងពីរនេះឬ?

-ពរម្ចាស់, ត្រូវវេននាងហើយ, តាមតែទ្រង់សព្វព្រះរាជហឫទ័យចុះ, ខ្ញុំម្ចាស់ផ្ចិតផ្ចង់ណាស់ក្រាបទូល!

-អើល្អណាស់!

ស្ដេចនេះ មើលទៅនារីម្នាក់ដែលមានទឹកមុខស្រពាប់ស្រពោន ស្ដេចលូកដៃទៅចាប់ចង្កានាងភ្ញើយមុខឡើង រួចមានបន្ទូលទៅកាន់ស្រីស្នំចាស់:

-ម៉ែវីន, នាងនេះឈ្មោះអ្វី?

-ពរម្ចាស់, នាងឈ្មោះសារិកា ក្រាបទូល!

-ម៉ែវីន, នាងស្រីល្អនេះពុំដែលរីករាយសោះ ខ្ញុំសំគាល់រាល់ដង ឃើញតែស្រពោនអ៊ុំចេះឯង, ម៉េចម៉ែវីន ឯងមិនជួយពន្យល់នាងឱ្យបានសប្បាយផង?

-ពរម្ចាស់, អស់យល់តាមខ្ញុំម្ចាស់ហើយ លក្ខណ:នាងសារិកាចេះតែអ៊ុំចឹងក្រាបទូល!

-អើ, ប៉ុន្តែមិនអីទេ រូបនាងស្អាតណាស់ បើទុកជាស្រពោនក៏នៅតែស្រស់ដែរ! អើ ម៉ែវីនឯងចេញទៅវិញចុះ!

ស្រីស្នំចាស់លូនថយមកក្រោយ ហើយឈោងបិទវាំងននជិតស្រួលបួល ហើយថយចុះទៅកន្លែងវិញ ។

ស្រីចាស់ដែលហ្លួងហៅថាម៉ែនេះ ជាស្នំជើងចាស់ខាងការតុបតែងកាយស្រីៗ នាំយកមកថ្វាយស្តេចរាល់រាត្រី ។ មានដំណាក់មួយដាក់សុទ្ធតែស្រីៗ ប្រមាណជា៥០នាក់ នៅក្រោមបង្គាប់ម៉ែវិននេះ ។

ម៉ែវិនគ្មានព្រួយអ្វីទេ ព្រួយមួយតែគ្មានស្រីល្អៗយកទៅថ្វាយហ្លួងប៉ុណ្ណោះ ។

ពេលដែលមកដល់កន្លែងវិញ ម៉ែវិនក៏ប្រះដេកលើគ្រែធ្វើព្រងើយ ហើយស្រីៗពីរបីនាក់ទៀត ក៏ចូលមកគក់ច្របាច់ឱ្យដោយយកចិត្តទុកដាក់ គឺជាពួកជំនិតរបស់គាត់។

នៅដំណាក់ស្តេចឯណោះវិញ មានសភាពស្ងប់ស្ងៀមសុខសាន្ត ។ ភ្លេងឈប់លេង នៅសល់តែសម្លេងសព្ទល្អិតចង្រិតរៃ ស្រែករោទ៍ចេញពីគុម្ពផ្កាប៉ុណ្ណោះ ដែលនៅបន្តកំដររាត្រីតទៅទៀត ។

ម៉ែវិនដែលមានត្រចៀកចាំតែស្តាប់ជាប់នោះ គាត់ចុះពីកន្លែងគាត់ភ្លាម ឡើងទៅព្រះរាជដំណាក់ លូនទៅរកព្រះទែន ។ គ្រានោះ ស្រីទាំងពីរដែលគាត់នាំយកទៅពីល្ងាច បានរើកវាំងននចេញមក មានសម្លៀកបំពាក់ខ្វះរបៀបរៀបរយ ។ ក្រោយស្រីទាំងពីរនោះ ព្រះពញា

អនបេញមកដែរ មានបន្ទូលមកកាន់ស្នំចាស់:

_ម៉ែវីនឯងនាំនាងនេះទៅវិញចុះ ហើយមិនបាច់នាំនាងណាមកទៀតទេ ខ្ញុំត្រូវការគិតស្ងប់ស្ងាត់បន្តិច!

_ពរម្ចាស់!

ម៉ែវីននាំស្រីទាំងពីរត្រឡប់ទៅវិញ ។ ព្រះពញាអនចូលទៅគង់លើព្រះទែនវិញ ប្រះផ្ទៃយកដៃគងថ្ងាស ទំនងត្រិះរិះគិតគូររឿងអ្វីមួយ ។ មួយស្របក់ក្រោយមក ជនកំពូលនេះលូកដៃទៅគោះរគាំងលើក្បាលដំណេកនោះបន្តិច ។

អាមាត្យម្នាក់ដើរវារចូលមក ជននោះក៏បង្គាប់ថា:

_នែ ឯងទៅហៅលោកអគ្គមហាសេនាមួយភ្លែត ! អញមានការណ៍!

_ព្រះករុណាថ្លៃវិសេស!

អាមាត្យនោះវារថយក្រោយវិញដូចជាសត្វអណ្តើក ដែលគេទាញកន្ទុយថយក្រោយ ។

មិនបាន ៤_១០ ដង្ហើមផង លោកអគ្គមហាសេនាបានឡើងមកដល់ក្រាបបង្គំទូលសួរ:

_សូមទ្រង់ព្រះមេត្តាប្រោស, ល្អងធូលីព្រះបាទមានកិច្ចការអ្វីជា

សំខាន់ឬ បានជាហៅទូលបង្គំជាខ្ញុំឱ្យឡើងគាល់ទាំងកណ្ដាលរាត្រីដូច្នេះក្រាបទូល?

ស្ដេចនេះញញឹម:

-លោក, កិច្ចការនេះនឹងថាជាការសំខាន់ក៏ថាបាន ព្រោះវាជាការរបស់ខ្ញុំ ! អើកាលពីថ្ងៃមុនលោកមាននឹកឃើញទេ? តើលោកប្រទះឃើញអ្វីខ្លះ?

លោកអគ្គសេនាដូចជានៅងឹងងើ:

-សូមទ្រង់ព្រះមេត្តាប្រោស, ទូលព្រះបង្គំជាខ្ញុំដូចជាពុំទាន់យល់, ព្រះករុណាចង់មានបន្ទូលពីរឿងអ្វី?

-ហ៊ឺ! លោកមិនបានសង្កេតស្រីម្នាក់នៅភូមិទួលតាឯកទេឬ? លោកកោធានឹកឃើញ ក៏តបដូចជាភ្ញាក់

-សូមទ្រង់ព្រះមេត្តាប្រោស, ទូលបង្គំនឹកឃើញហើយ យល់ហើយ នាងនោះល្អណាស់ ស្អាតណាស់, ប៉ុន្ដែតើល្អងធូលីព្រះបាទសព្វព្រះទ័យឬ បើនាងជាប្រពន្ធរបស់ពញានោះទៅហើយ?

-យល់ចិត្តខ្ញុំហើយ មិនបាច់សួរខ្ញុំទេ ប្រពន្ធនរណាក៏ដោយ ឱ្យតែត្រូវភ្នែកខ្ញុំហើយ ខ្ញុំស្រលាញ់ទាំងអស់ ! ហើយចំពោះនាងនៅទួលតាឯកនោះ ល្អលើសលែងស្រីទាំងអស់ដែលខ្ញុំបានជួបទៅទៀត!

បុរសម្នាក់នេះ ដាក់មុខចុះ ទំនងត្រិះរិះរួចងើបឡើងវិញទូលថា:

-ទូលបង្គំជាខ្ញុំ នឹងចាត់លោកមហាមន្ត្រីឱ្យទៅនាំនាងមកថ្វាយល្អងធូលីព្រះបាទ នៅព្រឹកស្អែកនេះក្រាបទូល!

-អ៊ីចឹងហើយ, ប៉ុន្តែ ដើម្បីកុំឱ្យអាក្រក់មើលពេក យើងត្រូវសម្រួលការនេះឱ្យស្រួលបន្តិចៗ ជាការស្រួល ខ្ញុំយល់ថាត្រូវហៅពញ្ញាជាប្តីនោះឱ្យមកជាមួយប្រពន្ធផងចុះ យើងថាឱ្យប្តីមកនៅធ្វើការក្នុងវាំង ហើយឱ្យប្រពន្ធជួយធ្វើការបំរើស្រីស្នំផ្សេងៗនៅក្នុងវាំងដែរ ។ ថាខ្ញុំជាម្ចាស់ផែនដី មានសេចក្តីអាណិតមេត្តាណាស់ ដ្បិតឃើញវាគូស្រករថ្មីនោះមានសភាពស្លូតបូតសមរម្យ។ យើងធ្វើដូច្នេះ។ លុះវាមកដល់កណ្តាប់ដៃយើងហើយនោះ ស្រេចតែយើងសម្រេច! ខ្ញុំគិតនេះសមរម្យទេ?

-ព្រះករុណាថ្លៃវិសេស, ល្អងធូលីព្រះបាទទ្រង់ព្រះតម្រិះនេះសមរម្យណាស់, ព្រះរាជយោបល់នេះល្អណាស់, យើងធ្វើដូច្នេះគ្មានរាស្ត្រណាម្នាក់ដឹងថាព្រះករុណាទៅនាំប្រពន្ធគេមកទេ ! ឯពញ្ញានោះមើលទៅឱ្យតែគ្នាបានមកនៅវាំង គ្នាមុខជានឹងគោរពព្រះអង្គទ្រង់មួយជាដប់ទៅហើយ! គ្មានជំទាស់នឹងព្រះរាជបំណងព្រះអង្គទេ!

-អើ ស្អែកលោកចាត់ការតាមរបៀបស្លូតអ៊ីចឹងទៅ!

-ព្រះករុណាថ្លៃវិសេស,

លោកអគ្គមហាសេនាក្រាបកំបង់អញ្ជលី ថ្វាយបង្គំលាព្រះចៅក្មេងនេះ ត្រឡប់ថយចុះទៅទីកន្លែងវិញ ។

គិតទៅ គេគ្មានគិតអ្វីក្រៅពីរឿងអាស្រូវព្រៃផ្សៃដូច្នេះសោះឡើយ ។

ព្រឹកឡើងលោកអគ្គមហាសេនា ប្រើលោកមហាមន្ត្រីឱ្យនាំទាហានសេះចំនួនដប់នាក់ ឆ្ពោះទៅកាន់ភូមិទួលតាឯក នាំសំបុត្រពិសេសទៅឱ្យពញាទៅភូមិតាឯកនោះ ។

យើងមើលទៅភូមិទួលតាឯកឯណោះវិញ ។

ពេលនោះជាពេលលោកទ្រង់បាត្រហើយ ។ សម្លេងបង្អួសៗនៃក្មេងសិស្សលោកថា:

" ដាក់_បាត្រ, ចង្ហាន់លោក ! " " ទាន់ចង្ហាន់លោកទេ !" ....បានលាន់ឡើង ។ កូនសិស្សលោកអាយុ ៦_៧ ឆ្នាំ ដែលដើរតាមលោកបានស្រែកហូរហែនូវពាក្យនេះ គ្រាដែលលោកនិមន្តជិតទៅដល់ផ្ទះមួយៗ ដើម្បីឱ្យអ្នកផ្ទះទាំងនោះ យកបាយសម្លមកដាក់បាត្រលោក ។ ឯអ្នកផ្ទះដែលនៅឆ្ងាយ លោកនិមន្តទៅពុំទាន់ដល់ ឮពាក្យក្មេងស្រែកនេះ ក៏តាំងប្រុងប្រៀបបាយសម្លជាស្រេចដែរចាំដាក់បាត្រលោក ។

ពាក្យនេះកូនសិស្សលោកបានប្រើជាពាក្យអំពាវនាវឬក៏

ប្រកាសឱ្យអ្នកភូមិដឹងមុន។

ពាក្យនេះជាទម្លាប់របស់កូនសិស្សលោកតាំងពីបូរាណកាលមក។ ទំនុកនេះគួរកុលបុត្រដែលមិនធ្លាប់ដើរតាមលោកបិណ្ឌបាត្រ, ដែលមិនធ្លាប់នៅស្រុកស្រែចំការកត់ចាំតទៅចុះ ! ព្រោះជាពាក្យប្រព្រឹត្តប្រក្រតីរបស់ក្មេងវត្តនៅស្រុកស្រែចំការយើង ។ យើងក្មេងស្រករក្រោយត្រូវដឹងថា ពាក្យនេះជាវប្បធម៌ខាងព្រះពុទ្ធសាសនារបស់យើងដែរ បើយើងមិនដឹង យើងនឹងខ្វះនូវចំណេះវប្បធម៌ផ្នែកនេះបន្តិចដែរ ។ ហេតុនេះទើបអ្នកនិពន្ធឆ្លៀតលូកដាក់ត្រង់ផ្នែកនេះបន្តិច ឱ្យយុវជនយើងបានដឹងផង ។ ឯអ្នកដែលដឹងហើយ ព្រោះធ្លាប់រស់នៅនឹងវត្តអារាមស្រុកស្រែចំការនោះសូមរំលងវគ្គត្រង់នេះចោលចៅចុះ ។ យើងនាំគ្នាមើលនាងទាវឯនោះវិញ។

នាងដណ្តាំបាយស្រេច ពញ្ញាថី ប្តីនាងពុំទាន់មកពីធ្វើការនៅសាលាស្រុកឡើយទេ ។ នាងឮក្មេងវត្តស្រែក "ដាក់ចង្ហាន់លោក" នាងប្រញាប់ដោះដួសបាយសម្លទុកដាក់បាត្រ។

គ្រានោះ ព្រះសង្ឃកូននេនមួយអង្គក៏និមន្តមកដល់ នាងក៏យួរចានស្រាក់ និង កាន់ផ្តិលបាយចុះទៅដាក់បាត្រលោកដោយជ្រះថ្លា ។ កិរិយារបស់នាងទន់ភ្លន់ណាស់ នាងដាក់បាត្រហើយ ក៏សំពះលោក

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ដោយសមរម្យ ។ ចំពោះចានស្រាក់វិញ នាងនិយាយទៅកាន់កូនសិស្ស លោកថា " អាអូនឯងផ្ទេរយកមក ឱ្យបងវិញផងព្រឹកស្អែក !"

ព្រះសង្ឃនិមន្តផុតទៅ នាងក៏ឡើងទៅលើផ្ទះវិញ រៀបចំម្ហូបអាហាររង់ចាំប្តី ។ នាងហាក់ដូចជាមានការទន្ទឹងប្តីខ្លាំណាស់ ។ កំពុងរង់ចាំនេះ ប្តីនាងក៏មកដល់ ហើយខាងក្រោយនោះគឺជាទាហានសេះ ។ នាងមានការភ្ញាក់អារម្មណ៍យ៉ាងខ្លាំង ។ ពួកទាំងនោះនៅរង់ចាំឯមាត់របងឯប្តីនាងក៏ឡើងមកលើផ្ទះដោយទឹកមុខមិនធម្មតា ។ នាងភ័យណាស់ នាងលុតជង្គង់សួរប្តី:

_អ្នកបង, មានការអីនៅសាលាស្រុកឬ ? ហើយពួកទាហាននេះមកផ្ទះយើងមានការណ៍អ្វី ?

ហើយនាងសម្លឹងមុខប្តីយ៉ាងចំ រង់ចាំស្តាប់ចម្លើយដោយថប់បារម្ភ។ ពញាថីលើកត្រកងចង្កេះភរិយាឱ្យងើបឡើងហើយឆ្លើយ:

_ហ៊ឺ អូនសម្លាញ់មាសបង, បងព្រួយចិត្តណាស់ មិនដឹងជានឹងគិតវេទៅយ៉ាងម៉េចទេ ! ពេលនេះប្រហែលជាយើងមានទុក្ខហើយ បងពិបាកចិត្ត ណាស់អូន !

នាងទាវត្រជាក់ខ្លួនស្រីតតែម្តង :

_រឿងអីបង បងប្រាប់អូនភ្លាមមក !

_ហ៊ឺអូន, ព្រះករុណាជាអម្ចាស់ជីវិត លោកផ្ញើសារបញ្ជាឱ្យបង ទៅធ្វើការនៅវាំងហើយឱ្យអូនធ្វើជាអ្នកបំរើខាងស្រីស្នំ!

_ទេ, អូនមិនទៅទេ! បងគិតយ៉ាងណា?

_ហ៊ឺ, ឥឡូវលោកឱ្យពួកទាហានមកនាំយើងស្រេចទៅហើយ!

នាងទាវប្រាប់ឱ្យស្វាមីយ៉ាងណែន:

_ហ៊ឺ អ្នកបង, ខ្ញុំមិនទុកចិត្តព្រះករុណាទេ, ខ្ញុំខ្លាចលោកណាស់!

_បងក៏ព្រួយណាស់ដែរ, ប៉ុន្តែលោកមហាមន្ត្រីដែលនាំសារមក នេះបានអះអាងថា ព្រះករុណាលោករមែងមានមេត្តាករុណាធម៌ក្នុងព្រះ អង្គយ៉ាងបរិបូណ៌, លោកពុំមែនកាន់ព្រះទ័យផ្តេសផ្តាសធ្វើបាបយើងទេ!

_បើអ៊ីចឹង, យើងសម្រេចទៅនៅវាំងហើយឬ?

_ហ៊ឺ, អូនអើយ, បើយើងជំទាស់នោះ យើងមុខជាស្លាប់, ដូច្នេះ យើងត្រូវតែប្រថុយផ្សងតាមកម្មព្រេងទៅចុះ! គេចទៅណាក៏មិនរួចដែរ!

កំពុងសាសងគ្នានេះ សម្លេងអ្នកជិះសេះម្នាក់ដែលចាស់ជាងគេ និយាយមកពីក្រៅរបងថា:

_អើពញ្ញាអ្នា! មើលរៀបចំទៅ ខ្ញុំទៅចាំឯសាលាស្រុកមុនខ្ញុំ ទៅបាយទឹកឯណោះហើយ!

_បាទ ព្រះតេជគុណ

ពញ្ញាជីតបរិញ្ញ រួចមើលទៅឃើញពួកលោកមហាមន្ត្រីត្រឡប់ទៅវិញ ។

ទាំងពីរនាក់ភរិយាស្វាមី ដែលធ្លាប់តែសប្បាយរីករាយពេលនេះចាប់ផ្តើមមានសេចក្តីទុក្ខហើយ ។ គេរៀបអាស្រ័យបាយដោយទឹកមុខក្រំក្រៀម ។

បន្ទាប់មកអ្នកទាំងពីរ ក៏ប្រញាប់រៀបរទេះគោ លាមាតាបិតានិង ញាតិជិតខាង ចេញដំណើរទៅសាលាស្រុក ។ ឯលោកមហាមន្ត្រីនៅរង់ចាំឯសាលាស្រុកនោះ បាយទឹកនៅជាមួយចៅហ្វាយស្រុក ។ លុះឃើញពញ្ញាជីមកដល់ មានអំណរណាស់ ប្រញាប់លាចៅហ្វាយស្រុកនាំសេនាអាមាត្យចុះដី និយាយទៅកាន់ពញ្ញជី និងនាងទាវថា :

- ទៅយើងធ្វើដំណើរទៅ!

ពួកទាហានទាំងអស់ ក៏ធ្វើដំណើរហែហមរទេះគោរបស់អ្នកទាំងពីរឥតឱ្យឃ្លាត ។

ទាំងអស់គ្នាបានទៅដល់ព្រះបរមរាជវាំង នៅពេលរសៀល។

លោកអគ្គមហាសេនាកោធា, ចេញទៅជួបពញ្ញាជី និងនាងទាវ។ នាំបុរសស្ត្រី ប្តីប្រពន្ធ នេះចូលទៅថ្វាយបង្គំព្រះពញ្ញាអន ។

ព្រះពញ្ញាអនស្តេចល្មោភកាមគុណ គ្រាន់តែបានទតឃើញលំអ

នាងទាវភ្លាម ស្ដេចស្មើរតែនឹងស្ទុត ប៉ុន្ដែទ្រង់ខំអត់សង្កត់ចិត្តទៅសិន។

ពេលដែលអ្នកទាំងពីរកំពុងឱនមុខក្រាបបង្គំនេះ ទ្រង់ក៏ធ្វើជាមានបន្ទូលថា:

- អើពញ្ញា និង នាង, បានហើយ សមរម្យហើយ, អើពញ្ញា និង នាង, តាំងពីខ្ញុំបានឃើញលក្ខណៈសមរម្យរបស់អ្នក និង នាងមក ខ្ញុំមានចិត្តអាណិតណាស់ ខ្ញុំឃើញថាអ្នកមិនសមនឹងរស់នៅតាមជនបទទេ គួរតែរស់នៅទីក្រុង ក្នុងវាំងឯណោះទើបសម ខ្ញុំអាណិតណាស់ ទើបខ្ញុំប្រើគេឱ្យទៅហៅអ្នកមកនៅនឹងវាំងផង និងឱ្យអ្នកធ្វើការបំរើផ្ទាល់លោកមហាមន្ត្រី ។ ឯនាងជាភរិយាអ្នក មានរូបសម្បត្តិ និង លក្ខណៈសមរម្យខ្ញុំសុំតាំងនាងជាជំនួយការខាងរក្សាស្រីស្នំរបស់ខ្ញុំ ។ ខ្ញុំយល់ថា ការនេះមិនជាធ្ងន់អ្វីសម្រាប់នាងទេ ហើយយល់ថា ពញ្ញាឯងមុខជានឹងយល់ស្របផងដែរ ! អើ, ខ្ញុំសុំប្រាប់ថា គឺជាកិត្តិយសខ្ពង់ខ្ពស់ ពន់ពេកហើយដែលខ្ញុំបានហៅយកមកឱ្យថែរក្សាស្រីស្នំខ្ញុំដូច្នេះ !

-ព្រះករុណាថ្លៃវិសេស !

តបពាក្យនេះ ដោយលើកដៃដែលផ្គុំនោះខ្ពស់ឡើងបន្តិចផង ប៉ុន្តែ ក្នុងចិត្តពញ្ញាថី សែនទើសទាល់អស់យ៉ាង ។

គ្រានោះ ស្ដេចពញ្ញាអន ងាកទៅកាន់ស្នំចាស់:

_នែ ម៉ែវីន មើលយកនាងនេះរកកន្លែងផងទៅ!

ហើយងាកមកកាន់នាងទាវ:

_ទៅនាង, ទៅឱ្យគេរៀបចំឱ្យទៅ, ការងារអ្វីៗ សួរគេអ្នកដើងចាស់ៗ នេះទៅ!

ម៉ែវីន ក៏ងើបនាំនាងទាវចេញទៅ នាងទាវមើលមុខប្ដីទំនងភ័យព្រួយ។ តែព្រះពញាអនអះអាងថា:

កុំខ្លាចក្រែងរអែងអ្វី! កុំភ័យបារម្ភអ្វី, ទៅតាមគេទៅចុះ!

រួចងាកមកកាន់លោកមហាមន្ត្រី:

_លោកមហាមន្ត្រី, នាំពញាទៅប្រាប់កិច្ចការផងចុះ! ទំនុកបំរុងគ្នាទៅ!

ក្រោយដែលពញាចី និងនាងទាវត្រូវគេនាំបំបែកគ្នាទៅនោះ ព្រះពញាអន ងាកមកញញឹមដាក់លោកអគ្គមហាសេនាក្នុងន័យរីករាយ។

គួរឱ្យអាណិតនាងទាវ និង ពញាថីណាស់ ដែលនាំខ្លួនមកស្ថិតនៅក្នុងទ្រុងស្តេចពាលយ៉ាងនេះ។

ក្នុងថ្ងៃទី ១ ទី ២ មុនដំបូង គ្មានហេតុអ្វីដែលនាំឱ្យនាងភ័យព្រួយទេ នាងជួយធ្វើការម៉ែវ៉ាន ក្នុងការតុបតែងសម្លៀកបំពាក់ឱ្យនារីដែលត្រូវយកទៅថ្វាយព្រះរាជា ពេលរាត្រី។

ប៉ុន្តែល្ងាចនេះគួរឱ្យកើតបារម្ភហើយ, នាងទាវត្រូវម៉ែវ៉ានប្រាប់ឱ្យងូតទឹក រួចប្រាប់ទៅស្នំជើងចាស់ពីរបីនាក់ទៀត ឱ្យនាំចូលក្នុងល្វែងសំអាង ។ គ្រានោះគេយកសំលៀកបំពាក់ប្រណីតឱ្យនាងស្លៀកពាក់ ។ រូបកាយរបស់នាងទាវ ដែលមានលំអរស្រាប់ពីកំណើត លុះមកទ្រង់គ្រឿងពស្ត្រាលង្ការដ៏ចើតចាយ ជារបស់រាំជួច្នេះថែមទៀត ក៏ក្លាយទៅជាបវកញ្ញាសួគ៌ាល័យទៅឯង មិនបាច់ប្រឹង។

ពេលនោះ អ្នកតុបតែងកាយឱ្យនាងក៏ជញ្ជក់មាត់ លបសរសើរប្រាប់គ្នាថា:

-យី, នាងនេះល្អឯកណាស់, ព្រះករុណាច្បាស់ជាទ្រង់សន្ទង់សន្ទិននឹងនាងនេះហើយ! ប៉ុន្តែគួរឱ្យអាណិតនាងដែរ ដែលមានប្តី

ហើយ ត្រូវមកធ្វើជាស្នំរបស់ព្រះករុណាដូច្នេះនេះ !

កំពុងខ្សឹបខ្សាវគ្នាដូច្នោះ ហ្លួងពញាអន ក៏យាងចូលមកក្នុងល្វែងសំអាងនេះ រាល់គ្នាក៏ប្រញាប់ឱនកាយថ្វាយបង្គំ ។

នៅកន្លៀតក្បែរទ្វាម្ខាងទៀតនោះ នាងសារិកាលបមើលមកនាងទាវដោយទឹកមុខស្ញប់ ។ លុះឃើញពញាអនចូលមកនោះ នាងសារិកាក៏គេចចេញ ទៅវិញភ្លាម ។

ពញាអនទ្រង់ទតរូបនាងទាវភ្លាម ស្ដេចរិតតែចាបចូលស្នេហាទ្វេឡើង ទ្រង់នឹកថា : យីនាងនេះស្អាតណាស់ ! ស្អាតជាងនាងទាំងអស់ដែលអញធ្លាប់ឃើញ ទ្រង់បន់ឱ្យតែយប់ចាប់នឹងអាលបានរួមរសតណ្ហាជាមួយនាង ។

ទ្រង់និយាយប្រាប់ទៅពួកស្នំតុបតែងនោះថា :

-អើ មើលជួយរៀបចំខ្លួននាងឱ្យស្រួលបួលផង គ្នាទើបតែមកនៅថ្មី !

- ពរម្ចាស់ , ស្រីស្នំបានប្រណម្យទូលតបស្ទើរតែស្របសម្លេងគ្នា។ ព្រះពញាអនថយទៅវិញ ។ នាងទាវមានការថប់បារម្ភណាស់ឆ្ងល់ថាស្ដេចយកនាងមកឱ្យថែរក្សាស្រី។ ឥឡូវម្ដេចក៏ស្ដេចឱ្យយកនាងមកតុបតែងកាយដូច្នេះទៅវិញ ? អត់ពុំបានទេ នាងសួរទៅស្រីស្នំម្នាក់

-អ្នកបង, ព្រះករុណាស្ដេចថាយកខ្ញុំមកឱ្យថែរក្សាស្រីស្នំ, ឥឡូវម្ដេចក៏ស្ដេចឱ្យអ្នកបងតុបតែងខ្លួនខ្ញុំទៅវិញ? អ្នកបងអាណិតប្រាប់ខ្ញុំតាមត្រង់ផង!

ប៉ុន្តែតើនាងស្នំនោះមិនហ៊ាននិយាយត្រង់ប្រាប់នាងឬ ? ប្រាប់ទៅទាល់តែកំបុតក្បាលទៅឬ? តាមចិត្តានាងចង់តែប្រាប់ទៅដែរ ប៉ុន្តែមកពីខ្លាចស្លាប់ទើបតបដោយខ្ចីថា:

-ចាសនាង, ខ្ញុំក៏មិនដឹងដែរ ស្ដេចឱ្យធ្វើដូចម្ដេច ខ្ញុំក៏ធ្វើដូច្នោះ!

ចម្លើយនេះ ក៏អាចប្រាប់ស្រីទាវឱ្យបានដឹងមុន នូវអាថ៌កំបាំងរបស់ព្រះពញាអនដែរ ។ នាងទាវមានការថប់បារម្ភខ្លាំងឡើង ។

ពេលនោះ ព្រលប់យប់មកដល់ហើយ ។ គ្រប់ល្វែងដំណាក់ទាំងអស់ បំភ្លឺដោយប្រទីបជ្វាលាលព្រោងព្រាត ។ ឯភ្លេងមហោរីក៏ប្រគំរងំពិរោះគួរឱ្យសប្បាយក្នុងចិត្ត ប៉ុន្តែ ពន្លឺប្រទីបជ្វាលា និង សំណូរតន្ត្រីពុំបានធ្វើឱ្យនាងទាវបានធូរចិត្តទេ ផ្ទុយទៅវិញ រិតតែធ្វើឱ្យនាងញាប់ញ័រថប់បារម្ភខ្លាំងឡើង ។ ហើយប្ដីនាងមិនដឹងជានៅឯណាផង នាងមិនដឹងជាពិគ្រោះនឹងនរណាផង ខ្លួននាងបីដូចជាបក្សីដែលគេយកមកក្រុងទុកមិនដឹងជានឹងទុកដើម្បីអ្វីនាំឱ្យភ័យព្រួយរន្ធត់គ្រប់ដង្ហើម ។

កំពុងតែញាប់ញ័រប្រេបល់នេះ ម៉ែវិនដើរចូលមកក្នុងល្វែងនេះ

ហៅនាង:

-នែនាង, ព្រះករុណាជាអម្ចាស់ទ្រង់សព្វព្រះទ័យ ឱ្យនាងចូលគាល់ សូមនាងអញ្ជើញតាមខ្ញុំមក!

ស្រីទាវភ័យព្រឺតថែមទៀត តែពុំអាចប្រកែកកើតទេ នាងត្រូវតែដើរទៅតាមគេចូលទៅកន្លែងព្រះរាជា។

នៅក្នុងក្រឡាព្រះបន្ទំនៃព្រះពញាអន បំភ្លឺដោយប្រទីបតូចៗពីរដែលមិនជាភ្លឺប៉ុន្មាន ។ សភាពនេះនាំឱ្យយើងយល់រំពេចថា ព្រះរាជានេះស្ដេចត្រូវការផ្ចិតផ្ចង់តែពីក្បាលល្ងាចទៅតែម្ដង ជាមួយនឹងស្រីស្នំស្រីង្គារទាំងឡាយ។

ឱ, មានពេលឯណានឹងគិតគូររឿងស្រុកទេស?

គ្រាដែលទ្រង់ទតឃើញស្រីទាវចូលមកដល់ ព្រះពញាអនក៏រួសរាយថា:

-អ៊ឺ, នាងចូលមកណេះមកជិតខ្ញុំមក!

នាងទាវហាក់ដូចជាដឹងខ្លួនជាមុនស្រេចថា ស្ដេចនេះប្រាកដជានឹងប្រព្រឹត្តអំពើមិនគប្បីចំពោះនាងមិនខាន។

នាងរារែកចង់ថយទៅវិញ ប៉ុន្តែព្រះពញាអនថា:

-មកនាង, ចូលមក, កុំខ្លាចអី, បន្តិចទៀតមានស្រីស្នំឯទៀតគេ

ចូលមកដល់ដែរហើយ, ចូលមកប្រាប់ដើងឱ្យខ្ញុំបន្តិច!

នាងស្រីអល់ឯកងាកមកមើលមុខម៉ែវីន ដែលនាំនាងមកដូចជាចង់ពិគ្រោះការ ពេលនេះនាងគ្មាននរណានឹងពិគ្រោះក្រៅពីម៉ែវីនទេ។ ម៉ែវីនមើលមុខនាងបន្តិច រួចមើលទៅព្រះភក្ត្រព្រះរាជា ស្តេចនេះសម្លក់ម៉ែវីន ក្នុងន័យថា: ម៉េចក៏មិនប្រាននាងឱ្យចូលមក? ចាំដល់ណាទៀត?

ទើបម៉ែវីនរុញខ្នងនាងទាវដោយនិយាយតិចៗ:

-ទៅ, ចូលទៅ! កុំទទឹងនឹងព្រះរាជបញ្ជា, មិនអីទេ!

នាងទាវក៏ចូលខ្លួនទៅជិតព្រះទែន (គ្រែ) ទាំងញាប់ញ័រ នាងលុតជង្គង់ចុះក្បែរនោះ ។ ព្រះពញាអនញញឹមពេញចិត្ត ក៏ប្រះព្រះកាយទំរេតសន្ទឹងព្រះបាទ ទាំងទ្វេ រួចហៅនាងថា:

-នែ នាងឡើងមកលើព្រះទែននេះមក, ហើយប្រាប់ដើងឱ្យខ្ញុំមក ទំរាំនឹងស្រីស្នំឯទៀតគេមកដល់!

នាងក៏ប្រតិបត្តិតាម ប៉ុន្តែចិត្តនាងកន្ទះរាយ៉ាងខ្លាំង។ ពេលនោះស្រីស្នំដែលនាំនាងមក ចេញទៅវិញបាត់ហើយ នាងនៅតែជាមួយស្តេចនេះពីរនាក់គត់ ។ ព្រះពញាអនទតភក្ត្រានាងដោយពេញចិត្ត ទ្រង់ក៏តាំងចាប់ផ្តោះផ្គងពាក្យស្នេហាជាដំបូងថា:

-នែ នាងបានពញានោះយូរហើយឬ? នាងសប្បាយចិត្តនឹងប្តី

នាងនោះដែរឬ?

នាងស្រីលើកដៃប្រណម្យ:

_ពរម្ចាស់, ខ្ញុំម្ចាស់សប្បាយចិត្តពេញចិត្តនឹងប្ដីខ្ញុំម្ចាស់ដូចជាស្រីឯទៀតដែលស្រឡាញ់ប្ដីគេដែរ, ប្ដីខ្ញុំម្ចាស់ល្អណាស់, ស្មោះត្រង់ណាស់ហើយស្រឡាញ់ខ្ញុំម្ចាស់ណាស់...

ព្រះពញាអនទ្រង់សើចតិចៗ:

_ហ៊ឺះ ៗ ...នាងចេះនិយាយពិរោះណាស់ ហើយលក្ខណៈរាងរៅរបស់នាងមិនសមនឹងបានប្ដីថ្នាក់ទាប ឋានៈជាពញានៅធ្វើការឯចុងកាត់មាត់ញកដូច្នេះទេ, សមតែនឹងបានជាប្ដីអ្នកធំ អ្នកកំពូល ជាព្រះអង្គម្ចាស់ ឬក៏ស្ដេចផែនដី ដូចយ៉ាងខ្លួនខ្ញុំតែម្ដងទើបសម នេះខ្ញុំនិយាយដោយត្រង់..... អើ តើនាងដឹងការពិតទេ ខ្ញុំឱ្យគេយកនាងមកទីនេះធ្វើអ្វី?

ពាក្យជន្លជន្លេញរបស់ស្ដេចនេះ នាំឱ្យនាងភ្លឺភ្នែកយល់គោលបំណងស្ដេចនេះជាក់ដូចថ្ងៃ ។ នាងចង់តែគេចចេញពីទីនេះឥឡូវ ប៉ុន្តែនាងគ្មានត្រូវធ្វើដូច្នោះទៅកើតទេ ត្រូវតែនិយាយសាសងនឹងស្ដេចនេះសិន:

_ពរម្ចាស់ ចំពោះការដែលព្រះករុណាទ្រង់បញ្ជាឱ្យលោកមន្ត្រីទៅនាំខ្ញុំម្ចាស់មកនោះ ព្រះករុណាទ្រង់សព្វព្រះហឫទ័យឱ្យខ្ញុំមកថែរក្សា

ស្រីស្នំព្រះករុណាមានបន្ទូលប្រាប់ខ្ញុំម្ចាស់ដូច្នេះឯង!

ព្រះពញាអនញ្ញញឹមមានបន្ទូលទៀត:

-មិនពិតទេនាង ខ្ញុំកុហកនាងលេងទេ ខ្ញុំពុំមែនយកនាងឱ្យមកថែរក្សាស្រីៗទាំងនោះទេ ខ្ញុំពុំមែនខ្វះស្រី ស្នំដើម្បីថែរក្សាស្រីទាំងនោះទេ តាមដោយពិត ខ្ញុំឱ្យគេនាំនាងមកគឺមានបំណងផ្សេង ហើយជាកំពូលបំណងរបស់ខ្ញុំ....

បន្ទាប់ពីបន្ទូលនេះ ស្តេចនេះក៏ងើបពីទំរេត សម្លឹងមុខស្រីទាវយ៉ាងចំ ហើយថ្នមវាចាថា:

-ខ្ញុំឱ្យគេនាំនាងមក ព្រោះខ្ញុំស្រឡាញ់នាង.... ខ្ញុំចង់លើកនាងជាអគ្គមហេសី! នាងមានវាសនាខ្ពស់ណាស់!

នាងស្រីស្តាប់ពាក្យនេះ ក៏ត្រជាក់ខ្លួនស្រិត ខំលើកហត្ថទាំងញ័រប្រណម្យទូល:

-ពរម្ចាស់ ឱ្យខ្ញុំម្ចាស់សូមទោសទៅ ខ្ញុំម្ចាស់មានប្តីរួចហើយ! ដូចព្រះករុណាទ្រង់ជ្រាបហើយ!

...រួចនាងរំអិលចុះពីលើគ្រែព្រះទែន ប៉ុន្តែព្រះពញាអនរហ័សចាប់ដៃនាងជាប់:

-ខ្ញុំស្រឡាញ់នាង ខ្ញុំត្រូវតែបាននាងជាអគ្គមហេសី នាងត្រូវតែ

ព្រមព្រៀង...

- ទេ ទេ លែងខ្ញុំម្ចាស់ទៅ! ខ្ញុំម្ចាស់មានប្តីហើយ អាណិតខ្ញុំម្ចាស់! ខ្ញុំម្ចាស់មិនព្រមទេ!

នាងស្រីបំរះ ប៉ុន្តែព្រះពញាអនរិតតែបន្តឹងហត្ថយ៉ាងណែន រួបប្រវាឱបថើបនាង គ្រញីចគ្រញីល នាងស្រីភ័យច្របល់ពេញបន្ទុក... នាងប្តេជ្ញាចិត្តការពាររូបកាយនាង នាងពុំព្រមឱ្យស្តេចនេះកន្លងលើរូបឡើយ ក៏ខំទធាក់ប្រដោលយ៉ាងពេញកម្លាំងព្រមទាំងស្រែកផង:

- លែង! លែងខ្ញុំម្ចាស់! លែងខ្ញុំម្ចាស់ទៅ! បងអើយជួយខ្ញុំផង! (នាងស្រែកហៅប្តី)

ពញាអនរិតតែស្រើបស្រាលខ្លាំងឡើង ដោយបានប៉ះពាល់ប្រាណនាង ក៏ប្រឱបនាងញូក់ញី ច្រានទាងផ្តួលទៅ អាការដួលដេករបស់នាងធ្វើឱ្យទ្រង់សប្បាយឥតឧបមា ទ្រង់ប្រវាទ្រោបទៅលើនាងដោយអន្ទះអន្ទែង ប៉ុន្តែ ខុសស្នៀតបន្តិច នាងស្រីគេចភ្លែត រួបងើបភ្លាមស្ទុះគេចទៅ ព្រះពញាអនប្រវាចាប់បានតែផាហ៊ុម នាងស្រីលាស់ផាហ៊ុមចោល នាងរត់ចេញក្រៅបានដូចបំណង, នៅខាងក្រៅឯណោះពួកស្រីស្នំពីរបីនាក់ នឹងម៉ែវនទឹកមុខឡឹងឡង់ ហើយជាមួយពួកស្នំនេះពញាជី ប្តីនាងក៏ឈរដូចជារង់ចាំនាងដូច្នេះ នាងស្ទុះទៅអោបប្តីយំអួល

អាក់ :

-បង, យើងទៅវិញ, ហ្លួងធ្វើបាបយើងហើយ លោកប្រុងរំលោភខ្ញុំហើយ ! បង.....យើងនៅទីនេះពុំបានទេ !

ព្រះពញាអនចេញមកតាមក្រោយ ដោយសើងមមើង មើលទៅគូស្វាមីភរិយានេះ ។ ហើយភ្លាមនោះ លោកអគ្គមហាសេនាក៏ទើបមកដល់ដែរ ។

ព្រះពញាអនមានបន្ទូលទៅកាន់លោកថា :

-ផ្កាស លោកមហាសេនា ម្តេចក៏លោកបណ្តោយឱ្យប្តីវាចូលមកទីនេះបាន ? ទៅ, នាំវាចេញទៅ !

ហើយមានបន្ទូលទៅកាន់ស្នំទាំងប៉ុន្មាននាក់នោះ :

-នែ នាំនាងនេះទៅទុកមួយកន្លែងសិនទៅ , ជួយនិយាយបញ្ចុះបញ្ចូល ពន្យល់នាងនេះឱ្យស្រួលផងទៅ ! អើហើយហៅនាងផ្សេងមកឱ្យអញ !

ពញាថី និង នាងទាវខំប្រឹងប្រឹងគ្នាយ៉ាងណែនលើសដើម ពញាថីស្រែកទូលទៅព្រះពញាអនថា :

-ព្រះអង្គ, អាណិតដោះលែងទូលបង្គំ និង ភរិយាឱ្យទៅស្រុកវិញទៅ !

ប៉ុន្តែព្រះពញ្ញាអនគំហកទៅលោកអគ្គមហាសេនា:

_ម៉េចលោក, ម៉េចក៏មិនបំបែកនាំចេញឱ្យរហ័សភ្លាមទៅ ! ចាំដល់កាលណាទៀត ?

_លោកមហាសេនា ស្ទុះកន្ទ្រាក់ពញ្ញាថីដួលទាំងជំហររបូតដៃពីនាងទាវ នាងទាវស្ទុះតាម តែត្រូវពួកស្រីស្នំចាប់ជាប់ ប្រអូសប្រទាញនាងចូលទៅក្នុងល្វែងមួយ គ្រានោះលាន់ឡើងយ៉ាងខ្លោចផ្សា : អូន !បង! ខ្ទរពេលរាត្រី ។

ពញ្ញាថី ត្រូវលោកអគ្គមហាសេនាកញ្ឆក់កញ្ឆែងចេញទៅរកកន្លែងមួយ ។ លោកនេះក្រេវក្រោធណាស់ចំពោះពញ្ញាថីដែលហ៊ានចូលទៅដល់ដំណាក់ព្រះរាជា នាំឱ្យព្រះរាជាមិនសប្បាយព្រះទ័យ ហើយមានសេចក្ដីបន្ទោសចំពោះរូបលោកអម្បាញ់មិញផង ។ លោកក្ដៅណាស់ ក៏ទះតប់នាយថីដួលត្រឡប់ត្រឡិននិយាយថា :

_អាថ្គាស, នរណាអនុញ្ញាតឱ្យអាឯងចូលទៅរកដំណាក់ព្រះរាជា? អាឯងអីក៏ហ៊ានម្ល៉េះ ?

_សូមទោសចុះព្រះតេជគុណ, ខ្ញុំបាទឮសម្លេងភរិយាខ្ញុំបាទហៅខ្ញុំបាទ ទើបខ្ញុំបាទហ៊ានចូលទៅ... ឱព្រះតេជគុណសូមព្រះតេជគុណមេត្តាកុំធ្វើបាបខ្ញុំបាទ និងភរិយាខ្ញុំបាទអី សូមមេត្តាដោះលែងខ្ញុំបាទ និង

ភរិយាខ្ញុំបាទឱ្យបានទៅស្រុកភូមិវិញទៅទានព្រោស!

-ហ៊ឺះ អាគម្រក់ ស្ដេចយកប្រពន្ធមកតាំកុំតាំកើង ហើយបែរជាចង់ទៅណាឯណោះវិញ... ហើយឱ្យអញដោះលែង? ដោះលែងមិនបានទេ ស្ដេចពុំទាន់បានក្រសាលប្រពន្ធអាឯងផង ស្ដេចពុំទាន់ឱ្យអញដោះលែងផង ឱ្យអញដោះលែងម្ដេចនឹងបាន ? អើអាឯងឃើញស្រាប់ហើយ ថាស្ដេចសព្វព្រះទ័យចំពោះភរិយាអាឯងណាស់ អម្បាញ់មិញ លោកឱ្យគេយកនាងទៅអប់រំឱ្យដឹងខុសត្រូវ ឈប់ទទឹងនឹងព្រះអង្គ ... អាឯងឃើញទេ ?

ពញាចិនីកឈឺចាប់ក្នុងចិត្តអស្ចារ្យចំពោះសំដីនេះ ប៉ុន្តែ គេត្រូវប្រថុយអង្វរករបន្តិចទៀតចុះ :

-ព្រះតេជព្រះគុណអើយ ! សូមព្រះតេជព្រះគុណជួយអង្វរព្រះទ័យព្រះករុណាផង ខ្វះអីស្រីគគោក ពុំគួរលោកមកសព្វព្រះទ័យលើភរិយាខ្ញុំបាទទេ សូមព្រះតេជគុណជួយអង្វរផង!

-ហ៊ឺះ អាចំកួត, អញជាអ្នកចាត់ការឱ្យទៅនាំមកដើម្បីថ្វាយព្រះករុណា ! អញត្រូវការយកគាប់គួរនឹងព្រះអង្គ ម៉េចក៏អាឯងបែរជាឱ្យអញទៅសុំពីព្រះអង្គយកមកឱ្យអាឯងវិញ? អាចំកួត, អញមិនមែនជាអ្នកទទួលអង្វរអាឯងទេ កុំប្រទ្បំ!

សំដីឃ្លាក្រោយនេះដុតរោលដើមទ្រូងពញ្ញាថី ឱ្យក្ដៅប្រឡោត ឡើង:

_ហ៊ឺះ លោកអគ្គមហាសេនា លោកចិត្តអាក្រក់ណាស់, ទៅកុហកបោកប្រាស់គេមក ដើម្បីយកគាប់គួរនឹងស្ដេច ! ហ៊ឺះ ចិត្តលោកមិនសមជាមនុស្សទេ !

_ ហ៊ឺះ អាគម្រក់ហ៊ានថាឱ្យអញផង ?

ភឹប ! ភឹប ! ស្លាប់ទៅអាឯង !

លោកអគ្គមហាសេនាក្រេវក្រោធយ៉ាងខ្លាំង ក៏ធាក់ពញ្ញាថីដួលទាំងជំហរ រួចហៅទៅទាហានឯទៀត :

_នែ, ចាប់អាព្រហើននេះចងទៅ ! យកទៅឃុំទុកមួយកន្លែងទៅ !

ភ្លាមនោះមនុស្សប្រមាណជា ៥ នាក់ស្ទុះស្រមកចោមចាប់ពញ្ញាថីប្ដីនាងទាវចងស្លាបសេកជាប់មួយរំពេច ។

ពញ្ញាថីអស់សង្ឃឹមត្រឹមណោះ ។ គេនឹកតូចចិត្តយ៉ាងអស្ចារ្យដែលមិនគួរជានឹងមកធ្លាក់ក្នុងក្រញាំពួកព្រៃតិរច្ឆានដូច្នេះសោះ ។ ម្យ៉ាងទៀត គេនឹកព្រួយភ័យយ៉ាងខ្លាំងចំពោះភរិយាគេ ។ ដឹងជាស្ដេចចង្រៃអប្បលក្ខណ៍នោះ រំលោភធ្វើបាបនាងយ៉ាងណាទេ....

ស្របគ្នានឹងអារម្មណ៍នេះ នាងទាវដែលត្រូវគេនាំទៅកាន់ល្វែង

ស្អីវិញនោះ នាងក៏សែនអន្ទះអន្ទែងណាស់ដែរ ដោយពុំដឹងថាប្ដីនាងគេធ្វើបាបយ៉ាងណា... នាងមានទឹកភ្នែកដោបហូរដាបមុខ គួរឱ្យអាសូរណាស់។

# ៨

ពញ្ញាថីត្រូវជាប់នៅក្នុងទីឃុំឃាំង ។ គេពុំអាចមើលឃើញទីកន្លែងដែលឃុំឃាំងនេះយ៉ាងដូចម្ដេចទេ ពីព្រោះយប់ងងឹត ។ ប៉ុន្តែលុះព្រឹកឡើង ទើបយល់ថា កន្លែងនេះមានចម្រឹងដែកមាំ ៗ ព័ទ្ធជុំវិញ ហើយមានទ្វារចាក់សោ មានអ្នកយាមពីរនាក់ កាន់លំពែងរងាស ។

តាំងពីព្រឹកដល់ថ្ងៃត្រង់ អ្នកយាមផ្លាស់វេនគ្នា ។ តាំងពីព្រឹកថ្ងៃត្រង់ដល់រសៀល គ្មាននរណាមកជិតសោះឡើយ ។ ពញ្ញាថីនឹកថាមើលទៅពួកគ្នាតអស់នេះពុំយកអ្នកទៅណាទៀតទេ ប្រហែលជាវាឃុំឃាំងបង្អត់បាយទឹកឱ្យស្លាប់នៅនឹងកន្លែងនេះហើយ ។ អ្នកមើលតាមចម្រឹងទៅក្រៅ ឃើញកំពូលប្រួងប្រាងនៃដំណាក់លាបពណ៌មាសក្រហមឆ្អៅចាំងតទៅនឹងពន្លឺថ្ងៃរសៀល ឃើញដូចជាដុំដែកដែលក្ដៅ ជះចំហាយមកលើទ្រូងអ្នកដូច្នោះដែរ អ្នកគេចមុខបិទភ្នែកទៅវិញ មិនចង់ឃើញទិដ្ឋភាពដែលនាំឱ្យក្ដៅក្រហាយចិត្តយ៉ាងនេះទេ ។

ពេលព្រលប់យប់មកដល់ ។ ផ្សែងងងឹតលូនចូលមកក្រាលគ្របលើទីឃុំឃាំង ។ ពញ្ញាថីហាក់ដូចជាមានអ្វីមកក្ដោប ក្រសោបរឹតរួចប្រមាត់ថ្លើមគេឱ្យរឹតតែរួញតឹងណែនទ្វេឡើយ ។ ក្រឡេកទៅក្រៅ ឃើញគេអុជ

ភ្លើងបំភ្លឺដំណាក់ ហើយលេងភ្លេងនៅដំណាក់មួយ ។ គេខាំមាត់ សង្កៀត ធ្មេញក្រឹត ! និយាយឈឺចាប់ម្នាក់ឯងថា : " វាំងស្អីព្រៃផ្សៃ....ហ៊ឺ ប្រពន្ធអញធ្លាក់ទៅក្នុងកណ្ដាប់ដៃស្ដេចបីសាចនេះហើយ"

កំពុងចេះចួលទោមនស្សនោះ ស្រាប់តែអ្នកយាមពីរនាក់កាន់ចន្លុះដើរចូលមកចាក់សោរ រួចម្នាក់ចូលមកអូសអ្នកចេញទៅក្រៅដួលប្រចាប់ប្រចឹល :

- លោកអគ្គមហាសេនា ឱ្យនាំអ្នកឯងទៅជួប !

ពញ្ញាចីឈឺចាប់ពន់ប្រមាណ ខំដើរតាមគេទៅដល់លំនៅមួយ។ លោកអគ្គមហាសេនាឈរក្រអឺត អមដោយមនុស្សមាឌមាំ ៣-៤ នាក់ ក៏និយាយដោយសម្លេងកាចមកកាន់ពញ្ញាចីថា :

- អាពញ្ញា, អាឯងឈប់ហ៊ានព្រហើនដាក់អញទៀតហើយឬ?

ពញ្ញាចីខំសង្កត់កំហឹង និយាយសួរពីរឿងប្រពន្ធសិនថា :

-ហ៊ុះ ទានប្រោស, លោកយកប្រពន្ធខ្ញុំទៅណាហើយ ? ហ្លួងធ្វើបាប ប្រពន្ធខ្ញុំយ៉ាងណាហើយ ?

-ហ៊ុះ អានេះនៅតែមិនយល់ទៀត ឈប់គិតពីរឿងប្រពន្ធអាឯងទៅ ! ព្រះករុណាកុំពុងឱ្យស្នំចាស់ៗអប់រំនាងឱ្យស្មគ្រនឹងលោក ! ប្រពន្ធអាឯងត្រូវនៅក្នុងវាំងរហូត ឯអាឯងបើនៅទទឹងរឹងរូសចង់ទាមទារ

ប្រពន្ធវិញនោះ អញនឹងឱ្យគេដេញចេញពីទីនេះភ្លាម ! ស្តាប់បានទេ ?

ពញាចីនឹកអស់សង្ឃឹមត្រឹមណោះ គេក៏ចេះភ្លើងកំហឹងឡើង :

_ហ៊ឺ លោក, ចិត្តលោកអាក្រក់ពេកណាស់, ទាំងហ្លួងរបស់លោកក៏ដូច្នោះដែរ យកប្រពន្ធកូនគេមកត្រេកត្រអាល !..

_យីះ ! ផាំង ! ផាំង ! លោកអគ្គមហាសេនាទះកំភ្លៀងអ្នកទោសនេះដួលស្រឡើតតើតទៅ រួចទាញសក់ក្បាលឱ្យងើបឈរឡើងវិញ និយាយថា :

_យីះ អាឯងនៅតែព្រហើនទៀតឬ ? ហើយហ៊ានប្រមាថព្រះចេស្តាផងឬ ? អាឯងចង់ស្លាប់ឬ ?

ពញាចីដល់ចិត្តហើយ គេអស់ស្តាយជីវិតហើយ :

_ហ៊ឺះ ពួកប្រេត ! ពួកតិរច្ឆាន ! ជែត !

អ្នកទោសនេះ ព្រោះទឹកមាត់ដាក់មុខលោកកោជា

លោកនេះភ្ញាក់ព្រើយកដៃជូតភ្នែកជូតមុខ រួចក៏ទះកំភ្លៀងពញាចីដួលទៅទៀត ព្រមទាំងបញ្ជា :

_ អាដែង , យកអានេះទៅចងសណ្តូនថ្មទម្លាក់ទឹកទន្លេទៅ !

ភ្លាមនោះ សេនាមាត្យ ៤_៥ នាក់លេចផ្លោមកចាប់ពញាចីឱ្យងើបឡើង ពញាចីស្រែកយ៉ាងក្តៅក្រហាយ :

-លែងអញសិនអាពួកចង្រៃ អាបិសាច! ទុកឱ្យអញនិយាយនឹងអាមេ កោយឯងបន្តិចសិន!

-ហ៊ឺះ អានេះព្រឺហើនអស្ចារ្យណាស់ ! ដាក់ថ្នាំខ្លាំងឱ្យដល់ការទៅ!

បន្ទាប់ពីពាក្យបញ្ជានេះ ទាហានដែលកំពុងប្រទាញពញាថីនោះ ក៏តាំងព្រួតគ្នាវាយតប់ទាត់ធាក់បុរសនោះព្រមគ្នា ។

ពញាថីពេលនោះបីដូចជាដុំសាច់ ដែលត្រូវចែ្កត្របាក់ដណ្តើងគ្នាដូច្នោះ ។

-អាឯងរាល់គ្នា... សម្លាប់អញទៅចុះ ! អញមិនរស់នៅឃើញអំពើព្រៃផ្សៃរបស់អាឯងតទៅទៀតទេ... អួយ!

សម្រែកក្តៀវក្លារបស់ពញាថី លាន់ឡើងបានតែប៉ុណ្ណោះក៏ចប់ទៅ ខ្លួនគេក៏ដួលស្តូកទៅ ឈប់មានដង្ហើមត្រឹមណោះ ។ ទើបលោកអគ្គមហាសេនាឃាត់ ពួកអ្នកដៃដល់ទាំងនោះ :

-ឈប់ទៅ, បានហើយវាស្លាប់ហើយ, ឥឡូវនេះយកខ្មោចវាប្រែកបាវដាក់ថ្មសណ្តូនទម្លាក់ចោលក្នុងទន្លេទៅ ! ហ៊ឺះ អញមិនដែលឃើញអាណាកោងកាចដូចអានេះទេ!

ភ្លាមនោះ យើងឃើញចន្លុះភ្លឺព្រោងព្រាត មនុស្សម្នាពីរនាក់បាន

សែងបាវតែកតោក ហើយមានពីរបីនាក់ទៀតកាន់ចន្ទុះខាងមុខ ពីរបីនាក់ទៀតកាន់ចន្ទុះខាងក្រោយ ។ ទាំងអស់គ្នា ធ្វើដំណើរឆ្ពោះទៅកាន់មាត់ទន្លេ យើងអស់សង្ឃឹមស្រេច ដ្បិតពញ្ញាថីពិតជានឹងត្រូវគេយកទៅទម្លាក់ទឹកចោលហើយ ។ ពញ្ញាថីដែលនៅសន្ធប់ក្នុងបាវ ពិតជានឹងត្រូវស្លាប់ក្នុងទឹក ហើយបាត់ទាំងខ្លួន ប្រាកដ។

ឱ! គួរឱ្យអាសូរនាងទាវណាស់, ប្រសិនបើនាងបានឃើញនូវព្រឹត្តិការណ៍នេះ តើនាងនឹងខ្លោចផ្សាយ៉ាងណាទៅ?

ពួកអន្យតិរ្ថិយ ទាំងនោះធ្វើដំណើរកាត់វាលចំការរហូតដល់មាត់ទន្លេ មាត់ទន្លេសឹងមានដើមត្រែងដុះញឹកស្អេកស្កះ មានតែផ្លូវដើងតូចមួយចុះទៅរកទឹក ។

ពួកទាំងនោះ ដាក់ស្នែងចុះ ពិគ្រោះគ្នា ។ ម្នាក់សួរថា

_យើងគិតយកអានេះទៅឱ្យដល់កណ្តាលទន្លេ សឹមទម្លាក់ចោលឬ?

ម្នាក់ទៀតឆ្លើយវិញថា:

_មិនបាច់ទេ អាសាង, កុំនាំអុំទូកហត់អត់ប្រយោជន៍អីអា, យើងគ្រាន់តែយកវាឱ្យឆ្ងាយពីប្រាំងបន្តិច ហើយលើកវាបោះទៅ, វានឹងក្លាយទៅជាចំណីត្រីហើយ, កុំទៅសាញសូញនាំឃូរការ ! អញប្រញាប់ទៅវាំង

វិញផង!

ម្នាក់ទៀតក៏ស្របថា:

_មែន, អ៊ីចឹងមែន , អាខ្វៃវាថាត្រូវមែន ខ្មោចអានៅក្នុងបាវនេះ វាគ្មានពេលនឹងផុសទេ!

និយាយត្រូវគ្នាដូច្នោះហើយ ក៏តាំងលើកស្នែងឡើងសែងបាវនោះទៀត ហើយនាំគ្នាចុះតាមផ្លូវត្រែងចុះទៅមាត់ទឹក ។ ដល់មាត់ទឹកស្រាប់តែក្រឡេកទៅកណ្ដាលទន្លេ ក៏ឃើញចន្លុះពីរកំពុងទ្រោលមក គឺទូកតូចមួយអុំយ៉ាងលឿនមក ហើយប្រហែលជានឹងចូលមកចំត្រង់កំពង់នេះហើយ ពួកសេនាវាំងឃើញដូច្នេះងឿងឆ្ងល់ មើលមុខគ្នាបន្តិច រួចនាយសាងនិយាយឡើងថា:

_យីអាខ្វៃ, ពួកនោះវាស្អីវើយ ទ⁺ អុំទូកកាត់ទន្លេទាំងអធ្រាត្រដូច្នេះ?

នាយខ្វៃឆ្លើយថា:

_ប្រាកដជាពួកចោរហើយ យីនេះវាគិតអុំឆ្លងមកលួចនៅត្រើយខាងយើងឯណេះហើយ កុំសង្ស័យ!

ម្នាក់អារកាត់ឡើង:

_បើជាចោរ វាមិនហ៊ានចូលមកចំកន្លែងយើងទេ ចាំមើលមុខ

ជាគេចទៅចតឯណាឯណីហើយ!

-អើមែន, យើងចាំមើល!

ទូកនោះក៏ចូលមកដល់ល្មម ។ រាល់គ្នាមើលទៅឃើញអ្នកជិះទូកនោះ ៥ នាក់ ម្នាក់អុំក្បាល ម្នាក់អុំកន្សៃ ពីរនាក់កាន់ចន្លុះ ហើយម្នាក់មាឌមាំទៅអង្គុយចំកណ្ដាលយ៉ាងស្ងៀមស្ងាត់ជាអ្នកធំ ។ ដោយចិត្តអង់អាច នាយសាងមិនបានឱ្យពួកទូកនោះចុះឡើងគោកទាន់ទេ គំហកសួរទៅថា:

- នែ, ពួកអាឯងរាល់គ្នានេះជាស្អី? ធ្វើដំណើរមកពីណាទៅណាទាំងយប់អធ្រាត្រដូច្នេះ? ពួកឯងជាចោរឬ?

ពួកអ្នកជិះទូកមើលមុខគ្នាបន្តិច រួចមើលទៅបុរសមាឌមាំនៅកណ្ដាលនោះ ដូចជារង់ចាំស្ដាប់បញ្ជាបុរសនោះដូច្នោះ ឯបុរសនោះក៏នៅស្ងៀម ប៉ុន្តែ ក្នុងទឹកមុខមាំ ដូចជាមិនពេញចិត្តសោះចំពោះសំណួរព្រហើនកោងនេះរបស់អ្នកនៅគោក, បានបន្តិច បុរសនេះក៏និយាយទៅកាន់អ្នកនៅក្បាលទូកដោយសំដីតិចល្មម:

-សុខឯងចុះទៅប្រាប់ពួកនេះ ឱ្យរៀបចំសំណួរម្ដងទៀតទៅ.... ហើយសួរវាមើល វាជាស្អីដែរ?

ឈ្មោះសុខទទួលបាទ! ដោយគោរព រួចចុះពីទូកដោយទាំង

ប្រវាទៅផង ឡើងទៅរកពួកវាំងទាំងអស់គ្នាដោយមានឫកពាក្រអឺត ។ ឈ្មោះសុខឈរទល់មុខនឹងនាយសាន និយាយមួយៗ លះៗ ថា :

-នែ, ល្បែងឯងល្មមរៀបពាក្យសំដីឱ្យបានសមរម្យជាងនេះបន្តិចទៅ! ពួកយើងមិនដែលឮពាក្យគ្រោតគ្រាតដូច្នេះទេ! ពួកល្បែងឯងជាស្អីទៅ បានជាប្រើពាក្យសុទ្ធតែព្រៃផ្សៃយ៉ាងនេះ ពួកល្បែងឯងគ្មានគ្រូបាអាចារ្យប្រដៅឬ?

ចំពោះសំដីនេះ នាយសាងក៏តាំងសើចលោក់ទាំងខ្លួនហាស ៗ យ៉ាងខ្លរ ងាកមើលមុខគ្នីគ្នាទាំងអស់គ្នានោះ ក៏តាំងសើចឡើងព្រមគ្នាដែរ បង្ហាញនូវការចំអកមួយដ៏ធូន់ចំពោះមុខពួសុខ ។ នាយសាងបង្អង់សំណើចបន្តិច និយាយឡើង :

-ហ៊ុះអាភ្នក់នេះគម្រក់អស្ចារ្យ វាមើលពួកយើងមិនស្គាល់ជាអ្វីរើយ! ហើយវាថាយើងព្រៃផ្សៃផង! យីអានេះចំជាពួកចុងកាត់មាត់ញ៉ុកមែន!

ហើយក៏តាំងនាំគ្នាជំទាលសើច កាច់កកាច់ស្រង់តទៅទៀត ។ កំពុងតែប្រហមាត់ហាសៗក្អាកក្អាយនេះ ស្រាប់តែប្រហោងមាត់ពួកនេះទទួលដុំភក់ល្បប់លាន់ផ្លប់ៗ ស្ទើកប់ដល់កន្ទើតគ្រប់គ្នា ពួកនេះបាត់សំណើចដូចគេចុក ហើយម្នាក់ៗតាំងខ្ទេះដុំភក់ចេញពីមាត់ ខាកស្ដោះ

យ៉ាងញាប់... ទឹកមុខចំអកបែរជាក្រញូវមាំទាំ សម្លឹងទៅពួកអ្នកទូក ដែលកំពុងឡើងមកនោះស្ទើរស៊ីសាច់ ។ ប៉ុន្តែពួកវាំងនេះ គង់បែបស្ទើច ដែរ ដែលពួកអ្នកទឹកនោះគប់ផុកកក់ត្រង់ ។ ដល់ម្ល៉េះ ។ ពួកនេះពិតជាអ្នក លែងដៃថើតដែរហើយ។

ពួកអ្នកទូកឡើងមកទល់មុខនឹងអ្នកវាំង ប្រើទឹកមុខមាំមើលពួក វាំងតាំងពីក្បាលដល់ចុងជើង ឯអ្នកវាំងវិញក៏ដូចគ្នាដែរ ឈរសម្លក់ពួក អ្នកទូកស្ទើរជ្រុះប្រស្រី ។ ឯចន្ទុះក៏ទ្រោលនឹងថ្កល់ទៅវិញទៅមកបំភ្លឺ មុខគ្នា ។ សេនា មាត្យ របស់ពញាអនទាំគ្នាថយមួយជំហានមកក្រោយ ហើយហូតដាវខ្វាក។ សស្វាច ចាំងទៅនឹងពន្លឺចន្ទុះមើលទៅគួរឱ្យព្រឺ ។

នាយសាងដែលបានប្រើពាក្យ ប្រទូសរ៉ាយពីដំបូងដៃនោះ ទទោកអាវុធ ហើយសួរទៅបុរសចាស់មាឌធំ ដែលខ្លួនយល់ថាគឺជាមេ គេនោះថា:

_មើលតាប៉ុឯងនិយាយមកមើល ពួកតាប៉ុឯងជាស្អី ? ធ្វើដំណើរ ពីណាទៅណាទាំងកណ្តាលអាធ្រាត្រដូច្នេះ?

បុរសមាឌធំនោះមិនឆ្លើយទេ ភ្នែកមើលទៅបាវចងមាត់ដែល ដាក់ចោលនោះ គាត់ងាកមកសួរចំពោះមនុស្សនេះដោយសង្ស័យវិញ:

_អើ ចុះពួកឯងជាស្អីដែរ បានជាធ្វើដំណើរទាំងកណ្តាល

អាជ្រាត្រដូចពួកអញដែរនោះ ? ហើយនៅក្នុងបាវចងមាត់នោះមានស្អី ? ស្រាយឱ្យអញមើលផងមើល ?

_យី អាប៉ិនេះព្រហើនណាស់ ឯងសួរទៅបែជាត្រឡប់សួរបកមកឯងវិញ ! ពួកយើងប្រដៅពួកអាមិនដឹងអីនេះឱ្យវាដឹងដៃម្ដងទៅ !

ប្រាវ ! មេអាមាត្រនោះវាត់ដាវមុនគេទៅលើបុរសចាស់ បុរសចាស់គេចផុត នាយសុខក៏រងជួសឡើង ឯអាមាត្រឯទៀតក៏វាត់ខ្វាប់ៗទៅលើអ្នកទូកដែលមានតែច្រវារង ។ ការប្រកាប់គ្នាបានផ្ដើមឡើងលាន់ផូងផាំងៗ យ៉ាងសម្បើម ។ ប៉ុន្តែពុំជាយូរ គ្រាន់តែមួយប្រាវប៉ុណ្ណោះ ពួកសេនាវាំងក៏ត្រូវរបូតអាវុធម្នាក់មួយៗ ហើយទាំគ្នាផាយ ប៉ុន្តែ ត្រូវពួកទូកវាយស្ទងឱ្យដួលមួយកន្លែង ថ្ងូរហ៊ឹះ លើកដៃសំពះគ្រប់គ្នា ឯនាយសាងយល់ថាទប់ទល់មិនឈ្នះឈ្មោះសុខ ក៏ដាំក្បាលប្រុងរត់ដែរ ប៉ុន្តែ នាយសុខស្កាត់មុខជាប់ បុកមួយច្រវាចំត្រង់ពោះទីក ធ្វើឱ្យវាដូរបង្គ្រាង រមួលខ្លួនដោយចុក, នាយសុខជន្លមួយផ្លែទៅទៀត នាយសាងក៏ប្រញាប់លើកដៃសំពះញ័រ :

_ កុំ! កុំ! ខ្ញុំខ្លាចហើយលោក ! កុំថែមទៀត!

បុរសចាស់ដើរមកជិត ឱ្យគ្នាគាត់ទ្រោលចន្លុះមើលមុខពួកអ្នកអន់លោងទាំងប៉ុន្មាននេះដោយអង់អាច ។ គាត់សួរទៅអាម្នាក់ជាមេគេ

នោះថា:

-អើ អីឡូវល្មមថ្លើយហើយ ពួកឯងជាស្អី?

-បាទៗ! ពួកខ្ញុំបាទជាទាហានហ្លួង!

រាល់គ្នាឮដូច្នោះដូចជាភ្ញាក់ខ្លួនបន្តិច ។ បុរសចាស់សួរទៅទៀត:

-ចុះស្អីនៅក្នុងបាវនោះ!

-បាទទាន, មនុស្ស... មនុស្សអ្នកទោស!

-ស្រាយចេញយកមកឱ្យអញមើលមើល៍!

ទាហានហ្លួងទាំងនោះ ក៏តាំងត្រដរម្នីម្នាស្រាយបាវ ។ ខ្លួនមនុស្សម្នាក់បានត្រូវលេចឡើងចំពោះភ្នែកពួកថ្មីទាំងអស់គ្នា ។ នាយសុខលើកបាវនោះរលាស់ទៀត ដុំថ្មពីរបីដុំធ្លាក់ចេញមក ។ ច្បាស់លាស់ណាស់ គេមិនបាច់បញ្ជាក់សួរទៀតទេ គេយល់ថាមនុស្សនេះពិតជាត្រូវពួកវាំងនេះ វាយប្រកបាវសណ្ដូនថ្មប្រុងទម្លាក់ទន្លេនេះប្រាកដ បុរសចាស់ងាកទៅសួរមេអាមាត្យនោះយ៉ាងម៉ឺងម៉ាត់:

-អាឯងនិយាយឱ្យត្រង់មកមើល ? នរណាឱ្យយកមនុស្សនេះមកសណ្ដូនថ្មទម្លាក់ទឹកដូច្នេះ? តើមនុស្សនេះមានកំហុសអី?

-បាទទាន, មនុស្សនេះមានទោស ព្រោះប្រមាថប្រចាំងទទឹងរឹង

រូសចំពោះលោកមហាសេនា ព្រមទាំងព្រះករុណាជាអម្ចាស់ជីវិត ! ដោយកំហុសនោះហើយ បានជាលោកមហាសេនា បញ្ជាឱ្យយកមក សណ្ដូនថ្មទម្លាក់ទឹកនេះឯងទានប្រោស!

-អាឯងមានដឹងរឿងរ៉ាវទេ ដំណើរហេតុអ្វីបានជាមនុស្សនេះ ហ៊ានប្រឆាំងនឹងលោកមហាសេនា ព្រមទាំងព្រះរាជានោះ?

-ខ្ញុំបាទ ពុំបានដឹងច្បាស់លាស់ទេទានប្រោស ប៉ុន្តែតាមដំណើរ រឿង លោកមហាសេនាទៅនាំប្រពន្ធបុរសនេះ យកមកថ្វាយព្រះរាជា បុរសនេះ ឮប្រពន្ធស្រែកក៏ស្ទុះទៅរកប្រពន្ធ ប្រហែលជាបុរសនេះ ជជែកតវ៉ាយ៉ាងនេះ យ៉ាងនោះ ចំពោះព្រះភក្ត្រព្រះរាជាហើយ បានជា ស្ដេចក្រេវក្រោធ ហើយលោកមហាសេនា ក៏នាំបុរសនេះយកមក ឱ្យខ្ញុំបាទនេះឯង! ខ្ញុំបាទគ្មានដឹងរឿងអីទៀតទេទានប្រោស!

-ហ៊ឹះ, ស្ដេច និងលោកមហាសេនារបស់អាឯងអាក្រក់ណាស់! ចាប់ប្រពន្ធកូនគេយកមកលេងសើច ហើយធ្វើបាបប្ដី ម្ដាយឪពុកគេទៀត ឱ្យតែគេហ៊ានជជែកតវ៉ា! អញឮអាវអូមខ្លាំងណាស់ទៅហើយ ថាស្ដេច សព្វថ្ងៃនេះ ឱ្យបម្រើដើរប្រមូលកូនចៅអ្នកស្រុកទូលបាសាណយកមក ត្រេកសប្បាយ! ហើយពួកអាឯងក៏ដែរ សុទ្ធតែពួកដៃដល់ ចិត្តសាហាវ ឃោរឃៅ ជាងសត្វព្រៃទៅទៀត!

នាយអាមាត្យនោះលើកដៃសំពះញ័រ

-ខ្ញុំបាទខ្លាចហើយ រាងហើយលោកម្ចាស់ ខ្ញុំបាទសូមលោកម្ចាស់អភ័យទោសចុះ ខ្ញុំបាទធ្វើតែតាមបង្គាប់បញ្ជាពីគេទេ ទានប្រោស!

បុរសចម្លែកនេះ ឈប់ដេញដោលនាយអាមាត្យត្រឹមណោះ គាត់ប្រញាប់ស្ទាបសារពាង្គកាយអ្នករងគ្រោះមើលបន្តិច គាត់ងក់ក្បាលលាន់មាត់ថា:

-អ៎ មិនអីទេ អ្នកនេះនៅមានជីពចរនៅឡើយ ! ហើយគាត់រាវរកក្នុងថង់បានគុលិកាមួយគ្រាប់ គាត់យកមកទំពា រួចក៏ងើបឈរឡើងព្រួសផែតទៅលើបុរសដែលដេកស្លូកនោះ ! អស្ចារ្យ ! ទឹកមាត់ដែលគាត់ព្រួសចេញទៅនោះ មានពន្លឺព្រាតដូចរងើកភ្លើង ហើយមានចំហាយក្តៅភាយមក ! ពួកសេនាវាំងភ្ញាក់ព្រើតគ្រប់គ្នា ដ្បិតមិនដែលឃើញនរណាស្តោះព្រួសចេញភ្លើងដូច្នេះ ប៉ុន្តែចំពោះគ្នីគ្នាគាត់វិញ គេគ្មានភ្ញាក់ផ្អើលអ្វីទេ ប្រហែលជាគេធ្លាប់ដឹង ធ្លាប់ឃើញធម្មតាមកហើយ។ គេរាល់គ្នានោះ បែរជាខំសង្កេតចំពោះជនរងគ្រោះនោះទៅវិញ ។ អស្ចារ្យណាស់, ពញាថីដែលសន្លប់យ៉ាងធ្ងន់ហើយប៊ិះតែរលត់ធាតុក្តៅទៅហើយ ថ្ងូររហ៊ឹះតែម្តង ។ ពញាថីដឹងខ្លួនវិញហើយ ។ នរៈនេះងើបអង្គុយឡើង មើលទៅជុំវិញខ្លួន ឃើញអាមាត្យដែលបានវាយដំខ្លួនខ្លះ និង

មនុស្សឯទៀតខ្លះ ហើយបានឃើញទាំងបាវទាំងដុំថ្ម ព្រមទាំងដំបងព្រនង់ឯទៀតផង ពញ្ញាជីវង្វេងស្មារតី យីអញនៅឯណាអ៊ីចេះ ? អញស្លាប់ទៅហើយទេដឹង ?

កំពុងរងរងីនោះ បុរសព្រួសផ្កាភ្លើងសួរឡើង :

_ នែក្មួយ , បានស្រួលបន្តិចហើយឬ ? ដឹងខ្លួនមែនទែនហើយ ឬ ?

ពញ្ញាជីឆ្លើយទាំងមិនទាន់ទុកចិត្តខ្លួនឯង :

_ បាទលោកពូ បានស្រួលហើយ.. អើចុះខ្ញុំនៅកន្លែងណាអីចេះ ? ហើយលោកពូជាអ្វី ?

នាយសុខឈ្ងោកទៅជិតប្រាប់ថា :

_នែទីនេះជាមាត់ទឹក, គេយកបងឯងដាក់ក្នុងបាវសណ្តួនថ្មនេះ សំបកបាវនេះ ដុំថ្ម ( នាយសុខចង្អុល) គេប្រុងទម្លាក់បងឯងឱ្យស្លាប់ក្នុងទន្លេនេះ !

ពញ្ញាជីមើលទៅសំបកបាវនឹងដុំថ្ម ក៏នឹកតក់ស្លុត.

_យី, ចុះនរណាគេឱ្យយកខ្ញុំមកទម្លាក់ទឹក ? ចុះប្រពន្ធខ្ញុំនៅឯណាទៅ? លោកណាជាអ្នកសង្គ្រោះខ្ញុំ ?

នាយសុខឆ្លើយទៀតព្រមទាំងចង្អុលប្រាប់ផង :

_នែ នេះជាលោកគ្រូ ជាអ្នកសង្គ្រោះបងឯង ! អម្បាញ់មិញបង

ឯងសន្ធប់គ្មានដឹងខ្លួនទេ!

ពញ្ញាថី ឱនក្បាលគោរព:

_ឱលោកគ្រូជាទីគោរព ដឹងគុណពុំភ្លេចទេ ! លោកគ្រូមានដំណើរមកពីណាទៅណា បានជាអញ្ជើញមកជួបជួយសង្គ្រោះខ្ញុំបាទនេះ? លោកគ្រូនៅឯណា?

នាយសុខក៏ឆ្លើយជួសលោកគ្រូទៀត:

_អើ កុំសង្ស័យ, លោកគ្រូនេះគាត់នៅឆ្ងាយណាស់ នៅម្ដុំវត្តខ្លបតាយ៉ង ស្រុកភ្នំដូនពេញឯណោះ! លោកគ្រូនេះហើយដែលមានព្រះនាមថា កែវព្រះភ្លើងនោះ ឈ្មោះកែវព្រះភ្លើង នៅស្រុកនោះនរណាក៏ស្គាល់ដែរ! ចម្លើយរបស់នាយសុខនេះ ធ្វើឱ្យនាយអាមាត្យភ្ញាក់ព្រើតឡើងដែរ: ឱលោកគ្រូនេះឈ្មោះកែវព្រះភ្លើង ? ឈ្មោះនេះពួកវាំងក៏ដូចជាធ្លាប់បានឮខ្លះៗដែរ។

កែវព្រះភ្លើងក៏និយាយសួរបុរសរងគ្រោះថា:

_នែ ! ក្មួយឯងមានដំណើររឿងយ៉ាងណា បានជាមកទាក់ទងនឹងវាំង ទាល់តែមានទុក្ខទោសដូច្នេះ? ក្មួយឯងឈ្មោះអី? នៅឯណា?

ពញ្ញាថីលើកដៃសំពះ បន្តិចក៏រ៉ាយរ៉ាប់ដំណើរទំនងប្រាប់គ្រូកែវព្រះភ្លើងយ៉ាងហូរហែ រួចបន្ថែមថា:

-ឱលោកគ្រូជាទីគោរពអើយ  សូមលោកគ្រូមេត្តាគិតយ៉ាងណា ជួយប្រពន្ធខ្ញុំបាទឱ្យជួបនឹងខ្ញុំបាទវិញផង!

គ្រូកែវព្រះភ្លើងលាន់មាត់ថា:

-យិះ  គិតទៅស្ដេចស្អីគេនេះព្រៃផ្សៃសម្បើមណាស់  ចាប់យកប្រពន្ធ កូនគេមកលេងសើចជាល្បែង  ហើយហ៊ានផ្ដន្ទាប្ដីគេទៀត  ហ៊ុះ ពូតែងបានឮដំណើងដូច្នេះរឿយៗណាស់  ពូក៏សែនតូចចិត្តណាស់ចំពោះអំពើទាបថោករបៀបនេះ  អើចំណែករឿងភរិយាក្មួយនោះមិនអីទេ  ចាំមើលពូគិតជួយយកមកវិញឱ្យខាងតែបាន!

ពោលដូច្នេះគ្រូកែវព្រះភ្លើង  លូកយកក្រដាស និង ដៃខ្មៅមកសរសេរបានមួយឃ្លាពីរ ហុចទៅឱ្យនាយសាន នាយសានទទួលញ៉ូវដៃបត់ដាក់ក្នុងហោប៉ៅ, គ្រូកែវព្រះភ្លើងក៏បញ្ជាថា:

ទៅ, ពួកឯងត្រឡប់ទៅវិញចុះ  យកសំបុត្រហ្នឹងទៅឱ្យស្ដេចឯងក្នុងយប់នេះកុំខាន!

-បាទ បាទ!

ពួកសេនារាំងទាំងប៉ុន្មាន  នោះឱនក្បាលសំពះលាបុរសកែវព្រះភ្លើង ថយចេញទៅ។ គ្រាន់តែផុតពីមុខបុរសនេះភ្លាម  ពួកអាទាំងប៉ុន្មាននេះក៏តាំងស្រាវជំហានយកលឿនតែម្ដង ក្រែងពួកកែវព្រះភ្លើងតាម

ហៅប្រើដូច្នេះ ដូច្នោះ ទៀត ។ នាយសាននិយាយទាំងញាប់ជើងថា:

-យិះ អាដែង, អញឮតែឈ្មោះថា កែវព្រះភ្លើងអញមិនដែលស្គាល់មុខ ឥឡូវក៏ស្រាប់តែមកដល់ញ៉ាប់តែម្ដង!

ហ៊ឺ អស្ចារ្យ! ស៊ិយណាស់ ដូចគេដើរមកជួបខ្លាធំអ៊ីចឹង!

ខ្វែក៏តបថា:

-មែន, អម្បាញ់មិញអញស្មានតែគាត់ទុកពួកយើងជាឈ្លើយ ជាខ្ញុំកំដរទៅទៀតហើយ! យី លោកគ្រូកែវព្រះភ្លើងនេះពូកែណាស់វើយ ព្រួសស្ដោះទៅ ចេញទឹកមាត់ដូចជាផ្កាភ្លើង!

- អ៊ីចឹង បានជាគេឱ្យឈ្មោះថាកែវព្រះភ្លើងនោះ!

ពួកអាមាត្យនិយាយគ្នាបណ្ដើរ បោះជំហានយ៉ាងញាប់បណ្ដើរ ឯក្រោយឯណោះ យើងឃើញពួកកែវព្រះភ្លើង កំពុងធ្វើដំណើរសរសៀតាមមាត់ទន្លេ ឆ្ពោះទៅទិសខាងជើង ។

# ៨

និយាយពីលោកអគ្គមហាសេនាកោជា ក្រោយដែលបង្គាប់ឱ្យពួកសេនា អាមាត្យនាំយកចេញពញ្ញាថីទៅទម្លាក់ទឹកចោលទៅនោះ លោកដូចជាបានរសាយសេចក្ដីក្រេវក្រោធពីក្នុងទ្រូងខ្លះ ។ ប៉ុន្តែ លោកចេះតែនៅនឹកថា : យីអាស្អីគេនេះ អង់អាចសម្បើមណាស់ គ្មានចេះតក់ស្លុតអ្វីសោះ ហ៊ានដៀលត្មះអញផង ! អើឥឡូវនេះឱ្យវាទៅនៅស្រុកទ្រីវាសី (ត្រីវាស៊ី) ទៅចុះ !

លោកកំពុងគិតបន្តពាក្យផ្ដាញ់ផ្ដាល់ដូច្នេះ ក៏ឃើញលោកមហាមន្ត្រីចូលមក ។ ទាំងពីរនាក់វរជននេះអង្គុយទីមគ្នាក្រោមពន្លឺចន្លុះ ។ លោកមហាមន្ត្រីចាប់សួរឡើងថា :

-លោកអគ្គមហាសេនា, ពីមុននេះខ្ញុំឮសូរមាត់តអ៊ីអ៊ូអរនៅកន្លែងលោកនេះ ?

-អ្ហ៎ គ្មានរឿងអ្វីទេ គឺខ្ញុំប្រដៅអាពញ្ញាដែលយើងទើបតែហៅវាឱ្យមករាំងនោះអី !

អានោះព្រហើនអស្ចារ្យ ! ហ៊ានតិះដៀលខ្ញុំ និង ព្រះករុណាជាអម្ចាស់ជីវិតយ៉ាងពេញមាត់ !

-យី វាគ្មានខ្លាចស្លាប់ទេឬ?

- អ៊ីចឹងមែន ដូចជាប្លែកគេណាស់អានោះ!

- ឥឡូវយកវាទៅណាហើយ?

-អើ ឱ្យទាហានប្រកបាវ យកទៅទម្លាក់ចោលកណ្ដាលទន្លេបាត់ទៅហើយ!

-អើ អ៊ីចឹងក៏ស្រួលដែរ កុំឱ្យវានាំឱ្យប្រពន្ធវាអាលោះអាល័យយូរ!

កំពុងនិយាយគ្នានោះ ស្រាប់តែលេចអ្នកបម្រើទាំងប៉ុន្មានត្រឡប់ចូលមកធ្វើគារវភាព។ លោកអគ្គមហាសេនា ប្រញាប់សួរមុនថា:

-ម៉េចអាសាង, អាខ្មៅ យកវាទៅទម្លាក់ទឹកដល់ណា ? ដល់កណ្ដាលទន្លេទេ?

នាយសាងតបដោយខ្លបខ្លាច:

-បាទទាន, ពួកខ្ញុំបាទពុំបានយកវាទៅទម្លាក់ទឹកទេ, ដ្បិតជួបនឹងមនុស្សមួយក្រុម មនុស្សនោះជួយវា! ទានប្រោស!

-ស្អី? អាឯងថាម៉េច? មនុស្សណាជួយវា?

លោកអគ្គមហាសេនាសួរដោយភ្ញាក់ ។ នាយសាង ក៏ជម្រាបឡើងវិញ:

-បាទទាន, ពេលដែលពួកខ្ញុំបាទហៀបតែនឹងដាក់អានេះទៅ

ក្នុងទូក ដើម្បីយកទៅទម្លាក់កណ្ដាលទន្លេនោះ ស្រាប់តែមានមនុស្សមួយក្រុមមកដល់ វាបង្ករឿងរ៉ាវភ្លាម ពួកខ្ញុំបាទតស៊ូនឹងវាពុំបានឡើយ, ពួកវាខ្លាំងពូកែណាស់ មេវា នោះ ឈ្មោះកែវព្រះភ្លើងទានប្រោស!

-ស្អី, ឈ្មោះកែវព្រះភ្លើង, ម៉េចក៏អាឯងដឹង?

-បាទទាន, ពួវានិយាយប្រាប់អាពញ្ញាបីនោះ, ហើយពេលដែលវាស្ដោះព្រួសឱ្យពញ្ញាបីនោះ ទឹកមាត់វាមានខ្ទាយជាភ្លើងព្រាតៗ ក្ដៅភាយៗ បន្តិចផង!

លោកទាំងពីរ ស្ដាប់រឿងនេះដោយភ្ញាក់ផ្អើលមើលមុខគ្នាទៅវិញទៅមក ។ ឈ្មោះកែវព្រះភ្លើងនេះ គេលាន់ខ្ទរខ្ទារយូរដែរហើយនៅតំបន់ភ្នំពេញ ហ្លួងលើកទ័ពទៅបង្ក្រាបពុំបានសោះ ។ ឯពេលនោះ នាយសាងក៏បង្ហាញសំបុត្រ របស់កែវព្រះភ្លើងដោយជម្រាបថា:

-ព្រះតេជគុណ គ្រូកែវព្រះភ្លើងនោះបានទាំងថ្វាយសំបុត្រមួយច្បាប់មកព្រះករុណាជាអម្ចាស់ជីវិតផង! នេះសំបុត្រ!

ហើយហុចសំបុត្រនោះមកលោកអគ្គមហាសេនា, លោកនេះប្រញាប់ទទួលមក ហើយអាមាត្យម្នាក់ប្រញាប់ទ្រោលបន្ទុះមកជិត ។ លោកអគ្គមហាសេនា និង លោកមហាមន្ត្រី ឱនក្បាលចោលភ្នែកស្រេបគ្នាទៅលើលិខិតនោះ ដែលមានសេចក្ដីថា:

" យើងជាប្រជាពលរដ្ឋម្នាក់កាន់សុចរិតយុត្តិធម៌, វិន័យថ្លៃថ្នូរ, យើងសូមរំលឹកព្រះចៅផែនដីថា គប្បីព្រះចៅលះបង់នូវអំពើថោកទាបអនាចារ្យ ព្រៃផ្សៃចោលចេញទៅ ! ឈប់កៀរគរកូនចៅប្រជារាស្ត្រយកមកកំសាន្តសប្បាយទៀតទៅ ! ហើយជាបឋមនេះ គប្បីព្រះចៅដោះលែងស្រីម្នាក់ដែលមានប្តីរួចទៅហើយ ឱ្យគេបាននៅជួបប្តីគេវិញផង ! បើព្រះចៅនៅតែប្រព្រឹត្តនូវអំពើអនាចារ្យថោកទាប ព្រមទាំងមិនដោះលែងស្រីនោះទៅវិញទេ ព្រះចៅនឹងត្រូវវង់គ្រោះថ្នាក់មួយដ៏ធំគេចពុំផុតសោះឡើយ !

ហត្ថលេខា: **កែវ ព្រះភ្លើង**

មើលសេចក្តីនេះចប់ លោកកោធាក្តៅប្រឡោតតួងតែម្តង:

_យី អាដែងកែវព្រះភ្លើងស្អីគេនេះ ហ៊ានប្រើពាក្យប្រមាថមកលើព្រះករុណាដល់ម្លឹងផង! យីអានេះព្រហើនអស្ចារ្យ !

លោកងាកទៅសួរនាយអាមាត្យ :

_ឥឡូវ ឯងមានដឹងទេ? ពួកអាទាំងនោះវាធ្វើដំណើរមកពីណាទៅណា?

-បាទទាន, តាមសំដីដែលគ្នាវាប្រាប់ពញាថីនោះ គឺពួកវាទើប

តែមកពីភ្នំពេញ! ឯដំណើរវាទៅណាទៀតនោះ ពុំឮវានិយាយទេ!

លោកអគ្គមហាសេនាងាកទៅកាន់លោកមហាមន្ត្រី:

-យី, យើងមានការណ៍មិនស្រួលកើតឡើងហើយ អាកែវព្រះភ្លើង

នេះចូលមក, ក៏ដូចជាខ្លាព្រៃចូលស្រុកដែរ!

លោកមហាមន្ត្រីសួរវិញ:

-ចុះសំបុត្ររបស់អាកែវព្រះភ្លើង នេះលោកគិតយ៉ាងម៉េច?

-អើ សំបុត្រនេះ ចាំព្រឹកសឹមយកទៅថ្វាយព្រះករុណា

ឥឡូវទុកសិន ត្បិតពេលរាត្រីព្រះអង្គកំពុងផ្ទុំស្រួល មិនត្រូវទៅ

នាំសៅហ្មងចំពោះព្រះអង្គទេ!

លោកកោធា យល់សេចក្តីសុខទុក្ខព្រះរាជាខ្លួនខ្លាំងណាស់ ។

ហើយលោកបែរជាសួរទៅនាយអាមាត្យទៀត:

-ចុះដំណើរយ៉ាងម៉េច បានជាវាដឹងថាស្តេចយកស្រីដែលមានប្តី

ហើយ វាព្រមានឱ្យស្តេចដោះលែង? ឯងមាននិយាយប្រាប់វាឬ?

-បាទ ទេ, គឺពញាថីទេដែលនិយាយរឿងនេះប្រាប់ឈ្មោះកែវ

ព្រះភ្លើងនោះ ខ្ញុំបាទឥតនិយាយទេ!

-បើអ៊ីចឹងពញាថី ឯងមិនបានទម្លាក់ទឹកទេឬ?

-បាទទាន, គ្រាន់តែទៅដល់មាត់ទឹក ក៏ពួកនោះមកដល់ល្មម កើតរឿងរ៉ាវក្លាមទានព្រោស !

-ហើយម៉េចក៏ពញាថីនោះវាដឹងខ្លួន ? ក្រែងវាសន្លប់ជិតស្លាប់ទៅហើយឬ ?

-បាទទេ, គឺឈ្មោះកែវព្រះភ្លើងដែលបេះស្ដោះព្រួសយ៉ាងចំឡែក ឈ្មោះ នេះព្រួសទៅលើខ្លួនប្រាណពញាថី ស្រាប់តែពញានេះដឹងខ្លួន ងើបឡើងតែម្ដង !

-ហ៊ឺ, អាកែវព្រះភ្លើងនោះខ្លាំងពូកែបេះអូមអាមណាស់ហ្ន៎ ! ឥឡូវនេះ អានេះប្រាកដជានាំពញាថីឱ្យទៅតាមជាមួយហើយ ! ប៉ុន្តែមិនជាអ្វីទេ ពួកអាអស់នេះទៅណាពុំរួចទេ វាមកក្នុងកន្លែងនេះ ដូចជានៅក្នុងជុបអញអ៊ីចឹងដែរ ! នែ, ឯងទៅសម្រាកទៅ, ស្អែកចាំគិតចាត់ការ !

ពោលតែប៉ុណ្ណោះ លោកធំទាំងពីរនាក់ ក៏ងើបបំបែកគ្នាចូលទៅកន្លែងរៀងខ្លួន។

ចំណែកលោកកោធា លោកសម្រាន្តពុំលក់ទេ បន់ឱ្យតែភ្លឺចាប់នឹងអាលយកសេចក្ដីទៅទូលព្រះបាទពញាអន ព្រមទាំងបានលើកទ័ពដើររកឈ្មោះកែវព្រះភ្លើងផង។

ព្រឹកឡើងដូចប្រាថ្នា លោកមហាមន្ត្រីនេះ ក៏បញ្ជាឱ្យវាយទ័ពទាហានសេះ១០០នាក់ជាស្រេច រង់ចាំចេញប្រតិបត្តិការ លោកម្ចីម្នាឡើងទៅគាល់ព្រះពញាអន ។ ព្រះពញាអនទ្រង់តើនឡើង ឃើញមន្ត្រីជំនិតឡើងមកគាល់តាំងពីព្រលឹមអុរដូច្នេះ ប្លែកណាស់ ក៏ត្រាស់សួរជាមុនថា:

-លោកកោធា ម៉េចលោកមានការអ្វីជាពិសេស បានជាលោកឡើងមកគាល់ខ្ញុំទាំងព្រលឹមអុរដូច្នេះ ? ហើយប្តីនាងស្រីល្អនោះ លោកយកទៅណាហើយ?

-សូមទ្រង់ព្រះមេត្តាប្រោស, ទូលបង្គំដោយនឹកក្តៅពេក ព្រោះវាបានពោលពាក្យប្រមាថចំពោះល្អងធូលីព្រះបាទនោះ ទូលបង្គំបានចាត់ឱ្យយកវាទៅសម្លាប់នៅមាត់ទន្លេក្រាបទូល !

ព្រះពញាអនសប្បាយព្រះទ័យមានបន្ទូលកាត់:

-អើធ្វើអ៊ីចឹងទើបសមនឹងកំហុសដែលប្រឆាំងនឹងខ្ញុំ ! តើឥឡូវវាស្លាប់ទៅហើយឬ?

-ព្រះករុណាថ្លៃវិសេស, វាពុំស្លាប់ទេ ដោយមានអាមេចោរម្នាក់វាមកជួយសង្គ្រោះនាំយកទៅ ! អាចោរនោះគឺឈ្មោះកែវព្រះភ្លើង សូមទ្រង់ជ្រាប....

ព្រះបាទពញាអន ឮឈ្មោះនេះស្តេចភ្ញាក់ព្រះអង្គព្រើត:

_ស្អីឈ្មោះកែវព្រះភ្លើង ដែលល្បីថាខ្លាំងពូកែនៅតំបន់ភ្នំដូនពេញនោះឬ? ហេតុអ្វីបានជាគេដឹងថា យើងយកអាពញាចីទៅសម្លាប់ហើយវាមកជួយបាននោះ?

_ព្រះករុណាថ្លៃវិសេស, ប្រហែលជាអានេះវាប្រុងចូលមកបង្កចលាចលនៅតំបន់នោះ វាមកដល់ក៏ជួបនឹងហេតុការណ៍ហ្នឹងទៅ សូមទ្រង់ជ្រាប!

_ចុះលោកគិតយ៉ាងណាដែរឥឡូវ ?

_សូមទ្រង់មេត្តាប្រោស ទូលបង្គំជាខ្ញុំគិតថា ត្រូវនាំទាហានទៅចាប់ឈ្មោះនេះ យកមកសម្លាប់ចោលខានមិនបាន ដ្បិតឈ្មោះនេះវាបានព្រមានលុះងធូលីព្រះបាទធ្ងន់ៗណាស់ វាបានផ្ញើសំបុត្រមួយមកលុះងធូលីព្រះបាទផង... ទូលបង្គំឈឺចាប់ណាស់!

ពេលដូច្នោះនាយកមន្ត្រីនេះ ថ្វាយសំបុត្ររបស់គ្រូកែវព្រះភ្លើងទៅព្រះពញាអន ។ ព្រះមហាក្សត្រនេះទទួលយកមកអាន ស្រាប់តែក្តោបញ្ញើលិខិតនោះភ្លាម ទឹកព្រះភក្ត្រប្រែជាមាំទាំ មានបន្ទូលហាក់ដូចជាកែវព្រះភ្លើងនៅនឹងមុខថា:

_យីះ, អាកែវព្រះភ្លើង អានេះហ៊ានប្រមាថអញដល់ម្លឹងផង?

អស្ចារ្យណាស់ ហ៊ានរំលឹកអញ ហ៊ានគម្រាមអញដែលជាម្ចាស់ផែនដី ! នែលោកកោធា ត្រូវលោកប្រញាប់នាំទាហានទៅចាប់អាមេចោរចង្រៃនេះឱ្យបាន ហើយយកមកដុតទាំងរស់នៅចំពោះមុខខ្ញុំ !

លោកកោធាថយចេញទៅ ។ ព្រះពញាអនក្តាប់ព្រះហស្តយ៉ាងណែន ក្រោកឈរ មានបន្ទូលមួម៉ៅថា :

-ខ្មោចអាប្រេតនរក, វាមិនដឹងថាឯងស្តេច, វាមិនដឹងថាឯងតួទេវតា តួព្រះឥន្ទព្រះព្រហ្ម, យីអានេះចង់ស្លាប់ចាប់ណាស់ !

ឯលោកកោធាព្រមទាំងលោកនាយទ័ព ក៏នាំគ្នារាយទាហានដើរស៊ើបសួររកមនុស្សចំណូលថ្មី ដែលទើបតែចូលមកនៅតំបន់នេះ។

## ៦

ចាប់និយាយអំពីលោកគ្រូកែវព្រះភ្លើងវិញ ។ ពេលព្រលឹមស្រាងៗ ក៏បានធ្វើដំណើរទៅដល់វត្តមួយ ។ វត្តទួលបាសាណមានបរិវេណធំបង្គួរ ។ វិហារបុរាណមួយគ្មានជញ្ជាំងនៅកណ្តាល មានកុដិព្រះសង្ឃ និង ចេតិយរកេតរកូតគ្មានរបៀបនៅពីក្រោយវិហារ ។ នៅក្បែររបងខាងមុខវិហារមានខ្ទមប្រក់ក្បឿងតូចមួយ ជ្រកនៅប្របគល់ជ្រៃសាខានៅលើខ្ទមនេះមានដុំថ្មពីរបីដុំ ព្រមទាំងមានស្លាធម៌ បាយសីតម្រៀបនៅនោះផង គឺជាខ្ទមអ្នកតា ។

នៅក្រោមម្លប់ជ្រៃសាខានេះ មានរោងវែងមួយសង់គ្របលើទូកងមួយដែលផ្កាប់លើបង្គង ។ លោកគ្រូកែវព្រះភ្លើង និង សិស្សគណនាំគ្នាដើរចូលទៅកាន់កុដិដែលនៅចំខាងក្រោយវិហារ ។

ឆ្កែធាត់ៗពីរបី ដែលកំពុងដេកវៀននៅនឹងភ្នក់ក្បែរនោះ លុះឃើញមនុស្សចម្លែកចូលមកដល់ ក៏តាំងស្ទុះដណ្តើមគ្នាព្រុស ផ្អើលយ៉ាងស្លន់ ។ លោកនេន និង ក្មេងវត្ត បានចូលមកចោមរោមមើលមុខមនុស្សចម្លែកនេះ ខ្លះស្រែកដេញឆ្កែយ៉ាងទ្រហឹង ។ គ្រានោះ លោកសង្ឃមួយអង្គសើងមម៉ើងចុះពីលើកុដិនោះ ដោយទ្រាំពុំបាននឹងការដែល

ទ្វហឹងអឹងអាប់នេះ ។ លោកនេះឃើញកែវព្រះភ្លើងក៏លាន់ព្រះឱស្ឋថា : ឱ! គ្រូទេតើ! ទើបអញ្ជើញមកដល់ទេឬលោកគ្រូ?

កែវព្រះភ្លើងលើកដៃដាក់លើថ្ងាស ឱនក្បាលបន្តិចជាកិច្ចគោរព លោកនោះ:

-ករុណា, ខ្ញុំករុណាទើបតែមកដល់ទេទាន ឱ ចុះម៉េចទៅព្រះតេជព្រះគុណធំនោះ? លោកបានស្រួលទេ ខ្ញុំករុណាគ្រាន់តែឮគេថា ព្រះអង្គប្រឈួនភ្លាមក៏ធ្វើដំណើរមកតែម្ដង... ប៉ុន្តែ ដំណើរទូកវាយូរក្រៃដល់ណាស់!

-ពរ លោកបានស្រួលហើយ ប៉ុន្តែពីល្ងាចមិញនេះមិនដឹងជាម៉េចទេ លោកចេះតែសួរអាត្មាអំពីលោកគ្រូ លោកថាលោកនឹកលោកគ្រូណាស់!

មានពុទ្ធដីកាដូច្នោះ ព្រះសង្ឃនោះក៏និមន្តឡើងទៅលើកុដិវិញ ។ ឯគ្រូ កែវព្រះភ្លើងក៏នាំសិស្សគណឡើងទៅដែរ ទាំងអស់គ្នានៅអង្គុយចាំឯរបៀងខាងក្រៅ ចំណែកលោកសង្ឃនោះ លោកចូលទៅល្វែងក្នុងបន្តិច លោកចេញមកវិញ បក់ព្រះហស្តហៅទាំងអស់គ្នា ។ កែវព្រះភ្លើង និង សិស្សគណនាំគ្នាដើរឱនៗចូលទៅ។

នៅក្នុងល្វែងនៃបន្ទប់នោះ ព្រះសង្ឃមួយអង្គចាស់ជរាគង់ស្តូក

ស្តីង ដកព្រះបស្សាសមួយៗដោយល្ហើយស្បើយកម្លាំង ។ គ្រូកែវព្រះភ្លើង ចូលទៅថ្វាយបង្គំយ៉ាងជិតលោកជរា លោកក៏ខំត្រដររងើបឡើងបាន ដូចជាសប្បាយៈ

-ឱកែវ, កែវមកដល់ហើយឬ ? អញល្ងាចមិញ បេះតែស្រមៃថា ឯងមក ហើយទើបនឹងភ្ញាក់អម្បាញ់មិញនេះក៏នឹកមៃៗដល់កែវឯងទៀត ស្រាប់តែលោកនេនចូលមកថាកែវឯងមក ! អា៎ គួរសរសើរណាស់ នឹក ដើមមកដល់ !

-ព្រះករុណា ខ្ញុំករុណាគ្រាន់តែបានដំណឹងថា ព្រះតេជគុណពុំ ស្រួលព្រះអង្គភ្លាម ក៏ធ្វើដំណើរមកភ្លាម.... ឯនេះជាសិស្សគណរបស់ខ្ញុំ ករុណា គេចង់ស្គាល់ ចង់ថ្វាយបង្គំព្រះតេជគុណនេះ ក៏ធ្វើដំណើរតាម ខ្ញុំករុណាមកដែរ! ហើយម៉េចទៅអាការរោគព្រះតេជព្រះគុណ ?

គ្រូកែវបានលូកស្ទាបព្រះបាទ ព្រះហស្ត របស់លោកគ្រូចៅ អធិការដោយគោរពផង ។ លោកគ្រូសង្ឃដ៏ចាស់នេះមានពុទ្ធដីកាថាៈ

-អើ, បានស្រួលហើយ, ប៉ុន្តែគឺជាការធម្មតាទេ ចំណាស់ថ្នាក់នេះ ហើយ ម៉ៃកាត់ មៃកោរយ៉ាងនេះ !

-ឱ មិនអីទេ ឥឡូវនេះខ្ញុំករុណាមកនេះ ក៏បាននាំយកឱសថខ្លះ មកប្រគេនចាន់ដែរ ដើម្បីរក្សាសុខភាពព្រះអង្គ !

ពោលតែប៉ុណ្ណោះ គ្រូកែវព្រះភ្លើងបានសុំឱ្យលោកនេនយកថ្មដុស និង ទឹកមកផង ។ បានថ្ម និង ទឹកមកហើយ គ្រូកែវព្រះភ្លើងបានទាញស្បោងក្បែរខ្លួនមករលាក់, ថ្នាំបុរាណឫសឈើ, មើមឈើ, សំបកឈើ, ចង្កូមសត្វ, ធ្មេញសត្វ បានធ្លាក់មករាយលើកន្ទេល ។ គ្រូកែវព្រះភ្លើងតាំងដាក់ទឹកដុសថ្នាំទាំងនោះមួយមុខម្តង ។ ឯនាយសុខក៏ជួយដុសដែរ ។

តើលោកគ្រូចៅអធិការវត្តទទួលបាសាណនេះ ត្រូវជាអ្វីនឹងកែវព្រះភ្លើង បានជាកែវព្រះភ្លើងខំយកចិត្តទុកដាក់ គោរពលោកគ្រូនេះម្ល៉េះ ? យើងសូមជម្រាបអស់លោកអ្នកអានថា លោកគ្រូចៅអធិការវត្តទួលបាសាណនេះ ត្រូវជាគ្រូបង្រៀន ឥ–មោ និង បាលីបារគូខ្លះដល់កែវព្រះភ្លើង កាលពីកែវព្រះភ្លើងនេះនៅជាកុមារ ។ កែវព្រះភ្លើងនេះ ពីដើមជាកុមារកំព្រា មាក្មើយមកផ្ញើនឹងលោក សុំឱ្យលោកជួយបង្ហាត់អក្សរលំនាំផង ។ កែវព្រះភ្លើងបានទទួលការទំនុកបំរុង សន្តោសប្រោសប្រាណអំពីលោកគ្រូនេះណាស់ ។

ហេតុនេះហើយ ទើបកែវព្រះភ្លើងមានសេចក្តីដឹងគុណចំពោះលោកគ្រូ ចៅអធិការនេះឯង ទោះបីខ្លួនបែកពីលោកទៅរៀនបាលី បារគូមន្តវិជ្ជាការពីគ្រូច្រើនទៀត លុះត្រាបានខ្លាំងពូកែមើលជម្ងឺអ្នកស្រុកហើយនៅឆ្ងាយពីលោកគ្រូដើមយ៉ាងណាក៏ដោយ កែវព្រះភ្លើងក៏នៅតែ

មានសេចក្ដីគោរពចំពោះលោកដែរ តែងឧស្សាហ៍មកអើតសួរសុខទុក្ខចំពោះលោកគ្រូរឿយៗ ។ ទើបតែក្នុងឆ្នាំនេះទេ ដែលកែវព្រះភ្លើងពុំសូវបានមក ព្រោះកែវព្រះភ្លើងត្រូវប្រយ័ត្នខ្លួន ខ្លាចពួកស្ដេចនៅទួលបាសាណនេះបៀតបៀន។

ពួកស្ដេចនៅទួលបាសាណនេះ បានចាត់ឱ្យសេនាទាហានទៅព្យាបាទកែវព្រះភ្លើងម្ដងពីរហើយ ប៉ុន្តែកែវព្រះភ្លើងពុំមានរងគ្រោះថ្នាក់ដោយសារពួកនេះឡើយ។

គ្រានេះ ដោយបានដំណឹងតាមអ្នកនៅទួលបាសាណនេះ ដែលគេទៅរកកែវព្រះភ្លើងដើម្បីឱ្យមើលជម្ងឺនោះ ថាលោកគ្រូចៅអធិការវត្តមានអាពាធជាទម្ងន់នោះ ទើបកែវព្រះភ្លើងម្នីម្នាធ្វើដំណើរមកនេះឯងដោយមានសិស្សគណច្រើននាក់ធ្វើដំណើរអមផង ។ ឯសិស្ស ដែលជំនិតជាងគេ គឺនាយសុខ ។

គ្រាដែលដុសថ្នាំដាក់កែវមួយបានធ្លនល្មមហើយ កែវព្រះភ្លើងក៏លើកភេសជ្ជ:នោះប្រគេនលោកគ្រូ:

-សូមព្រះតេជព្រះគុណនិមន្តឆាន់..

លោកគ្រូចៅអធិការទទួលឱសថនោះមកឆាន់បន្តិច រួចមានពុទ្ធដីកាថា:

-អើ រាងដូចជាល្វីងៗ!

-ព្រះករុណា ថ្នាំនេះត្រជាក់ស្រួលព្រះអង្គណាស់ !

លោកគ្រូចាន់ទៀត រួចលោកមើលទៅមុខសិស្សគណរបស់គ្រូកែវ ព្រះភ្លើងទាំងអស់គ្នា មានពុទ្ធដិកាថា:

-អើអស់លោកអើយ, អាត្មាបានសិស្សនេះម្នាក់ហើយ គេពុំដែលភ្លេចអាត្មាទេ ទោះបីគេបែកទៅរៀនសូត្រមានវិជ្ជាខ្លាំងពូកែយ៉ាងម៉េចក៏គេឧស្សាហ៍មកអើតឈ្វេកអាត្មាដែរ ! អើ អាត្មាធ្លាប់ហៅគេតាំងពីតូចនោះថា “ កែវៗ ” ដល់ឥឡូវគេ ធ្វើគ្រូហ្មទឹកមាត់មានផ្កាភ្លើងទៅ អ្នកស្រុកគេហៅថែមទៀតថា ព្រះភ្លើងតែម្តង ! ឈ្មោះនេះប្លែកណាស់ ! មែនទេអស់លោក ?

សិស្សទាំងប៉ុន្មាននោះឆ្លើយទៅលោកព្រមគ្នា រួចងាកមកមើលមុខគ្រូ របស់ខ្លួន ។ កែវព្រះភ្លើងគ្រាន់តែសើចញ៊ឹមៗ ។

គ្រានោះកែវព្រះភ្លើងមើលទៅពញាថី មនុស្សដែលគាត់បានសង្គ្រោះ គាត់ក៏មានរឿងជម្រងទូលសួរលោកគ្រូថា:

-ព្រះតេជគុណ, ខ្ញុំករុណាឮថាស្តេចសព្វថ្ងៃនេះ លោកផ្តេសផ្តាសសម្បើមណាស់ ធ្វើឱ្យរាស្ត្រក្តៅក្រហាយយ៉ាងច្រើន មែនឬទេព្រះគុណ ?

ឮពាក្យនេះ លោកគ្រូចៅអធិការដកដង្ហើមធំ!

-ហ៊ឺ, កែវ, ឯងឮនោះពិតប្រាកដហើយ អញឮសព្វថ្ងៃស្ទើរបែកទ្រូងទៅហើយ ដោយសារឧបាសក ឧបាសិកាជើងវត្ត ទឹកភ្នែកទឹកសំបោរមកប្រាប់នោះ ហ៊ឺ! សព្វថ្ងៃកូនចៅអ្នកស្រុកគ្មានសល់មួយទេ ស្ដេចនោះគៀរគរយកទៅធ្វើស្នំ... គ្នាខូចខ្លួនខូចប្រាណអស់ ! អំពើនេះអ្នកស្រុកមានការឈឺចាប់នៅក្នុងចិត្តណាស់ ! ប៉ុន្តែមិនហ៊ានធ្វើអី បើលោកជាហ្លួង, ជាអម្ចាស់ជីវិតលើត្បូងយើងទាំងអស់គ្នានោះ!

កែវព្រះភ្លើងដកដង្ហើមធំដែរ មើលមុខពញាថី ហើយទូលលោកគ្រូទៀតថា:

-ហ៊ឺ...ព្រះតេជព្រះគុណ, ឥឡូវតំបន់ក្បែរខាងទួលបាសាណត្រូវបានស្ដេចពាលនេះ ឱ្យសេនាដើររាតត្បាតកូនចៅអ្នកស្រុកថែមទៀត ហើយមិនថាតែស្រីក្រមុំទេ គ្នាមានប្ដីទៅហើយក៏ឱ្យគេចាប់យកមកទៀតដែរ ។ ក្មួយម្នាក់នេះនៅឯទួលតាឯក (គាត់ចង្អុលទៅពញាថីបង្ហាញលោក) ត្រូវស្ដេចនោះចាប់ប្រពន្ធគ្នាមក លុះគ្នាសុំអង្វរយកទៅវិញ ស្រាប់តែចោទប្រកាន់គ្នាថាប្រមាថព្រះចេស្ដា ហើយធ្វើទោសគ្នាយកគ្នាប្រេកបាវសណ្ដូនថ្មទម្លាក់ទឹក ! កុំតែខ្ញុំករុណាមកជួយទាន់ កុំអីគ្នាស្លាប់បាត់ស្រេច! ឃើញពួកនេះគាចសាហាវអស្ចារ្យ ខ្ញុំព្រះករុណាពុំដែល

ឃើញទេ !

ព្រះសង្ឃចាស់នេះងាកទៅមើលមុខពញាថី ដែលក្រៀមក្រំលោកនឹកអាណិតយ៉ាងខ្លាំង ងាកមកសួរសិស្សរបស់លោកថា:

_ហ៊ឺ, ចុះកែវឯងគិតយ៉ាងណាដែរទៅ ? កែវឯងមិនជួយគ្នាឱ្យបានប្រពន្ធគ្នាវិញទេឬ ? យីស្ដេចពាលចណ្ឌាលកាចនេះ ម៉េចក៏មិនមានទេវតាបរាមុខទៅហ្ន៎ !

កែវព្រះភ្លើងក៏ទូលលោកថា:

_ចំពោះរឿងក្ដួយនេះគឺជារឿងធំ ខ្ញុំករុណាទៅជាសត្រូវទី១របស់ស្ដេចនេះស្រេចទៅហើយ ដ្បិតខ្ញុំករុណាបានវាយពួកអាមាត្យទាល់តែរាប ហើយចាប់វាទុក ខ្ញុំករុណាសរសេរសំបុត្រខ្លីមួយច្បាប់ឱ្យមេអាមាត្យនោះយកទៅថ្វាយស្ដេច ក្នុងសំបុត្រនោះ ខ្ញុំករុណាប្រាប់ស្ដេចនោះថាឱ្យឈប់ផ្ដេសផ្ដាសធ្វើបាបរាស្ត្រទៀតទៅ ហើយថា ឱ្យដោះលែងនាងប្រពន្ធនាយនេះមកវិញផង ។ ខ្ញុំករុណាបន្ថែមថា បើស្ដេចឯងនៅតែរឹងទទឹងមិនព្រមឈប់ផ្ដេសផ្ដាស និង មិនដោះលែងប្រពន្ធគេមកវិញទេស្ដេចឯងនឹងឃើញគ្រោះអាក្រក់មួយមិនលែង ហើយខ្ញុំករុណាចុះឈ្មោះខ្ញុំករុណាថាកែវព្រះភ្លើង នៅខាងក្រោមផង !

_យីស ឯងហ៊ានសរសេរផ្ញើទៅស្ដេចនោះដូច្នេះផង ?

ព្រះគ្រូចៅអធិការលាន់ព្រះឱស្ឋដូចគេភ្ញាក់ ព្រោះលោកយល់ថា ការធ្វើដូច្នេះ គឺដូចជាគេប្រកាសតាំងខ្លួនជាសត្រូវចេញមុខត្រង់ៗតែម្តងចំពោះស្តេចផែនដី...

ស្តេចផែនដី កុំថាឡើយដល់ទៅពោលទ្រគោះដល់ថ្នាក់នេះ សូម្បីតែបានប្រព្រឹត្តឱ្យស្តេចខឹងបន្តិចនេះ មុខជានឹងត្រូវចោទថាប្រមាថព្រះចេស្តាមិនខាន ហើយឱ្យតែចូលក្នុងបទប្រមាថព្រះចេស្តាហើយ មុខជានឹងត្រូវស្លាប់យ៉ាងងាយ។ ព្រះគ្រូចៅអធិការលោកនឹកបារម្ភជាស្រេច:

-យី កែវឯងមុខជានឹងត្រូវពួកអាជ្ញាដើររកចាប់ក្នុងពេលឆាប់នេះមិនខានទេ ព្រោះឯងសរសេរនោះធ្ងន់ណាស់ យីវីវរហើយពេលនេះ !

គ្រូកែវព្រះភ្លើងទូលតបវិញថា:

-ការណ៍នេះខ្ញុំករុណាបានដឹងខ្លួនស្រេចហើយ ថាមុខជានឹងកើតរឿងរ៉ាវជាមួយស្តេចនេះ ប៉ុន្តែ ខ្ញុំករុណាដោយពិតទៅដូចជាគ្មានភ័យបារម្ភសោះចំពោះគ្រោះថ្នាក់ផ្ទាល់ខ្លួន ផ្ទុយទៅវិញ ខ្ញុំករុណាដែលហ៊ានសរសេរផ្ញើទៅរំលឹកស្តេចពាលនោះដូច្នោះ គឺខ្ញុំករុណាហ៊ានចេញមុខប្រឆាំងកំចាត់ស្តេចចង្រៃនោះដោយត្រង់ៗតែម្តង ! ខ្ញុំករុណាមិនអាចនៅស្ងៀមទ្រាំមើលសេចក្តីឈឺចាប់របស់ប្រជាជន បងប្អូនដែលបានរងគ្រោះដោយសារស្នាដៃស្តេចទុរយសនេះបានឡើយ !

លោកគ្រូភ្ញាក់ព្រះអង្គមែនទែន:

-ស្អី កែវឯងគិតចេញមុខប្រឆាំងនឹងស្ដេច? យី មែនទែន ឬម៉េច?

កែវព្រះភ្លើងញញឹមអង់អាចថា:

-ព្រះករុណាពិតមែន, ឱ្យតែស្ដេចនោះមិនព្រមដោះលែងប្រពន្ធក្មួយនេះមកទេ និង មិនព្រមឱ្យគេឈប់ដើរចាប់ប្រពន្ធក្មួយនេះមកទេ និង មិនព្រមឱ្យឈប់ដើរចាប់ប្រពន្ធកូនអ្នកស្រុកទេនោះ ខ្ញុំករុណាមុខជានឹងកទ័ពចូលកំចាត់ស្ដេចនោះមិនខាន ! ខ្ញុំករុណាស្ទាបស្ទង់ឃើញរួចស្រេចហើយថាមានរាស្ត្រជាច្រើនណាស់ ដែលគេក្ដៅក្រហាយនឹងស្ដេចអប្រិយនេះ គេទន្ទឹងតែមានកងទ័ពបដិវត្តន៍ គេនឹងចុះចូលរួមជាមួយភ្លាម ដើម្បីរួមដៃរំលំរបបគ្រប់គ្រងពុករលួយព្រៃផ្សៃនេះចេញ ។ ដូច្នេះបើនិយាយពីកងទ័ព, ឃើញថាខ្ញុំករុណាក៏មានសម្រាប់ធ្វើការដែរ !

ហើយបើនិយាយពីសមត្ថភាពខ្ញុំករុណាវិញ ដូចព្រះតេជគុណជ្រាបស្រាប់ ខ្ញុំករុណាប្រហែលជាអាចធ្វើការហ្នឹងបាន ! ឬព្រះតេជគុណជាគ្រូ ពុំសប្បាយព្រះទ័យនឹងគំនិតគ្រោងការរបស់ខ្ញុំករុណានេះទេ ?

លោកគ្រូចៅអធិការញញឹមតបវិញ:

-ទេ, អញមិនមែនមិនពេញចិត្តចំពោះគំនិតគ្រោងការរបស់ឯងទេ, ហើយអញក៏ជឿលើសមត្ថភាពឯងខ្លះៗដែរ, ឯការដែលអញបញ្ឆាក់

ឯងអម្បាញ់មិញនេះ គឺមកពីអញភ្ញាក់ស្រឡាំងកាំងបន្តិចប៉ុណ្ណោះ ព្រោះអញពុំស្មានថាឯងហ៊ានដល់ទៅគិតយ៉ាងនេះទេ .... ឥឡូវបើឯងហ៊ានដូច្នេះហើយ អញក៏មានអំណរដែរ ហើយសូមប្រសិទ្ធិពរ, បើកើតកលិយុគនោះ អញសុំឱ្យឯងមានជ័យជំនះ ឈ្នះពួកស្តេចដូចប្រាថ្នា!

កែវព្រះភ្លើងក្រាបក្បាលគោរព :

-សាធុ, ខ្ញុំករុណាសូមទទួលពរព្រះតេជគុណ!

ការទទួលពរជាលើកដំបូងនេះ ព្រឺព្រួចសម្បើម

# ៧

ការប្រកាសខ្លួនរបស់កែវព្រះភ្លើង ចំពោះលោកគ្រូចៅអធិការគ្រានេះ នាំឱ្យយើងយល់បានថា ប្រាកដជាមានការបដិវត្តន៍មួយធំពុំខាន។

ក៏ប៉ុន្តែគ្រានេះ កែវព្រះភ្លើងផ្ដើមកិច្ចការអ្វីពុំទាន់ទេ ពួកវាំងបានចាត់ការលើរូបកែវព្រះភ្លើងជាមុនស្រេច ។ ក្នុងគ្រាដែលកែវព្រះភ្លើង និង បក្សពួកកំពុងនៅជជែកលេងនឹងព្រះគ្រូចៅអធិការ ស្រាប់តែលាន់គគ្រឹកមកតែម្ដង ។ ក្មេងវត្តម្នាក់ត្រហេបត្រហប ឡើងមកទូលលោកគ្រូនៅចំពោះមុខទាំងអស់គ្នាថា:

-លោកគ្រូ មានទាហានច្រើនណាស់ មកដល់ខាងលិចវត្តហើយទាន!

កែវព្រះភ្លើងមើលទៅមុខបណ្ឌិតសុខបន្ថិច ទើបងាកទៅទូលលោកគ្រូចៅអធិការថា:

-ព្រះតេជព្រះគុណ, ប្រហែលពួកវាំងបានដឹងថា ខ្ញុំករុណាមកទីនេះហើយ ដើម្បីចៀសវាងកុំឱ្យវាចូលមកបៀតបៀនព្រះតេជព្រះគុណដោយសារខ្ញុំករុណានោះ ខ្ញុំករុណាសុំថ្វាយបង្គំ នាំបក្សពួកចេញពីទីនេះហើយ!

_យីវីវរហើយ, នៃកុំទៅណា ឡើងទៅពួនលើស្អាកកុដិសិនទៅ! ចាំវាមកសួរអាត្មាឆ្លើយថាមិនឃើញ!

_ទេ, នាំតែរវល់ទេ វាមកវាមុខជានឹងឡើងឆែកចេរ លុះឃើញក៏កើតកាប់ចាក់គ្នានៅទីនេះ នាំឱ្យពិបាកព្រះតេជព្រះគុណ ខ្ញុំករុណាលាសិនហើយ!

ពោលតែប៉ុណ្ណោះ កែវព្រះភ្លើង និង សិស្សគណ ព្រមទាំងពញាថីថយ ចុះម្នីម្នាមកដី ហើយរត់គេចតាមខឿនវិហារសំដៅទៅមុខវត្តតែម្តង។

គ្រាន់តែកែវព្រះភ្លើងចុះបន្តិច កងទាហានក៏បានចូលព្រឹបមកដល់វត្ត ហើយទាហានបួនដប់នាក់សំដៅមកកុដិលោកគ្រូចៅអធិការ ។ លោកកោធាមើលខាយអាយ រួចស្រែកសួរទៅលោកនេនមួយអង្គដែលឈរធ្វើឡឹងឡង់នោះថា:

_នៃលោកនេន, មានឃើញមនុស្សចម្លែកទេ?

_ទេ អាត្មាអត់ដឹងទេ!

_លោកគ្រូធំនៅទេ?

_ពរ, លោកនៅនេះទេ! លោកអាពាធ!

លោកកោធាបញ្ជាទៅទាហាន:

_អាសាន, ឡើងទៅឆែកឱ្យអស់ ហើយអាឯទៀតឡើងទៅឆែក

ឱ្យគ្រប់កុដិឯទៀតកុំឱ្យសល់ ! មើលឱ្យមែនទែន! បើវាចូលមកក្នុងវត្តនេះមែន វាគ្មានទៅណារួចទេ!

ភ្លាមនោះ ពួកទាហានប្អូនដប់នាក់ឡើងស្រលើកុដិព្រះគ្រូចៅអធិការ ។

ព្រះគ្រូចៅអធិការគង់ស្ងៀម លុះពួកនោះមកដល់ លោកក៏សួរថា:

_យី, ចុះអស់លោករាល់គ្នាអញ្ជើញឡើងមកដល់កុដិអាត្មានេះមានការអ្វី?

នាយសានឆ្លើយព្រមទាំងសួរ:

_មករកអាមេចោរម្នាក់ វាមកសំណាក់នៅលើកុដិនេះ ឥឡូវវានៅឯណា? តេជគុណឱ្យវាទៅណាហើយ?

លោកគ្រូចៅអធិការជ្រាបច្បាស់ថា ពួកនេះជលោកទេ ក៏ធ្វើងើ:

_យី ម៉េចក៏អស់លោកជ្រាបថា មានចោរមកសំណាក់នៅលើកុដិអាត្មា? នរណាប្រាប់លោក? អាត្មាមានដែលចិញ្ចឹមចោរពីកាលណា?

_ប៉ុន្តែ ខ្ញុំករុណារាល់គ្នាសុំឆែកមើលសិន!

_ពរ, សុំអញ្ជើញឆែកទៅ!

ឆ្លើយដូច្នោះហើយ ព្រះគ្រូចៅអធិការក៏សឹងទៅវិញធ្វើព្រះងើយ ។

ពួកអស់នោះក៏តាំងរើអាយរមូរកន្ទេល ដែលបញ្ឈរនៅជញ្ជាំង ហើយខ្លះឡើងទៅលើស្លាកទៀត រកមើលមនុស្សដែលខ្លួនប្រាថ្នា ។ ប៉ុន្តែ រកឯណាឃើញ បើមនុស្សនោះគេចទៅបាត់ហើយ រាល់គ្នាចុះមកវិញ ជំរាបលោកមហាសេនាថា : អត់ឃើញទេ រកសព្វហើយគ្មានឃើញទេ ! លោកកោធានឹកចង់ដឹងជាក់ច្បាស់ ក៏ទៅលើកុដិខ្លួនឯងទៀត ចូលទៅ សួរលោកគ្រូចៅអធិការដែលកំពុងសឹង ។ តាមការគោរពគួរសមចំពោះ ព្រះសង្ឃគួរតែលោកនេះថ្វាយបង្គំបន្តិច ប៉ុន្តែ លោកកោធាគ្មានការ គោរពលោកឡើយ ចូលទៅដល់ក៏សួរលោកថា :

_លោកគ្រូកើតអីហ្នឹង ?

លោកគ្រូនឹកថាមហាសេនានេះព្រហើនណាស់ ប៉ុន្តែ ប្រកាន់គេ ពុំបានទេ គេជាពួកហ្លួង លោកឆ្លើយថា :

_ពរអាត្មាឈឺ, ចុះលោកអញ្ជើញមកមានការអី ?

_ខ្ញុំករុណាបានដំណឹងថា មានចោរវាចូលមកស្រុកបាសាណ នេះ ហើយប្រហែលវាសំណាក់នៅវត្តនេះ ! តើលោកគ្រូមានឃើញវាទេ ? ប្រាប់ខ្ញុំករុណាមក !

_អាត្មាគ្មានទេ, អាត្មាជាលោកសង្ឃ អាត្មាប្រដែប្រដៅគេឱ្យ

កាន់សីល យ៉ាងហោចណាស់ក៏ឱ្យគេមានសីលដែរ គឺកុំសម្លាប់គេ កុំលួចគេ កុំលួចកូនប្រពន្ធអ្នកដទៃ កុំកុហកគេ កុំផឹកសុរា... បើអ៊ីចឹង តើម៉េចក៏ទៅជាចូលដៃចូលជើងនឹងចោរទៅរួច ? ដំណឹងដែលលោកទទួលនោះពុំពិតទេ !

លោកកោធាបែបទាល់ប្រាជ្ញាដែរ លោកថយមកវិញ ប៉ុន្តែ ហៀបនឹងចេញផុតពីល្វែងនោះ លោកបែរទៅនិយាយម៉ឺងម៉ាត់នឹងលោកគ្រូចាស់ថា :

_លោកគ្រូ ខ្ញុំករុណាសូមពិតពុទ្ធដីកាឱ្យហើយ ថ្ងៃមុខថ្ងៃក្រោយតិចលោខ្ញុំករុណាឃើញលោកគ្រូទាក់ទងនឹងពួកកែវព្រះភ្លើងអី ខ្ញុំករុណានឹងមិនអត់ឱនឱ្យទេ ខ្ញុំករុណានឹងឱ្យគេចាប់ផ្សឹកយកទៅកាត់ទោសហើយ !

...ទើបចុះមកដីវិញរួចស្រែកសួរទៅទាហានឯទៀត :

_ម៉េចអាដែងវាល់គ្នា រកឃើញទេ ?

ពួកនោះរត់ចូលមកឱនក្បាលជម្រាប :

_បាទ, រកសព្វទីកន្លែងកៀនកោះអស់ហើយ គ្មានឃើញទេទានប្រោស !

លោកកោធាសម្លក់ដំរិះគិត លោកនិយាយតិចៗនឹងលោកនាយ

ទ័ពថា

-អានេះប៉ិនគេចខ្លួនណាស់ ! ទៅយើង ទៅរាំងរីញចាំគិតការជាថ្មីទៀត!

កងទាហានរាំងនេះក៏តាំងឡើងសេះព្រីបៗ រួចធ្វើដំណើរទៅវិញ។

ឯចំណែកព្រះគ្រូចៅអធិការ កាលបើបាត់ឮសូរជើងសេះ លោកហៅលោកនេនមកសួរថា:

-ពួកទាហានហ្លួងទៅវិញអស់ហើយឬ?

-ករុណា វាទៅវិញអស់ហើយ!

-យីពួកអស់នេះព្រហើនៗណាស់ ហើយព្រហើនសម្បើមគឺលោកមហាសេនាតែម្តង គ្មានស្គាល់ឯងជាលោកសង្ឃអីទេ ! ហើយវាមានដាក់កម្រិតឱ្យឯងទៀត វាថាតែឯងទាក់ទងនឹងកែវព្រះភ្លើងវានឹងចាប់ផ្សឹកយកទៅកាត់ទោស ! យី អានេះប្រមាថអញសម្បើមណាស់ មិនយូរមិនចាប់ទេគង់តែទេវតាបំផ្លាញឱ្យថ្លោះយសធ្លាក់ងារមិនខានទេ។

-អើ ចុះលោកនេនឯងមានដឹងថា កែវព្រះភ្លើងទៅពួនឯណាដែរ?

-ព្រះករុណា, ខ្ញុំករុណាពុំដឹងដែរ ប៉ុន្តែកាលដែលឃើញគាត់រត់

ទៅនោះ គឺរត់សសៀរតាមខឿនវិហារទៅខាងកើត ប្រហែលជាច្លងអូរផុតទៅដល់ភូមិឯកើតហើយយ៉ាង!

-អើ ឯងឱ្យក្មេងតាមទៅរកផងមើល បើឃើញឱ្យវាត្រឡប់មកវិញ!

-ព្រះករុណា!

លោកនេនឆ្លើយទៅនឹងលោកគ្រូ រួចងាកមកប្រើក្មេងឱ្យទៅតាមរកគ្រូកែវព្រះភ្លើង។

ក្មេងម្នាក់ខោខ្លីទទេ បានរត់ទៅទិសខាងកើតបាត់មួយស្របក់ធំទើបយើងឃើញក្មេងនោះត្រឡប់មកវិញទូលលោកនេនថា:

-ទានលោកគ្រូ កែវព្រះភ្លើងបានច្លងផុតចូលទៅភូមិឯកើតហើយទាន។

-អ៎ បើអ៊ីចឹងទៅដល់ភូមិឯកើតមែនហើយ!

លោកនេនក៏ទូលទៅលោកគ្រូអធិការតាមដំណើរ:

-ព្រះតេជព្រះគុណ, គ្រូកែវព្រះភ្លើងនោះច្លងផុតទៅដល់ភូមិឯកើតមែនហើយ ក្មេងទើបតែមកប្រាប់ ! មើលទៅគាត់ផុតគ្រោះថ្នាក់ហើយ!

-អើ អញបន់ឱ្យតែវាបានសុខសប្បាយទៅទេ! ប៉ុន្តែ កែវព្រះភ្លើង

វាមុខជាមិនសុខចិត្តស្ងៀមទេ វាមុខជានឹងបញ្ឆះបញ្ឆូលរាស្ត្រ ធ្វើការប្រឆាំងតទល់នឹងស្តេចសព្វថ្ងៃនេះមិនលែង! អើចាំមើលទៅចុះ!

ព្រះគ្រូចៅអធិការនេះមានពុទ្ធដីកាប៉ុណ្ណោះ ក៏ស្ងៀមនៅ។

ចំណែកគ្រូកែវព្រះភ្លើង និង បក្សពួកពេលនេះបានថ្លែងអូរ រួចចូលផុតទៅដល់ភូមិឯកើត គេចផុតពីកណ្តាប់ដៃសត្រូវដូចប្រាថ្នា។

និយាយពីស្តេចឈ្មោះពញាអនវិញ។ ពេលដែលលោកអគ្គមហាសេនាកោធាចេញទៅនោះ លោកមានសេចក្តីសប្បាយណាស់ ហើយរង់ចាំដោយសង្ឃឹមថា នឹងបានឃើញមុខមនុស្សដែលស្តេចត្រូវការសម្លាប់នោះផង។

គ្រានោះលោកអគ្គមហាសេនាបានចូលមកដល់។

គ្រាដែលលោកកោធាចូលមកគាល់វិញដោយដៃទទេនេះ ព្រះពញាអនក៏សួរថា:

_ម៉េចលោកកោធា, លោកទៅរកអាកែវព្រះភ្លើងនុះឃើញទេឬ?

_ព្រះករុណាថ្លៃវិសេស, អានេះវាពិតជាសម្ងំពួននៅតំបន់ណាមួយ!

_លោកមានឱ្យរុករកគ្រប់ភូមិស្រុកហើយនៅ?

_ព្រះករុណាថ្លៃវិសេស, នៅតំបន់ឯទៀតរកពុំទាន់គ្រប់សព្វទេ

កំពុងឱ្យរុករកបន្តទៅទៀត ! ប៉ុន្តែផ្នែកខាងជើងដែលយើងសង្ស័យថាវាចូលមកស្នាក់នៅនោះ, រកសព្វគ្រប់ហើយពុំឃើញវាសោះ!

ព្រះពញាអនដកដង្ហើមធំដោយបារម្ភ:

_ហ៊ឺ... វាទៅទីណាអ៊ីចេះ ? អានេះប្រហែលជាវាពួនសម្ងំកទ័ពទីងនៅតំបន់ណាមួយមិនខាន!

តែលោកកោធាទូលដោយឥតកង្វល់ថា:

_សូមទ្រង់ព្រះមេត្តាប្រោស, អាកែវព្រះភ្លើងនោះ ពុំអាចនឹងកទ័ពទីងបានសោះឡើយ ហើយបើមានអ្នកស្រុកចុះចូលនោះក៏មិនច្រើនដែរ ខ្លាំងណាស់មួយស្រុកម្នាក់ពីរប៉ុណ្ណោះ ! ការនេះសូមទ្រង់កុំបីព្រួយបារម្ភឡើយ អ្នកស្រុកខ្លាចព្រះអង្គណាស់ ខ្លាចសេចក្តីស្លាប់ណាស់ពុំអាចនឹងកម្រើកចិត្តគិតប្រឆាំងនឹងល្អងធូលីបានឡើយ!

ព្រះពញាអនងក់ព្រះកេសយ៉ាងល្ហើយ:

_អ៊ីចឹងមែនហើយលោក ប៉ុន្តែខ្ញុំនៅតែបារម្ភ, បានជាដូច្នោះ ពីព្រោះដូចលោកជ្រាបស្រាប់ ឈ្មោះកែវព្រះភ្លើងនេះខ្លាំងពូកែណាស់ យើងបានចាត់ការឱ្យទៅរកចាប់វានៅភ្នំដូនពេញនោះ អស់ពេលពីរដង ហើយពុំបានសោះ ឥឡូវស្រាប់តែវាលបចូលមកដល់ស្រុកយើងតែម្តង ព្រមទាំងហ៊ានសរសេរសំបុត្រផ្ញើមកខ្ញុំត្រង់ៗថែមទៀត ។ ដោយសារ

សំបុត្រនេះ ខ្ញុំយល់ថា អាកែវព្រះភ្លើងនេះពិតជាលាក់ខ្លួនពួនទៅទីណា បញ្ចុះបញ្ចូលរាស្ត្រឱ្យប្រឆាំងនឹងយើងពុំខាន !

ចំពោះរឿងនេះ ខ្ញុំយល់ថាទាល់តែយើងចាត់ការរកវាឱ្យឃើញ យកមកបំបាត់ដង្ហើមឱ្យផុតរលត់តែម្តងទៅ ទើបយើងអស់កង្វល់អស់បារម្ភ!

លោកកោធាឱនក្បាលគោរពព្រមទាំងវាចាថា:

-សូមទ្រង់កុំបីព្រួយបារម្ភឡើយ, ព្រះអង្គគឺជាតួទេវតា, ព្រះឥន្ទ ព្រះព្រហ្មចារកំណត់ឱ្យទ្រង់យាងមកគ្រប់គ្រងអាណាចក្រនេះ, ឯអាកែវព្រះភ្លើងនុះជាសត្វនរកប្រេត ! ឯពួកនរកប្រេតវាគ្មានវាសនាអ្វីនឹងផ្ចាញ់ទេវតាទេ ! ហេតុនេះ សូមទ្រង់គង់ជាសុខ ហើយមានព្រះអារម្មណ៍សប្បាយចុះ !

លោកបង្អង់បន្តិចទើបបន្តទៅទៀតថា:

-ចំណែកវិធានការរកចាប់មនុស្សនេះវិញ ទូលបង្គំនឹងចាត់ឱ្យសេនាទាហានដើរឈ្លបយកការណ៍ឱ្យបានគ្រប់ភូមិ មើលសកម្មភាពវាឱ្យតែដឹងថាវានៅកន្លែងណា យើងនឹងលើកទាហានទៅកន្ទ្រីបវាតែម្តង វាមិនអាចគេចទៅណារួចទេ !

ព្រះពញាអនពុដ្ឋច្នោះ រែបកក់ក្តៅឡើងវិញ:

-អើខ្ញុំសូមសង្ឃឹមលើលោកហើយ សូមលោកចាត់ការហ្នឹងឱ្យបានរួសរាន់ទៅ!

លោកកោធាថយទៅវិញ ចាត់ការតាមគំនិតនេះ។

ក្រោយនោះព្រះពញាអន ដែលឈ្លក់អារម្មណ៍នឹងសម្ផស្សនាងទាវ ហើយពុំទាន់បានសម្រេចបំណងស្នេហានឹងនាងនោះ ក៏បានហៅស្រីស្នំដែល រក្សានាងមកសួរថា:

-ម៉េចទៅពួកឯងរាល់គ្នា ដែលអញប្រើឱ្យលួងលោមនាងនោះ បានការម៉េចខ្លះដែរ? ល្ងាចនេះអាចនាំនាងមកឱ្យអញបានទេ?

ម៉ែវិនលើកកំបង់អញ្ជលីប្រណម្យទូល:

-ពរម្ចាស់, ខ្ញុំម្ចាស់គ្រប់គ្នាបាននិយាយលួងនាងពន្យល់នាងឱ្យព្រមស្ម័គ្រនឹងព្រះអង្គគ្រប់បែបគ្រប់យ៉ាង ប៉ុន្តែ នាងចេះតែអង្វរខ្ញុំម្ចាស់ថានាងខ្លាច ព្រះអង្គណាស់ កុំឱ្យខ្ញុំម្ចាស់នាំនាងមកថ្វាយព្រះអង្គអី!

ហើយក្រោយមក ស្រាប់តែនាងមានជំងឺគ្រុនក្តៅ សន្លប់សន្លិនតែម្តង! ឥឡូវពុំទាន់ជានៅឡើយទេ!

-យី! ម៉េចក៏អ៊ីចុះ? ហើយពួកឯងមានមើលនាង រកថ្នាំសង្កូវឱ្យនាងទេ?

-ពរម្ចាស់, ខ្ញុំម្ចាស់រាល់គ្នាកំពុងព្យាបាលនាងឥតមានធ្វេស

ប្រហែសទេ!

ព្រះពញាអន នឹកស្តាយណាស់ មិនគួរជានាងនេះភ័យរហូតដល់ទៅឈឺដូច្នោះសោះ ។ ស្តេចនេះនឹកថា មកពីខ្លួននាំនាងមកស្រឡាញ់ដោយគំហុក ប្រញាប់ប្រញាល់ពេក បើល្បួងបន្តិចម្តងៗទៅមានអី ? ធម្មតាស្រីល្អ ហើយមានប្តីទៀតផងដូច្នេះ ឯងយកមកនិយាយភ្លាមៗ ស្រឡាញ់ភ្លាមៗយ៉ាងនេះម៉េចនឹងបាន ? ហ៊ឺខុសអស់! ប៉ុន្តែមិនអីទេ ថ្មមនាងឱ្យជាខ្លួនសិន សឹមធ្វើការនេះម្តងទៀត:

_នែ, បើអ៊ីចឹងពួកឯងរាល់គ្នាជួយមើលថែទាំងនាងឱ្យបានស្រួលផង ហើយចាំនាងបានស្រួលបួលមែនទែនសឹមនាំនាងមកឱ្យអញ!

_ពរម្ចាស់!

ពួកស្នំប្រណម្យទទួលព្រះរាជបញ្ជា ហើយក្រាបថយមកវិញ ។ និយាយពីនាងទាវ តាំងពីគេបំបែកចេញអំពីប្តីនាងមក ហើយយកនាងមកដាក់នៅល្វែងស្រីស្នំនោះ នាងមានសេចក្តីទុក្ខសោកដ៏ខ្លាំងក្រៃលែង។ ពពួកស្រីស្នំបានប្រើពាក្យល្បួងលោមនាងគ្រប់បែបគ្រប់ប្រការ ឱ្យនាងលះបង់ប្តីនាងចោល ហើយឱ្យសុខចិត្តស្ម័គ្រនឹងហ្លួងម្ចាស់ផែនដីវិញ ពួកស្នំទាំងនេះនិយាយបង្ហាញហេតុផលថា បើនាងស្ម័គ្រទៅ នាងនឹងក្លាយទៅជាអគ្គមហាសីនៃព្រះអង្គ ! ប្រពន្ធស្តេចអស្ចារ្យណាស់ ប្រពន្ធ

ស្ដេចធំណាស់ ធំប៉ុនស្ដេចដែរ ! គួរតែនាងព្រមល្មមទទួល ។ ប៉ុន្តែស្រីទាវគ្រវីក្បាល ហើយអង្វរពួកស្រីទាំងនោះវិញថា : ខ្ញុំពុំហ៊ានស្រឡាញ់ព្រះអង្គទេ សូមបងៗរាល់គ្នាកុំយកខ្ញុំទៅថ្វាយព្រះអង្គអី ! ហើយបើលោកបង្ខំ ខ្ញុំនឹងសុខចិត្តស្លាប់ ព្រោះខ្ញុំពុំអាចលះបង់ប្ដីសម្លាញ់របស់ខ្ញុំបានទេ !

ស្រីទាវតែងតែនិយាយតបទៅយ៉ាងនេះ រាល់វេលាដែលគេមកលួងលោមនាងឱ្យលុះទៅតាមបំណងស្ដេចទុរយសនោះ មានស្រីស្នំម្នាក់ដែរ ដែលពុំបានធ្វើដូចគេឯទៀត ។ នាងសារិកាមានទឹកមុខព្រួយដូចនាងទាវដែរ ហើយតែងមកអើតឈ្ងោកនាងនៅឱកាសស្ងាត់ ។ ពេលមួយនោះនាងសារិកានិយាយថា :

-សូមអូនឯងតាំងចិត្តឱ្យនឹងនទៅ, កុំព្រួយខ្លាំងពេក នាំឱ្យរីតតែឈឺដុនដាបទេ !

នាងទាវតបថា :

-អ្នកបងអើយ, មិនឱ្យខ្ញុំទុក្ខព្រួយម្ដេចបាន បើប្ដីខ្ញុំដែលខ្ញុំស្រឡាញ់ស្មើជីវិតនោះ មិនដឹងជាគេយកទៅណាហើយ ? ខ្ញុំមិនដែលបែកពីប្ដីខ្ញុំសោះ ! ឱអ្នកបងអើយ ប្រហែលជាជាតិមុនខ្ញុំបានកសាងបាបកម្មពង្រាត់បង្រាស់គូរសង្សារសត្វណាមួយហើយ, បានជាជាតិនេះខ្ញុំត្រូវ

ព្រាត់ប្តីសម្លាញ់ដូច្នេះ !

នាងនិយាយយ៉ាងនេះ ទឹកភ្នែកក៏រអិលស្រក់មក ។ នាងសារិកាយកកន្សែងជូតឱ្យ រួចនិយាយទន់ចិត្តដែរ :

_ហ៊ី អូនអើយ, រូបបងវិញក៏ដូច្នេះដែរ ប្រហែលជាមានកម្មពៀរវេរាដូច្នេះដែរ........

_អូ អ្នកបងព្រាត់ប្រាស់ប្តីដូចខ្ញុំដែរ ?

_ហ្នឹងហើយ គឺមានរឿងដូចគ្នា !

_ហ៊ី ព្រះករុណានេះលោកមិនគួរកាន់ព្រះទ័យដូច្នេះសោះ !

_ហ្នឹងហើយអូនអើយ, ប៉ុន្តែនរណាឡើយនឹងហ៊ានប្រកែកទាស់បើលោកប្រើអំណាចកាប់សម្លាប់នោះ, ឥឡូវនេះបងចូលមកនេះគឺដើម្បីមកប្រាប់អូនថា : ប្តីអូននោះពុំស្លាប់ទេ សព្វថ្ងៃរស់នៅនឹងគ្រូឈ្មោះកែវព្រះភ្លើង ! សូមអូនកុំព្រួយពេក !

នាងទាវដូចជាភ្ញាក់ :

_មែនឬបង ? ម៉េចក៏បងដឹង ?

_បងដឹងដោយសារលោកមហាសេនា និង សេនាទាហាននិយាយរឿងនេះ តាំងពីមានរឿងជាដំបូង គឺគ្រាដែលគេនាំប្តីអូនទៅកាន់ទន្លេនោះ ក៏ជួបនឹងកែវព្រះភ្លើង កែវព្រះភ្លើងខ្លាំងពូកែ វាយពួកទាហាន

ឱ្យគ្រឡប់មកវាំងវិញអស់ ហើយរាល់គ្នាយល់ច្បាស់ថា គ្រូកែវព្រះភ្លើងប្រាកដជានាំប្ដីអូនទៅជាមួយហើយ ដូច្នេះ ប្ដីអូនពុំស្លាប់ទេ !

-ហ៊ឹ ខ្ញុំនៅតែព្រួយដដែល ដោយខ្ញុំនៅតែពុំបានជួបប្ដីខ្ញុំ ខ្ញុំអស់សង្ឃឹមដដែល...

-ណ្ហើយ កុំអាលអស់សង្ឃឹម, ឮថាពួកកែវព្រះភ្លើងមានគំនិតចង់រំលំស្ដេចចង្រៃនេះ ឥឡូវស្ដេចនេះកំពុងតែភ័យ ចាត់ការឱ្យគេរកកែវព្រះភ្លើងគ្រប់តំបន់ ប៉ុន្តែឮថា គេរកកែវព្រះភ្លើងពុំឃើញសោះ !

ដូច្នេះ ចូរអូនកុំអាលអស់សង្ឃឹមអី !

នាងសារិកាបាននិយាយដូច្នេះហើយ ក៏លានាងទាវថយមកវិញក្រែងស្រីឯទៀតដឹងហេតុការណ៍ ។

ចំណែកស្ដេចពញាអន មិនទាន់ហ៊ានបង្ខំនាងទាវទេ រង់ចាំឱ្យនាងបានជាស្បើយសិន ។ ដូច្នេះ ដោយសារនាងមានជំងឺនេះ នាងទាវក៏អាចគេចផុត ពីកណ្ដាប់ដៃស្ដេចល្មោភកាមនេះបាន ។

## ៨

និយាយពីគ្រូកែវព្រះភ្លើង ពេលដែលគេចផុតពីកណ្ដាប់ដៃពួកវាំងហើយ គាត់ទៅស្នាក់នៅភូមិឯកើត ។ ភូមិនោះគាត់មានសិស្សគណជាច្រើន ដោយគាត់ធ្លាប់ជួយមើលជំងឺផង ។ មានអ្នកស្រុកជាប្រធានភូមិរាប់អានគាត់ យ៉ាងស្មោះ។

កែវព្រះភ្លើងយល់ថា អ្នកស្រុកនេះអាចធ្វើជាបក្សរបស់គាត់បាន ក៏តាំងនិយាយហូរហែ អំពីការដែលគាត់មកថ្វាយបង្គំលោកគ្រូចៅអធិការ ហើយត្រូវពួកទាហានស្ដេចមករកចាប់ រួចគាត់សម្ដែងបំណងថា គាត់ត្រូវការរកទ័ពស្ម័គ្រចិត្ត ដើម្បីរំលំរបបស្ដេចចង្រៃយង់ឃ្នងនេះផង។

អ្នកប្រធានភូមិនោះឮដូច្នោះ ក៏តាំងញញឹមញញែម និយាយអះអាងថា

-ឱលោកគ្រូ លោកគ្រូមិនដឹងទេឬ ? សព្វថ្ងៃនេះអ្នកស្រុកមានការក្ដៅក្រហាយនឹងស្ដេចផែនដីនេះកាន់តែខ្លាំងឡើងហើយ ព្រោះស្ដេចនេះចេះតែឱ្យអាមាត្យ ដើរកៀរគរចាប់កូនចៅគេយកទៅធ្វើជាស្នំស្និទ្ធគ្មានសល់ម្នាក់ ។ សព្វថ្ងៃនេះឱ្យតែមានអ្នកដឹកមុខចេញមុខដឹកនាំនោះ

អ្នកស្រុកនឹងស្រុះស្រួលរួមគ្នាភ្លាម កដាទ័ពជាអីប្រឆាំងនឹងស្ដេចនេះ ប៉ុន្តែមកពីគ្មានអ្នកដឹកនាំទេ ទើបបានជារាល់គ្នាទ្រាំងនៅស្ងៀម បៀប សេចក្ដីទុក្ខទោមនស្សក្ដៅក្រហាយដូច្នេះ !

អ៎ ឥឡូវនេះស្រួលហើយ លោកគ្រូកុំអញ្ជើញទៅណា នៅនឹង ភូមិខ្ញុំនេះហើយ កដាទ័ពតូចមួយបានសឹមចេញទៅយោសនានៅភូមិឯ ទៀត !

កែវព្រះភ្លើងអរព្រើត គាត់ក៏សម្រេចសំណាក់ទៅនឹងភូមិនោះ ។ ក្រោយមក អ្នកស្រុកស្រីប្រុសបានចូលមកជួបចោមរោមគាត់សួរសុខទុក្ខ យ៉ាំងទាក់ ។

គ្រូកែវព្រះភ្លើង ដោយគាត់មានចំណេះវិជ្ជាមើលជំងឺអ្នកស្រុក ផង និង ដោយបំណងគាត់ចង់ជួយអ្នកស្រុកឱ្យផុតពីក្រញាំស្ដេចទុយស នោះផង រូបគាត់ឈ្មោះគាត់ពេលនេះធ្វើឱ្យអ្នកស្រុកស្រឡាញ់ និង គោរពដ៏ច្រើន ។

មនុស្សមួយភូមិដែលជួបគាត់មុនដំបូងនេះ ចុះចូលនឹងគាត់គ្រប់ គ្រាទាំងអស់ គាត់ដាក់ឱ្យសិស្សគាត់ម្នាក់បង្ហាត់បង្ហាញវិជ្ជាយុទ្ធសាស្ត្រ ។ រួចគាត់ចេញដំណើរទៅភូមិមួយទៀត ។ ភូមិណាដែលគាត់ចូលដល់ ភូមិ នោះរមែងអបអរសាទរចំពោះគាត់ដ៏ក្រៃលែង សុទ្ធតែនិយាយថា : បាន

លោកគ្រូអញ្ជើញមក យើងខ្ញុំមានសេចក្ដីសប្បាយណាស់ ព្រោះលោកគ្រូបានជួយមើលជំងឺអ្នកភូមិយើងខ្ញុំ ហើយបានមកដឹកនាំយើងខ្ញុំឱ្យរួបរួមគ្នា ! យើងខ្ញុំពេញចិត្តណាស់នឹងការរួបរួមគ្នានេះ ព្រោះយើងត្រូវការងើបឡើងប្រឆាំងនឹងស្ដេចពាលនេះយូរហើយ យើងខ្វះតែអ្នកដឹកនាំប៉ុណ្ណោះ ! ឥឡូវនេះយើងពិតជាបានសម្រេចបំណងហើយ ដោយសារបានលោកគ្រូមកជួយដឹកនាំ!

លោកគ្រូកែវព្រះភ្លើងមានប្រជាប្រិយភាពដ៏សម្បើម ធ្វើដំណើរទៅភូមិណាភូមិនោះអបអរសាទរ ទទួលរាក់ទាក់អញ្ជើញឱ្យស្នាក់អាស្រ័យ រួចស្មគ្រចិត្តបំរើក្នុងកងទ័ពយ៉ាងរីករាយ ។ ភូមិនីមួយៗ គាត់ឱ្យសិស្សគណជួយបង្ហាត់បង្រៀន ឱ្យអ្នកស្រុកឱ្យបេះកាត់អាវុធសម្រាប់ប្រយុទ្ធយ៉ាងម៉ត់ចត់ ។ ពញាចីចិញ្ចឹមចិត្តថានឹងទៅសងសឹក ពិឃាតពួកសត្រូវវិញខានមិនបាន។

ក្រោយនោះ គ្រូកែវព្រះភ្លើងនឹកដល់លោកគ្រូចៅអធិការវត្តបាសាណ ក៏បាននាំសិស្សគណមកថ្វាយបង្គំ ដើម្បីនឹងបានប្រគេនពត៌មាន:

-ព្រះតេជគុណ ខ្ញុំករុណាបានទូលព្រះតេជគុណពីពេលមុនមកហើយ គឺខ្ញុំករុណាសម្រេចថា នាំរាស្ត្រទៅទម្លាក់ស្ដេចពាលនោះតែម្ដង!

ការណ៍នេះ ខ្ញុំករុណារៀបចំស្រេច ហើយរង់ចាំតែពេលវេលាទេ !

លោកគ្រូចៅអធិការសម្តែងសេចក្តីថប់បារម្ភៈ

_ហ៊ឺ អាញ្ជួយព្រួយភ័យឯងណាស់, ពីព្រោះកងទ័ពហ្លួងមាន ចំនួនច្រើន ម្យ៉ាងទៀតគេមានមធ្យោបាយគ្រប់សព្វ រទេះ សេះ ដំរីស្អី ៗ សម្រាប់បង្ក្រាបយើងវិញ អាញជឿលើទឹកចិត្តក្លៀវក្លាប្តូរផ្តាច់របស់ឯង ហើយ ប៉ុន្តែអាញចេះតែមានសេចក្តីបារម្ភ !

កែវព្រះភ្លើងញញឹមទូលវិញថា

_មិនអីទេព្រះតេជព្រះគុណ, ខ្ញុំករុណាសព្វថ្ងៃបានពឹងលើប្រជារាស្ត្រនៅតំបន់នេះទាំងមូល ។ បើនិយាយពីចំនួនវិញ រាស្ត្រយើងមានច្រើនជាងទាហានវាំងយ៉ាងលើសលុប ប៉ុន្តែ ខ្ញុំករុណាពុំចង់ឱ្យរាស្ត្រចេញមុខទល់នឹងទាហានប៉ុន្មានទេ ព្រោះយល់ថា នាំឱ្យស្លាប់រាស្ត្រអត់ប្រយោជន៍ ខ្ញុំករុណាគិតថា នឹងជួមខ្លួនចូលឱ្យបានទៅក្នុងវាំងជាមួយគ្នីគ្នាបួនដប់នាក់ ហើយឯទ័ពប្រជារាស្ត្រវិញទុកនៅក្រៅ សម្រាប់បញ្ឆោតពួកវាំងតែប៉ុណ្ណោះ ។ បើមានការប្រកាប់ប្រចាក់គ្នានោះ ក៏ពុំសូវស្លាប់ដែរ ព្រោះយើងនៅពីក្រៅ ។ ខ្ញុំករុណាដឹងដែរថាប្រាកដជាមានការប្រយុទ្ធគ្នាយ៉ាងធំ ហើយត្រូវការកម្លាំងរាស្ត្រជាសំខាន់ ហេតុនេះទើបខ្ញុំករុណាក៏ចាត់កម្លាំងរាស្ត្រជាសំខាន់ ហេតុនេះ ទើបខ្ញុំករុណា

ក៏បានចាត់ឱ្យបង្ហាត់បង្ហាញដែរនូវវិជ្ជាយុទ្ធសាស្ត្រ ចំពោះបងប្អូនយើងទាំងនោះ ដូច្នោះបងប្អូនយើងទាំងនោះ ទោះបីប្រឈមមុខទល់ជាប់នឹងសត្រូវក៏មិនមែនអន់ថយឱ្យសត្រូវសម្លាប់បានដោយងាយៗទេ ! ហេតុនេះខ្ញុំករុណាដូចជាមានសង្ឃឹមច្រើនក្នុងរឿងនេះ ! ម្យ៉ាងទៀត ប្រជាជនបងប្អូនយើងគ្រប់គ្នាគេកំពុងចង់ខ្លាំងណាស់ ក្នុងការទៅទម្លាយកំពែងវាំង ចាប់ស្តេចពាលនោះយកមកកាត់ទោស ! ដូច្នេះរឿងខ្ញុំករុណាប្រាជកជានឹងចេះតែទៅមុខហើយ គ្មានការថយក្រោយវ្លញវាទេ....

_អើ អញក៏សូមប្រសិទ្ធិពរម្តងទៀត ឱ្យកែវឯងមានជោគជ័យដូចប្រាថ្នា។

កែវព្រះភ្លើង ថ្វាយបង្គំលាលោកចុះមកវិញ គ្រាដែលចុះមកវិញនោះ គាត់ឃើញមនុស្សម្នាក់ជិះសេះចេញពីគុម្ពប្ញស្សីត្រង់ខាងលិចវត្តឆ្ពោះទៅទិស ខាងត្បូងវឹងតែម្តង។

កែវព្រះភ្លើងឃើញដូច្នោះ ប្រើនាយសុខ និង សិស្សឯទៀតពីរនាក់ភ្លាម

_នែ នាំគ្នាតាមមនុស្សនោះភ្លាម !

សេះទាំងបីបានស្ទុះវឹងទៅ សំដៅទៅទិសដែលមានមនុស្សគេចចេញទៅនោះ។

សូមជ្រាបថា កងទ័ពប្រជារាស្ត្រ របស់កែវព្រះភ្លើងក៏មានសេះដែរ ។ សេះទាំងនោះជារបស់អ្នកស្រុក ។

កែវព្រះភ្លើងរង់ចាំមើលលទ្ធផល មួយសន្ទុះក្រោយមក ឃើញអ្នកទាំងបីត្រឡប់មកវិញដោយនាំទាំងមនុស្សម្នាក់មកផង ។ នាយសុខទម្លាក់មនុស្សនោះពីខ្នងសេះនៅចំពោះមុខគ្រូកែវព្រះភ្លើង ដោយជម្រាបថា:

_លោកគ្រូ អានេះហើយវាបរសេះចេញទៅអម្បាញ់មិញ វាមានគ្នាពីរបីនាក់ទៀត នៅឈ្លបពួនត្រង់ខាងត្បូងវត្តឯណោះ ! ខ្ញុំបាទចាប់បានតែអានេះ ចំណែកអាឯទៀត រត់បំផាយសេះរួចអស់ !

គ្រូកែវព្រះភ្លើងមើលទៅមនុស្សនោះ ដែលមានទឹកមុខស្លេកស្លាំង ដោយមានភ័យ ។ គាត់សួរថា:

_នែ ឯងជាទាហានវាំងឬ? ឯងមករកអី ?

មនុស្សនោះលើកដៃសំពះយ៉ាងញ័រ:

_បាទទាន, លោកអគ្គមហាសេនាប្រើឱ្យមកឈ្លបយកការណ៍អំពីអស់លោកខាងណេះទាន !

_នែ ឯងមកស៊ើបនេះមានគ្នាប៉ុន្មាននាក់ ?

_បាទមានតែបីនាក់ទេទាន ! ដូចលោកខាងណោះទៅទាន់

ឃើញស្រាប់ (វាចង្អុលទៅនាយសុខផង) ។

កែវព្រះភ្លើងញញើមដោយរាប់អានទៅកាន់ទាហាននេះ ហើយសួរដោយសម្លេងស្រាលៗថា ៖

_រ៉ែ បើលោកមហាសេនារបស់ឯងដឹងថាអញនៅកន្លែងនេះ ប្រហែលជាលោកគិតនាំទាហានមកគ្រញឹចចាប់អញតែម្តងហើយ មែនទេ ?

_បាទទាន ប្រាកដជាអ៊ីចឹងហើយ !

_អើ, ឯងប្រាប់អញឱ្យត្រង់តទៅទៀតបានទេ ?

_បាទ ទានបាន ... សុំតែលោកមេត្តាកុំសម្លាប់ខ្ញុំបាទ សុំទុកជីវិតខ្ញុំបាទ !

_អើមិនអីទេ អញទុកជីវិតឱ្យ .... អើតើឯងមានបងប្អូន សាច់សារលោហិតអីនៅក្នុងស្រុកនេះទេ ?

_បាទមាន ប៉ុន្តែ គ្រួសារខ្ញុំបាទនៅឯភូមិខាងត្បូងរាជធានីឯណោះទាន

_គ្រួសារឯងត្រូវស្តេចរបស់ឯងប្រោសប្រណីម៉េចដែរ ? ហើយលោកមហាសេនារបស់ឯងរាប់រកម៉េចទៅដែរ ?

ទាហាននោះស្រាប់តែមានទឹកភ្នែកហូររហាម ហើយនិយាយ

ពុំរួច ។ ឯពួកក្មេងវត្ត និង លោកសង្ឃឯទៀត ក៏ឈរចោមរោមជុំវិញអ្នកទាំងអស់នេះដែរ ដោយចង់ដឹងរឿងរ៉ាវផ្សេងៗជាធម្មតា ។ គ្រូកែវព្រះភ្លើងសួរទៀតថា:

-អញចង់ដឹងថា គ្រួសាររបស់ឯង បានទទួលសេចក្ដីសុខអំពីហ្លួងរបស់ឯងទេ ? ម៉េចក៏ឯងមិននិយាយ ?

-ឱទានប្រោស គ្រួសារខ្ញុំបាទកំពុងខ្វោចផ្សាណាស់ ពីព្រោះប្រពន្ធខ្ញុំបាទនោះ ត្រូវព្រះករុណាជាអម្ចាស់ជីវិតលើត្បូង លោកសព្វព្រះទ័យឱ្យគេនាំយកទៅធ្វើស្នំព្រះអង្គកាលពីប៉ុន្មានខែមុននេះ ! ឥឡូវនេះពុំទាន់បានរួចចេញពីវាំងនៅឡើយទេទានប្រោស ! ខ្ញុំបាទក៏ស្ដេចឱ្យធ្វើទាហានរហូតមក ហើយមិនដែលឱ្យខ្ញុំបានជួបនឹងប្រពន្ធសោះឡើយ !

-អើ ចុះឯងមានការឈឺចាប់ទេ ?

-បាទទាន ខ្ញុំបាទនឹកក្ដៅក្រហាយណាស់ ប៉ុន្តែមិនដឹងធ្វើម្ដេច ? ព្រោះថា ឱ្យតែហ៊ានសំដែងឬកពាថាមិនសប្បាយចិត្តភ្លាមនោះ ស្ដេចនឹងឱ្យគេយកទៅ កាត់ក្បាលចោលភ្លាម គ្មានចាំដេញដោលទេទានប្រោស !

-ហ៊ឹស, ស្ដេចឯងសាហាវណាស់ ... បើអ៊ីចឹងឯងនៅតែគោរពស្រឡាញ់ស្ដេចនោះទៀតឬ ?

-ទេ ទេ ម្ចាស់ថ្លៃអើយ, ខ្ញុំគ្មានស្រឡាញ់គ្មានស្អប់បន្តិចសោះហើយ!

ចង់គេចបេញដែរ ប៉ុន្តែមិនដឹងថាទៅជ្រកនៅនឹងអ្នកណា!

-បើអ៊ីចឹងមកនៅនឹងក្រុមរបស់អញទៅបានទេ ? អញអាចទទួលឯងបាន!

ជនជាប់ជាឈ្លើយនោះ ស្រាប់តែញញឹមញញែម:

-បាទទាន, បើលោកម្ចាស់មេត្តាឱ្យខ្ញុំបាទជ្រក ខ្ញុំបាទអរណាស់ទាន....

-អើ ឯងឈ្មោះអី?

-បាទទាន ខ្ញុំបាទឈ្មោះសេក!

-អើ, ប៉ុន្តែយើងត្រូវរួមគ្នាកំចាត់ស្ដេចពាលនោះចោល តើឯងពេញ ចិត្តទេ?

បុរសឈ្មោះសេកបើកភ្នែកធំៗ:

-ទេលោកម្ចាស់, ក្រែងពុំកើតទេដឹង ដ្បិតស្ដេចនោះមានសេនាទាហានច្រើនណាស់ ហើយកាចសាហាវណាស់ផង មើលទៅយើងពិបាកនឹងទល់ណាស់!

-យើងក៏មានទាហានច្រើនគួរសមដែរ មិនអត់ទេ ប៉ុន្តែអញពុំត្រូវការឱ្យទាហានយើងទៅបង្ក្រាបពួកវាំងនោះទេ អញគ្រាន់តែឱ្យទៅទ្បោមព័ទ្ធវាំង ហើយធ្វើការវាយប្រហារបន្តិចបន្តួចប៉ុណ្ណោះ ចំពោះតួ

ស្តេចនោះវិញ គឺខ្លួនអញតែម្តងដែលត្រូវចូលទៅប្រយុទ្ធតទល់.... ឱ្យតែចាប់ស្តេចបាន អាវុធប៉ុន្មាននឹងធ្លាក់ឯងៗ ពីដៃសេនាទាហានពុំខាន!

អើ ចំណែកឯង ចាំអញប្រើការផ្សេងទៀត .... ប៉ុន្តែឥឡូវត្រូវទៅជម្រំយើងសិន ។ ទៅ! វាល់គ្នាទៅវិញ!

ទាំងអស់គ្នាក៏ឱនក្បាលបន្តិចៗ គោរពបញ្ជានេះ ។

នាយសេកជនជាប់ជាឈ្លើយនេះ ក៏បោះជំហានទៅតាមគេដែរ។

និយាយពីលោកកោធា.... គឺក្នុងបំណងចង់ដឹងសកម្មភាពរបស់កែវព្រះភ្លើងយ៉ាងម៉េចខ្លះ នៅឯណាខ្លះដូច្នោះហើយបានជាគាត់ប្រើនាយទាហានឱ្យដើរស៊ើបអង្កេតគ្រប់ស្រុកភូមិ ។

លោកកោធាត្រូវរង់ចាំស្តាប់ដំណឹងគ្រប់ទីដែលលោកចាត់ទៅ ។ គ្រានោះ លោកឃើញសេនាពីរនាក់ ចូលមកដោយអាការត្រហេបត្រហប លោកប្រញាប់សួរឡើង :

_ម៉េចទៅអាសាន និង អាខែ្វ បានការយ៉ាងម៉េចខ្លះ ? ហើយឯណាមិនឃើញអាសេក ?

នាយសានឆ្លើយទាំងដង្ហក់ថា :

_បាទទាន អាសេក ពួកកែវព្រះភ្លើងចាប់បានទៅហើយទាន!

_ស្អី? អាសេកត្រូវពួកអាកែវព្រះភ្លើងចាប់បាន? វាច្រឡំចូល

ទៅក្នុងកន្លែងកែវព្រះភ្លើងឬ ? កន្លែងអាកែវព្រះភ្លើងនៅម្ដុំណា ? និយាយឱ្យហួរហែទៅមើល?

-បាទទាន កន្លែងអាកែវព្រះភ្លើងនោះប្រហែលជានៅម្ដុំវត្តទួលបាសាណនោះហើយ ព្រោះខ្ញុំរាល់គ្នាឃើញពួកវាចូលទៅវត្តនោះ ឯអាសេកវាលបចូលទៅខាងក្រោយវត្តនោះ ដើម្បីពិនិត្យឱ្យច្បាស់ ស្រាប់តែពួកវាដឹង ក៏ដេញតាមមក ចាប់អាសេកបានទៅទាន!

លោកកោធាងក់ក្បាល:

-ហ៊ឺះ គួរឱ្យស្ដាយអាសេកណាស់ ឱ្យវាចាប់បាន ប៉ុន្តែណ្ហើយ មិនអីទេ តែប៉ុណ្ណេះយើងក៏ដូចជាមានផ្លូវស្រេច អើយើងត្រូវតែលើកទ័ពទៅរកវាពេលរសៀលនេះ ! អើបើរកវាពុំឃើញទេ យើងត្រូវចាប់លោកគ្រូចៅអធិការវត្តទួលបាសាណមកសួរចម្លើយ រួចឱ្យនាំទៅបង្ហាញកន្លែងវា ! អើឯងទៅសម្រាកសិនទៅ ពេលរសៀលយើងលើកទ័ពទៅ!

-ប្របាទទាន!

សេនាពីរនាក់នោះឆ្លើយ របៀបស្របសម្លេងគ្នា គោរពលាចេញទៅ។

ពេលក្រោយនោះ លោកកោធាហៅនាយទ័ពមកបង្គាប់ឱ្យរៀបចំពលដើម្បីឆ្ពោះទៅវត្តទួលបាសាណនៅពេលរសៀលនេះ ។ រួចហើយ

លោកក៏ប្រុងប្រៀប ហៀបនឹងឡើងគាល់ព្រះពញាអនជាម្ចាស់ជីវិតរបស់លោក ដើម្បីនឹងទូលការណ៍នេះឱ្យទ្រង់ជ្រាបផង ។ លោកហៀបនឹងចេញពីបន្ទប់ទៅ ស្រាប់តែលាន់កុបៗ សេះមួយបោលមកឈប់, នាយសេកដែលលោកកំពុងនឹកស្ដាយនោះ លោតចុះពីលើសេះ ឱនក្បាលគោរពក្នុងកិរិយាធេងធោង ហេវហត់ ។ លោកកោធាអរណាស់ :

-យីងអាសេក, អាឯងរត់រួចមកវិញហើយ ! អញស្មានតែវាសម្លាប់អាឯងបាត់ទៅហើយ! អើម៉េចក៏ឯងរង់រួច ?

នាយសេកយកដៃអាវជូតញើសនៅថ្ងាស រួចជម្រាបនាយចៅហ្វាយនេះថា :

-ប្របាទទាន, គឺជាសំណាងរបស់ខ្ញុំបាទណាស់ ប៉ុន្តែ មកពីខ្ញុំបាទចេះរកឧបាយឃើញ ខ្ញុំបាទធ្វើជាចូលដៃនឹងវា បើកុំតែបានគិតដូច្នោះ កុំអីខ្ញុំបាទត្រូវវាកាត់កស្រេចទៅហើយទាន !

-អើសំណាងឯងខ្លស់ណាស់ ! មើលឯងនិយាយឱ្យសព្វគ្រប់ទៅមើល វាឱ្យឯងទៅធ្វើអ្វីខ្លះ ? ឯងដឹងទីកន្លែងវាច្បាស់ទេ ?

នាយសេកនិយាយលះៗ សម្លេងថា :

-បាទទាន, វាចាប់ខ្ញុំបាទហើយ អាមេវានោះសួរដេញដោលខ្ញុំបាទ ហើយចោទព្រះតេជព្រះគុណឯណោះ ព្រមទាំងព្រះករុណាជា

អម្ចាស់ជីវិតយើងផង ថាឃោរឃៅ, ថាអាក្រក់... ហើយវាបញ្ជាក់ខ្ញុំបាទមែនឬទេ ? ខ្ញុំបាទនឹកថាត្រូវតែឆ្លើយថាអាក្រក់ឃោរឃៅទៅចុះ ដើម្បីឱ្យវាទុកជីវិតមួយគ្រាសិន ខ្ញុំបាទធ្វើជានិយាយថា ពុំចង់នៅវាំងនេះផងទេ ! ពុជ្ឈូប្បេះវាអរណាស់ ក៏បបួលខ្ញុំបាទឱ្យចុះចូលនឹងវា ខ្ញុំបាទក៏ធ្វើជារីករាយព្រមព្រៀងភ្លាម ! វាចោតណាស់ វាជោរណាស់ ក៏នាំខ្ញុំបាទឱ្យទៅកាន់ដំរំវា បង្ហាញពួកពលវាឱ្យខ្ញុំបានឃើញផង !

លោកកោធាញញឹមសួរកាត់ :

_គ្រាន់បើ ឥឡូវឯងស្គាល់កន្លែងវាច្បាស់ហើយឬ ? វានៅត្រង់ណា ? ពីមុននេះគ្នារបស់ឯង២នាក់មកប្រាប់អញថា វានៅម្តុំវត្តទួលបាសាណ ហើយអញក៏កំពុងប្រុងប្រៀបរៀបពលទៅទីនោះផង ព្រមទាំងគិតទៀតថាបើរកវាពុំឃើញទេ អញនឹងចាប់លោកសង្ឃនោះយកមកឱ្យប្រាប់តែម្តង !

_បាទទាន, ថាកន្លែងវានៅម្តុំទួលបាសាណនោះក៏ត្រូវដែរ ប៉ុន្តែដែលប្រាកដប្រជាច្បាស់លាស់ សំបុកទីចាត់ការធំរបស់វាគឺនៅភូមិខាងកើតវត្តឯណោះទេ ! ខ្ញុំបាទស្គាល់កន្លែងនោះច្បាស់ ចាំទាំងផ្លូវថែមទៀត ផ្លូវនោះ ត្រូវកាត់មុខវត្ត ចូងអូរមួយទៅខាងកើត !

_អើល្អ ! គ្នាច្រើនឬ?

_បាទទានគួរសមដែរ! ហើយមើលទៅបែបចេះក្បួនប្រយុទ្ធផង!

_ប៉ុន្តែមិនជាអ្វីទេ ដឹងកន្លែងវាដូច្នេះស្រួលណាស់ យើងគ្រាន់តែលើកគ្នាមួយកងធំទៅសង្កត់មួយព្រឹបទៅ វារលាយខ្យល់ទៅហើយ! អើ តើវាដឹងថាឯងរត់រួចមកទេ? ឯងធ្វើម៉េចបានរត់រួច?

នាយសេកញញឹម:

_បាទទាន ការណ៍នេះខ្ញុំបាទនឹកសរសើរសំណាងខ្លួនឯងតែម្ដង ចេះរកឧបាយកុហកវាឃើញ!

ខ្ញុំបាទមុនដំបូងនឹកឃើញថា សេះរបស់ខ្ញុំបាទនោះត្រូវរបូតទៅត្រង់ខាងត្បូងវត្ត ខ្ញុំបាទប្រថុយនិយាយនឹងមេវានោះថាសេះខ្ញុំល្អណាស់ កាលដែលអស់លោកទៅចាប់ខ្ញុំមកនោះ សេះខ្ញុំរបូតទៅ ឥឡូវស្ដាយសេះនោះណាស់ សូមអស់លោកមេត្តាជួយខ្ញុំទៅរកចាប់សេះនោះមកវិញផង ទុកប្រើការទៅថ្ងៃក្រោយ អាមេនោះស្រាប់តែឱ្យកូនចៅវាពីរនាក់ជូនខ្ញុំបាទច្លងអូរមុខវត្តត្រឡប់មកវិញ!

លុះមកដល់ខាងលិចវត្តជាទីស្ងាត់ហើយ ខ្ញុំបាទក៏តាំងកាប់ខ្វាប់ទៅលើអាម្នាក់នោះដួលប្រួសមួយរំពេច ... អាម្នាក់ទៀតភ្ញាក់ស្រឡាំងកាំង ហៀបតែនឹងហូតដាវខ្ញុំបាទក៏ព្រលែងមុនមួយចុងដាវព្រួក! វាកោងខ្នងចូលចុះទៅដែរ ខ្ញុំបាទឥតបង្អង់ទេ រត់ភឹងមួយរំពេចមកខាងត្បូង ...

ជាសំណាងដែរ សេះខ្ញុំបាទនៅនោះឥតទៅណា ខ្ញុំបាទដែលភ្លាមបំបោលក្លួងមកតែម្តង!

លោកកោធាញញឹមពេញចិត្ត

_មើលទៅ, ពួកវាកំពុងតែរកឯងសម្បើមណាស់ហើយ ! អញគិតលើកទ័ពនៅពេលរសៀលនេះ ឥឡូវស្រួលណាស់ បើឯងដឹងកន្លែងវាដូច្នេះ ឯងត្រូវនាំអញទៅ! ប៉ុន្តែយើងត្រូវចូលទៅគាល់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូងសិន ដើម្បីទូលព្រះអង្គបានទ្រង់ជ្រាបផង!

ទាំងពីរនាក់នាំគ្នាឡើងទៅកាន់ដំណាក់ព្រះរាជា ព្រះពញាអនពេល នោះទ្រង់ក៏ទើបតែតើនឡើងបន្ទាប់ពីផ្ទុំថ្ងៃ។

លោកកោធាក៏ប្រញាប់ទូលថា :

_សូមទ្រង់ព្រះមេត្តាប្រោស, ពេលបន្តិចទៀតនេះទូលបង្គំជាខ្ញុំព្រមទាំងកងទ័ពនឹងលើកទៅចាប់ពួកអាកែវព្រះភ្លើងហើយក្រាបទូល!

_ ស្អី? លោកស្គាល់កន្លែងវាហើយឬ?

_ព្រះករុណាថ្លៃវិសេស, អ្នកស៊ើបការណ៍នេះ (គាត់បង្ហាញរូបនាយសេក) បានទៅផ្ទាល់ដល់ទីកន្លែងវាផង បានដឹងសព្វគ្រប់!

_អើ, នៅត្រង់ណាទៅ? មានរាស្ត្រចូលដៃឬ?

_ព្រះករុណាថ្លៃវិសេស, នៅភូមិមួយស្ថិតនៅខាងកើតវត្តទួលបា

សាលា មានរាស្ត្រចូលដៃផង !

_អ៊ុចឹងស្រួលហើយ យើងទៅក្រសោបវាទាំងមូលតែម្តង ក្រប៉ែល វាកុំឱ្យសល់ ! ស្អី ? វាហ្នឹងស្អី ? ពួករាស្ត្រចូលដៃនោះស្អី ? វាមិនដឹងថា ខ្ញុំជាអម្ចាស់ជីវិតលើត្បូងទេឬ ? វាមិនដឹងថាខ្ញុំគឺជាតួទេវតាចុះមកពី ស្ថានសួគ៌ទេឬ ? លោកត្រូវតែទៅប្រដៅពួកនេះឱ្យដឹងដៃ ! ហើយ ឱ្យរាស្ត្រឯទៀតៗបានដឹងផង កុំឱ្យយកតម្រាប់ពួកអាព្រហើនទាំងនោះ ! លោកទៅចុះ !

លោកកោធាត្រឡប់ចុះមកវិញ, ហើយប្រាប់លោកមហាមន្ត្រី ឱ្យនៅថែរក្សាវាំង រួចលោកក៏ស្លៀកពាក់ជាមេបញ្ជាការសឹកយ៉ាងសង្ហា។ កងពលបានរៀបរង់ចាំលោកជាស្រេច ។ លុះបានរបៀបរៀបរយហើយ លោកក៏បញ្ជាឱ្យលើកចេញមួយរំពេច ។ កងពលសេះ និង ពលថ្មើរ ជើងបានចេញដំណើរយ៉ាងគគ្រឹក ដ៏មានអាវុធប្រូងប្រាងចាំងតទៅនឹង ពន្លឺថ្ងៃពេលរសៀលឃើញព្រាតៗ ។

ធ្វើដំណើរបណ្តើរ លោកនិយាយទៅកាន់នាយទ័ពបណ្តើរថា:

_យើងត្រូវលើកទាហានទៅវាយព័ទ្ធវាឱ្យជុំវិញតែម្តង រួចវាយ ក្រសោបចូលបន្តិចម្តងៗ លុះត្រាតែវាមូលគ្នា សឹមយើងចូលចាប់គ្រញិចវា ...ពួកអាប្រេតនរកអស់នោះគ្មានដឹងស្អីទេ !

_បាទទាន    ប៉ុន្តែខ្ញុំបាទខ្លាចតែពួកវាពុំបាននៅមូលត្រកូលគ្នា ខ្លាចតែវានៅឯណោះម្ដុំចាំវាយប្រហារយើង ! ម្យ៉ាងទៀត វាមុខជាបាន ដឹងខ្លួនមុនពុំខានទេ ព្រោះបាត់អាសេកមក វាប្រាកដជាដឹងថានាយ សេកបាននិយាយប្រាប់យើងអំពីទីកន្លែងវាហើយ ដូច្នេះ វាមិនអាចនៅ ទីងកន្លែងដដែលទេ !

_អ៊ីចឹងមែនហើយ ប៉ុន្តែ វាពុំអាចរើបន្ទាយដឹកជញ្ជូនស្បៀង និង អាវុធទៅណាទាន់ទេ ហោចណាស់ ក៏យើងបានកម្ទេចបន្ទាយ វាយ ដណ្ដើមយកឃ្លាំងស្បៀងវាដែរ ហើយចំណែកជីវិតវានោះ យើងត្រូវតែ តាមរកជាបន្តៗទៅទៀត កាប់សម្លាប់ចោលជាបន្តទៅទៀត....

អើ កាប់មែកកាប់ធាងរាល់ថ្ងៃ លែងអីនឹងបានដើមមកធ្វើឱស ទៀត ? កុំទៅព្រួយ អាកែវព្រះភ្លើងគ្មានហោះទៅណារួចទេ !

បរទ័ពបណ្ដើនិយាយបណ្ដើរ លុះត្រាតែដល់វត្តទួលបាសាណ ឯថ្ងៃក៏កាន់តែទាបជិតលិចទៅហើយ ។ លោកកោធាសួរទៅនាយសេក :

_នែ ផ្លូវកាត់នៅត្រង់ណា ?

_បាទទាន ច្លងអូរទៅខាងកើត ប៉ុន្តែ សូមព្រះតេជព្រះគុណ ឱ្យកងពលចុះទៅក្នុងអូរ ធ្វើដំណើរតាមបណ្ដោយអូរនេះឆ្ពោះទៅជើង សិន !

លោកកោធាងឿងឆ្ងល់ :

_ម៉េចក៏ដូច្នោះ ក្រែងឯងថាភូមិនោះនៅខាងកើតអូរឬ ? ម៉េចក៏មិនច្លងទៅកើតតែម្ដងទៅ ? ម៉េចចាំបាច់ទៅខាងជើងឯណោះវិញ ? ហើយបើទៅខាងណា ។ ម៉េចក៏ចាំចុះដើរក្នុងអូរ ? ម៉េចមិនធ្វើដំណើរតាមមាត់អូរឯលើឯណោះទៅ ?

_បាទទាន, បើព្រះតេជគុណទៅចំត្រង់កន្លែងវាតែម្ដង ធ្វើម៉េចនឹងបានព័ទ្ធវា ខ្ញុំបាទឱ្យនៅខាងជើងដូច្នេះ ព្រោះថាយើងបានព័ទ្ធវាខាងជើង កុំឱ្យវាច្លងចូលទៅក្នុងព្រៃទាន់ ព្រៃខាងជើងនោះក្រាស់ណាស់ យើងពិបាករុករកវាណាស់ បើវាច្លងផុតព្រៃនោះ ។ ខ្ញុំបាទយល់ថាយើងគួរកៀងវាមកឱ្យធ្លាក់អូរនេះ នៅទីបញ្ចប់ស្រណុកយើងបាញ់ចម្រុះវាឱ្យវិនាសតែម្ដង !

លោកកោធាស្ដាប់ទៅបែបសមរម្យក៏ងក់ក្បាល :

_អើ, ឯងនិយាយត្រូវម្យ៉ាងដែរ, ប៉ុន្តែ ម៉េចបានចាំឱ្យគ្នាយើងធ្វើដំណើរតាមជ្រលងអូរនេះដូច្នេះ ? បើដើរដូច្នេះ លោកតែសត្រូវលបខ្ទប់បាញ់ចម្រុះមកយើងមិនស្លាប់ហើយ ? តទល់ម្ដេចនឹងបាន ? បើតាមអញ អញថាត្រូវដើរលើមាត់អូរទៅជាការល្អ ស្រណុកមើលនាយអាយឃើញ !

នាយសេកឱនក្បាលគោរពតបថា:

_បាទទាន បើព្រះតេជគុណនាំដើរតាមមាត់អូរនោះ សម្រេចទៅចុះ ប៉ុន្តែ មកពីខ្ញុំបាទយល់ថាការដើរលើមាត់អូរនោះ វាគគ្រឹកគគ្រេងសម្បើមណាស់ ហើយអ្នកស្រុក ឬ ក៏សត្រូវវាមើលមកក៏ឃើញច្បាស់ផង បើយើងចុះដើរតាមជ្រលងអូរនោះវិញ ដំណើរយើងបានស្ងប់ស្ងួល មិនផ្អើលភ្ញាក់ដល់សត្រូវ ព្រោះវាមើលមកពីនាយពុំបានឃើញសកម្មភាពក្បួនទ័ពយើងទេ យើងអាចដើរបានវែងឆ្ងាយរហូតដល់ទីដៅ!

លោកកោធាវេរាបន្តិច មើលទៅមុខនាយទ័ពក្នុងទំនងពិគ្រោះ។ នាយទ័ពនឹកឃើញថាគំនិតរបស់សេកល្អដែរ ក៏ជម្រាបថា:

_មែនហើយព្រះតេជព្រះគុណ, យើងដើរលើនេះគគ្រឹកគគ្រេងសម្បើមណាស់ បើយើងលបចុះដើរតាមចង្អូរនេះវិញស្រួលណាស់ គ្មាននរណាមើលឃើញទេ!

_អើ, បើអ៊ីចឹងយើងចុះធ្វើដំណើរតាមជ្រលងអូរនេះទៅ ហើយកុំមាត់ឡូឡាឱ្យសោះ កុំឱ្យសត្រូវភ្ញាក់ផ្អើល!

កងទ័ពទាំងអស់ក៏តាំងចុះពីលើមាត់អូរ មកក្នុងជ្រលងអូរ ហើយធ្វើដំណើរទៅមុខដោយស្ងប់ស្ងៀម។

ធ្វើដំណើរតាមជ្រលងអូរនោះអស់មួយស្របក់ធំ ពេលនោះ

ព្រលប់ព្រឹលៗទៅហើយ លោកកោធាសួរទៅនាយសេក :

-នែ, ល្មមដល់ទីដែលត្រូវឡើងទៅព័ទ្ធវាហើយឬនៅ ? ដើរៗតិច លោកជុតទៅ !

-បាទទាន, ជិតដល់កន្លែងឡើងហើយ នៅតែបន្តិចទៀតដល់ហើយ ! ន៎ ព្រៃម្ដុំខាងមុខនោះ ដែលយើងត្រូវលបឡើងទៅព័ទ្ធវា !

កងទ័ពទៅទន្ទឹមនឹងព្រៃនោះ លោកកោធាហៀបតែបំបែរក្បាលទ័ពឡើងលើមាត់អូរស្រាប់តែលាន់រ៉ឺៗ ! ឈើបៗសម្រែកអូយៗក៏លាន់ឡើង ទាហានពីរបីនាក់ធ្លាក់ពីលើសេះភ្លាម ព្រួញហោះពីព្រៃទាំងសងខាងចម្រុះមកលើទាហានថែមទៀតធ្លាក់ខ្លោកៗ លោកកោធាទៅជាស្រឡាំងកាំង បញ្ជាទ័ពឱ្យកងទ័ពបាញ់សងទៅវិញ ប៉ុន្តែ សម្រែកមនុស្សដែលច្នក់នោះ បានស្រែកឡើងគគ្រឹករញ្ជួយព្រៃតែម្ដង :

-ចូល ! ពួកយើងចូល វាចូលក្នុងស៊ងយើងហើយលះទៅ !

ស្រាប់តែកងទ័ពអ្នកស្រុក លោតចុះមកពីមាត់អូរព្រោងព្រាតកាំបិត ពូថៅ ដាវ លំពែង ស្ទុះចូលមកកាប់ទាហានវាំង ទាហានវាំងភាំងវង្វេងច្រួលច្របល់ ត្រូវពួកអ្នកស្រុកសម្រុកចូលកាប់ឥតប្រណីស្រែករំពងដោយឈឺចាប់ ខ្លះក៏ស្លាប់ភ្លាមទៅ លោកកោធាយល់ថាចូលខកមកក្នុងវង្វង់ខ្មាំង ក៏បញ្ជាឱ្យថយ :

_ថយក្រោយសិនកនយើង !

រួចលោកបង្វិលក្បាលសេះឱ្យថយក្រោយ ប៉ុន្តែ បុរសម្នាក់ហក់មកស្ទាក់ជាប់ដោយទាំងគំហកថា :

_ឈប់សិនលោកមហាសេនា, ចាំឆ្លើយនឹងខ្ញុំសិន ! ប្រពន្ធខ្ញុំនៅឯណា ?

លោកកោធាស្គាល់ជាពញាថី

_ស្អី ? អើអាឯងនៅរស់ទេឬ ? អើ ប៉ុន្តែអាឯងត្រូវស្លាប់នៅពេលនេះហើយ!

បន្ទាន់នឹងវាចានេះ លោកវាត់ដាវខ្វាប់មកលើពញាថី នាយនេះដែលស្ទាត់ស្ទាញ ដោយបានហ្វឹកហាត់ពីសំណាក់លោកគ្រូកែវព្រះភ្លើងហើយនោះរងជាប់ រួចកាប់តទៅទៀត...

លោកកោធាកាប់បណ្តើរសួរទៅពញាថីថា :

_ហ៊ឹស អាឯងឥឡូវជាសិស្សរបស់អាកែវព្រះភ្លើងឬ ?

_ហ្នឹងហើយលោក, ខ្ញុំពុំទាន់ស្លាប់ទេ ខ្ញុំបានលោកគ្រូកែវព្រះភ្លើងជួយ ហើយឥឡូវលោកគ្រូកែវព្រះភ្លើងគឺជាគ្រូរបស់ខ្ញុំ ! លោកមហាសេនាឯងមិនមានអំណាចអីនឹងប្រមាថគ្រូខ្ញុំទេ !

_ហ៊ឹស គ្រូអាឯងជាពួកនរកប្រេតមិនឱ្យអញប្រមាថ ? ហើយ

ឥឡូវវាទៅឯណាហើយ ? ម៉េចមិនឃើញថាចេញមុខមក ? ម៉េចក៏បែរជាឃើញអាឯងឆ្កួតចង់ងាប់មករងអារុធអញទៅវិញ?

_ហ៊ឹស ដាវរបស់លោកគ្រូខ្ញុំវាមានកិត្តិយសខ្ពង់ខ្ពស់ណាស់ វាមិនសមនឹងប្រទ្បាក់ឈាមថោកទាបរបស់លោកមហាសេនាឯងទេ វាមិនចង់ប្រឡាក់ទេ វាទុកកិត្តិយសទៅយកឈាមស្ដេចពាល របស់លោកមហាសេនាឯងឯណោះវិញ គ្រាន់បានថ្លៃថ្នូរ ប្រសើរជាងប្រឡាក់ឈាមលោកមហាសេនាឯង!

_ស្អី អាឯងថាម៉េច ? និយាយឱ្យច្បាស់ទៅមើល ? គ្រូអាឯងគេចទៅណាហើយ?

_ហាសហា ... និយាយប៉ុណ្ណឹងហើយនៅមិនយល់ ឥឡូវគ្រូខ្ញុំគាត់ទៅវាំងទៅហើយ ! គាត់មិនសមនឹងថ្នាក់តទល់ជាមួយលោកមហាសេនាឯងទេ គាត់ត្រូវតែទៅលេងនឹងព្រះករុណារបស់លោកមហាសេនាឯងតែម្ដង!

ឯលោកមហាសេនាឯងនេះ ខ្ញុំឱ្យគេនាំមកចូលស៊ីង ដើម្បីបានលេងតទល់នឹងខ្ញុំ!

លោកកោធាព្យុជូច្នេះដូចគេពញ្ញាក់ភ្ញាក់ក្រញាង ងាកទៅរកនាយសេក ព្រោះនាយសេកនេះហើយដែលនាំផ្លូវមករបៀបនេះ ។ ពុំ

ឃើញនាយសេក ឃើញតែលោកនាយទ័ព ដែលកំពុងការពារខ្លួនពេញទំហឹងដែរ លោកកោធាសួរថា:

-លោកនាយទ័ព អាសេកទៅណាទៅ?

ស្រាប់តែសម្លេងនាយសេកឆ្លើយពីខាងសត្រូវមកថា:

-ខ្ញុំនៅឯណេះទេព្រះតេជគុណ, ខ្ញុំហើយ និង ព្រះតេជគុណអស់កម្មពៀរនឹងគ្នាហើយទាន!

-យើសអាក្បត់ នាំអញឱ្យមកចូលចំណោមខ្មាំង

-បាទព្រះតេជព្រះគុណ ប្រជាជនត្រូវការចាប់ព្រះតេជព្រះគុណមកកាត់ទោស ហេតុនោះ ទើបខ្ញុំបាទមានភារៈនាំព្រះតេជព្រះគុណមកទីនេះទានប្រោស!

-យើសអាងាប់! អាឯងមិនរួចពីងាប់ទេ!

លោកកោធាគ្រវីដាវចាល់ទៅរកនាយសេក ។ ពេលនោះព្រលប់យប់ងងឹតហើយ លោកមើលពុំយល់ថាគ្នាលោកនៅឯណាៗសោះឡើយ លោកប្រាថ្នាកាប់នាយសេកដោយផ្ទាល់ដៃតែម្តង ដ្បិតលោកក្តៅក្រហាយណាស់ ចំពោះសេនាក្បត់នេះ ។ ប៉ុន្តែ ពុំទាន់បានទៅជិតនាយសេកផង នាយកងទ័ពរបស់លោកមហាសេនាមកកៀកនឹងលោក ហើយជម្រាបតិចៗថា:

-ព្រះតេជព្រះគុណ, សូមរំដោះខ្លួនចេញទៅសិន ដ្បិតកងទ័ពរបស់យើងស្លាប់ច្រើនណាស់បែកទ័ពឥឡូវហើយ!

លោកកោធាយល់ព្រមតាម ក៏គោះជំនិះគេចចេញពីមុខពញ្ញាថី ។ លោកស្រែកបញ្ជាកងពល:

-ថយ! ថយក្រោយទៅពួកយើង!

កងពលជ្រួលច្របល់ ខ្លះថយទៅរួច ខ្លះក៏ជាប់ដៃត្រូវពួកអ្នកស្រុកកាប់សម្លាប់ចោលយ៉ាងរហ័ស ។ កងទាហានវាំងបាក់ទ័ព រត់របាត់របាយលែងរើសទិសតំបន់ ។ ឯលោកកោធានឹងលោកនាយទ័ព ដោយមានសេះជាជំនិះ ក៏អាចគេចចេញភ្លាមពីសមរភូមិ ។ ទាំងពីរនាក់ចេញផុតពីគ្រោះថ្នាក់ ក៏បំបោលសេះត្រឡប់ទៅវាំងវិញ ដោយមានទោមនស្សជាទីបំផុត ។

លោកកោធារអ៊ូបណ្ដើរ ទៅកាន់លោកនាយទ័ព

-ហ៊ឺស, មិនគួរជាយើងចាញ់កលរបស់សត្រូវសោះ ! មិនគួរចាញ់បោកអាសេកសោះ ! ទាំងនាយទ័ពឯងទៀតក៏យល់ស្របនឹងវាទៀត ទាល់តែយ៉ាងអ៊ីចឹងទៅ ហ៊ឺសចំតែម្ដង!

-បាទ, មកពីព្រះតេជព្រះគុណដែរដែលយកអាសេកជាទីប្រឹក្សាមុនដំបូងនោះ កុំអីខ្ញុំក៏មិនជឿវាដែរ!

_ហ៊ឹស អញស្មានតែវារត់រួចមកដូចគេធម្មតា អញមិនដឹងថាចោរចាប់វាយកទៅអប់រំបានដូច្នេះសោះ ! ឥឡូវនេះមានការណ៍ធំមួយទៀត គឺយើងត្រូវប្រញាប់ចូលវាំងការពារព្រះករុណា...

_បាទទាន ! ត្រូវប្រញាប់ ព្រោះនៅវាំងឯណោះ គ្មាននរណាកាន់ទ័ពមាំមួនទេ !

មេទ័ពទាំងពីរនិយាយបណ្តើរបំបោលសេះបណ្តើរ ឯសេនាទាហានឯទៀត ដែលរត់រួចមកដែរនោះ ក៏តាមនៅពីក្រោយព្រោងព្រាត ។

និយាយពីពញាថី និង នាយសេក កាលបើបានជ័យជំនះហើយក៏ឱ្យកងទ័ពអ្នកស្រុករើសប្រមូលគ្រឿងសព្វាវុធពីពួកខ្មោចទាហាន ។ ពេលនោះយប់ហើយ គេអុជចន្លុះភ្លឺព្រោងព្រាត ។ តាមជ្រលងអូរ មនុស្សស្លាប់រដូករណែល ឈាមផ្កាបច្លូលចុងច្រមុះ ។ ពញាថីនិយាយសរសើរនាយសេក :

_ហ៊ឺស ល្អណាស់ បងឯងធ្វើការឱ្យលោកគ្រូយើងបានសម្រេចល្អណាស់ កិច្ចកលយើងមានដំណើរប្រសើរអស្ចារ្យ ! កុំតែបានបងឯងចេះធ្វើឱ្យវាជឿចូលមកទីនេះ កុំអីយើងមិនបានជោគជ័យដល់ម្ល៉េះទេ !

_បាទ, ទម្រាំតែលោកកោដានោះជឿ ខ្ញុំខំលួងលោមជូន

យោបល់ច្រើនណាស់ដែរ!

-អើ, ឥឡូវយើងប្រមូលគ្នីគ្នាយើងទៀត ធ្វើដំណើរទៅរាជធានី ជួយលោកគ្រូយើងទៀត!

សូមជំរាបថា នាយសេកដែលទៅនិយាយនឹងលោកកោធាទាំង ប៉ុន្មាននោះ គឺជាពាក្យកុហកមុសាទាំងអស់ ហើយប្រាថ្នាឱ្យលោកកោធា នាំទ័ពមកចូលចំណោមពួកទ័ពប្រជារាស្ត្រតែម្តង តាមគ្រោងការណ៍ របស់កែវព្រះភ្លើង ។

គ្រានោះ គឺថា គ្រូកែវព្រះភ្លើងបានមានគ្រោងការនឹងបញ្ឆោត ឱ្យលោកកោធានាំទ័ពចេញពីវាំង ហើយឯខ្លួនឯងនឹងត្រូវនាំទ័ពចូលទៅ វាំង ធ្វើការវាយប្រហារស្តេចពញាអនោះតែម្តង ។ ព្រោះថា ពេលនេះ បែកការណ៍ហើយ ដោយសេនាដែលរត់រួចទៅនោះ មុខជានឹងនិយាយ ប្រាប់លោកកោធាអំពីទីកន្លែងរបស់គាត់ ហើយលោកកោធានឹងលើក ទ័ពមកកំចាត់គាត់មិនខាន ។ ដូច្នេះគាត់ត្រូវតែចាត់ការប្រយុទ្ធឱ្យហើយ ទើបគាត់ប្រើនាយសេកដែលស្ម័គ្រចិត្តនឹងគាត់នោះ ត្រឡប់ទៅវិញធ្វើ ជារត់រួច ដើម្បីទៅណែនាំលោកកោធាមកកាន់ទីប្រយុទ្ធនេះឯង ។ រីឯ ទីប្រយុទ្ធនេះ គ្រូកែវព្រះភ្លើងបានរៀបចំជាស្រេច គឺដាក់គ្នាឱ្យនៅអម មាត់អូរ ហើយឱ្យនាយសេកនាំលោកកោធាចុះអូរ ជាហេតុនាំឱ្យស្រួល

ក្នុងការវាយខ្ទប់សម្លាប់ពួកលោកកោធាបានដោយងាយ ។ ម្យ៉ាងទៀត ដំណាលគ្នានឹងពេលនេះ គ្រូកែវព្រះភ្លើងត្រូវនាំទ័ពមួយចំនួនចូលទៅវាំងឯណោះ ធ្វើការវាយលុកព្រះពញាអនឱ្យបានស្រួលផង ។

ត្រង់នេះ យើងគប្បីសរសើរគំនិតវាងវៃរបស់លោកគ្រូកែវព្រះភ្លើងណាស់ ដែលចេះរកមធ្យោបាយបោកបញ្ឆោតឱ្យលោកអគ្គមហាសេនាវីលក្បួង ហើយទទួលបរាជ័យយ៉ាងធ្ងន់នេះបានដោយធូរដូច្នេះ ។

ឥឡូវណោះ ក្នុងគ្រាដែលកងទ័ពលោកកោធាទទួលបរាជ័យហើយ លោកកោធាកំពុងបោលទៅវាំងវិញនេះ យើងបានឃើញលោកគ្រូកែវព្រះភ្លើងបានទៅវាំងយ៉ាងស្ងប់ស្ងៀម ។ គ្រូកែវព្រះភ្លើង និង ជំនិតគាត់ គឺបណ្ឌិតសុខ កំពុងតែលបសង្កេតពិនិត្យពិច័យមើលដំណើរទំនងជ្រុងជ្រោយនៃព្រះរាជវាំងនេះ ដើម្បីវាយលុក ។

ចំណែកព្រះពញាអនវិញ ល្ងាចនេះទ្រង់គ្មានចាប់ភ្លឹកនឹកឃើញថា កែវព្រះភ្លើងមកជិតកំពែងព្រះបរមរាជវាំងដូច្នេះឡើយ តាមពិតទៅទ្រង់នៅចាំមើលជោគជ័យរបស់លោកកោធា ដែលចេញទៅចាប់កែវព្រះភ្លើង នៅវត្តទួលបាសាណឯណោះ ។ ស្តេចពញាអននឹកសង្ឃឹមជាស្រេចថា ទ្រង់នឹងបានឃើញរូបអ្នកទោសធំម្នាក់របស់ទ្រង់ ។ ដូច្នេះទ្រង់គ្មានព្រួយបារម្ភឡើយ ។ ទ្រង់នឹកឃើញដល់រូបនាងទាវ ក៏ហៅម៉ែវីនមកសួរ :

_ម៉េចម៉ែវីន នាងទាវដែលមានអាការរោគមិនស្រួលខ្លួននោះនាងបានស្រួលហើយនៅ?

_ពរម្ចាស់ , នាងបានស្រួលហើយ តែពុំទាន់បានជាស្រឡះទេក្រាបទូល!

_អ្ហ៎ នាំនាងចូលមកណោះមើល!

ស្រីស្នំនោះថយទៅវិញ មួយភ្លែតនោះ នាងទាវបាវមកប្រាកដចំពោះព្រះភ័ក្ត្រព្រះពញាអន ។ នាងទាវមានទឹកមុខក្រៀមក្រំ ស្រពោនដីក្រែលែងដោយទុក្ខព្រួយ តែនាងស្រួលខ្លួនជាឡើងវិញហើយ មាន

សម្ដួស្បវិញហើយ ។ ព្រះពញាអនក្សត្រល្មោភកាមគុណឃើញរូបនាង ទាវក៏ដូចព្រះទ័យស្នេហ៍ស្និទ្ធជាថ្មី ទឹកមុខស្និតស្រពោនរបស់នាង មិនបានបង្អាក់ព្រះទ័យស្ដេចនេះឱ្យឈប់រវល់ពេលនេះបានទេ ។

ព្រះពញាអនរិតតែស្រឡាញ់នាងទ្វេឡើង ទ្រង់ឱ្យនាងឡើងមក អង្គុយជិត នាងក៏ធ្វើតាមដោយញាប់ញ័រ ។ ស្ដេចនេះញញឹមកំចាត់ការ ភ័យបារម្ភរបស់នាងចេញ:

-កុំព្រួយភ័យអីនាង , ម៉េចនាងបានស្រួលហើយឬ?

-ពរម្ចាស់ នៅឡើយទេ ខ្ញុំម្ចាស់នៅតែអស់កម្លាំងដដែលព្រះអង្គ ខ្ញុំ ម្ចាស់ចង់ថ្វាយបង្គំលាទៅវិញហើយ!

-ទេនាង , ខ្ញុំចង់ឱ្យនាងនៅជិតខ្ញុំ ដើម្បីខ្ញុំបានព្យាបាលនាង ដោយផ្ទាល់តែម្ដង ! មើលម៉េវ៉ន យកថ្នាំមកឱ្យខ្ញុំមើល ខ្ញុំនឹងឱ្យនាង អាស្រ័យម្ដង! ម៉េវ៉នឯងគ្មានដឹងអ្វីទេ !

ម៉េវ៉នចេញទៅដោយយល់ការហើយ ។ គ្រាន់តែម៉េវ៉នចេញផុត ភ្លាម ព្រះពញាអន ក៏ចាប់នាងទាវគ្រញ៉ិចភ្លាម ... នាងទាវបម្រះវក់វី ស្រែក:

- ព្រះករុណា, ព្រះករុណាកុំធ្វើបាបខ្ញុំម្ចាស់ ! កុំធ្វើបាបខ្ញុំម្ចាស់ ! ខ្ញុំម្ចាស់មានប្ដីហើយ អាណិតខ្ញុំម្ចាស់ទៅ!

ប៉ុន្តែព្រះពញាអនស្តាប់លែងឮ ស្តេចរឹតតែឱបនាងថើបគ្រញិច គ្រញិលប្រានទាងផ្តួលទៅដោយមានតម្រេកជាទីបំផុត នាងទាវភ័យ រន្ធត់អស់អង្គ នាងខំបម្រះគេចក្រឡេចចេញពីគ្រែបានបន្តិច ស្តេចទាញ នាងបានមកវិញ ហើយទ្រោបសង្កត់នាងយកឈ្នះតែម្តង នាងអស់ សង្ឃឹម ហើយនាងគ្មានកម្លាំងឯណានឹងទប់ទល់ឡើយ ប្រាណនាងបីដូច កណ្តុរដែលសន្ធប់នៅក្នុងម្រាមដៃថ្មាជាស្រេច ។ ប៉ុន្តែជាកុសលដែរ គ្រា ដែលព្រះពញាអនហៀបតែនឹងសម្រេចកាមរសលើរូបនាង ស្រាប់តែ មាត់លោកមហាមន្ត្រីជាស់ស្តេចនេះយ៉ាងស្ងួន៖

-ព្រះករុណា! ព្រះករុណា! ស្តេចតើនឡើង!

មុនដំបូងស្តេចនេះពុំទាន់ឮទេ! ទាល់តែញាប់បន្ថែមទៀត៖

-ព្រះករុណា! ស្តេចចាប់តើនឡើង! មានការណ៍ធំណាស់ក្រាប ទូល

ទើបស្តេចនេះភ្ញាក់ ក្រោកចាកពីការក្រសបនាង ហើយត្រាស់ សួរដោយមួម៉ៅក្តៅក្រហាយ៖

-អាណានេះ? មានការណ៍អ្វី អាចផ្ទៃណាហ្នឹង?

-ទូលបង្គំជាខ្ញុំ មហាមន្ត្រី

អ៎ មានការណ៍អីទាំងអធ្រាត្រ!

-ព្រះករុណាថ្លៃវិសេស មានសត្រូវចូលមកក្រាបទូល!ឥឡូវបាន ចូលក្នុងវាំងចោមវាយដណ្តើមឃ្លាំងអាវុធបានហើយ ក្រាបទូល!

-យី ម៉េចអ៊ីចេះ?

ព្រះពញាអនលាន់ព្រះឱស្ឋ រួចក៏បើកទ្វារចេញទៅ ស្រាប់តែភ្ញាក់ព្រះកាយមួយរំពេច ព្រោះឃើញភ្លើងចន្លុះព្រោងព្រាត ព្រមទាំងសម្រែកប្រេបល់នៃទាហានបានលាន់ឡើងយ៉ាងគគ្រឹក។

សកម្មភាពប្រកបដោយភយន្តរាយនេះ បានកើតឡើងវាលពាក់កណ្តាលផ្ទៃវាំងទៅហើយ ព្រះអង្គពុំភ្ញាក់ផ្អើលសោះ រវល់តែឈ្លក់ភ្លុកភ្លឹកនឹងនាងទាវគ្រានេះ ទ្រង់ក៏ដូចជាទតឃើញនូវការផុតសង្ឃឹមជាស្រេច។ ស្តេចពញាអនញាប់ ញ័រណាស់ ត្រាស់សួរទៅមហាមន្ត្រី:

-លោកដឹងទេ ពួកចោរវាតត្បាតនេះជាពួកណា?

-ព្រះករុណាថ្លៃវិសេស គឺជាពួកកែវព្រះភ្លើងក្រាបទូល!

-យិះ ជាពួកកែវព្រះភ្លើង ? ហើយលោកកោធានឹងលោកនាយទ័ពពុំទាន់មកវិញទេឬ?

-ព្រះករុណាថ្លៃវិសេស, នៅឡើយទេ ! ហើយនៅក្នុងវាំងយើងនេះនៅ មានតែកងពលមួយកងតូចប៉ុណ្ណោះក្រាបទូល!

- យី! ហើយបានរណោជាអ្នកចាត់ការបញ្ជាតទល់ឥឡូវនេះ?

-ព្រះករុណាថ្លៃវិសេស មានតែនាយរង់បីនាក់ និង រូបទូលបង្គំម្នាក់ បានបញ្ជាទាហានឱ្យតទល់ក្រាបទូល!

-អើ ចាត់ការទៅបើអ៊ីចុះ, ធ្វើយ៉ាងម៉េចកុំឱ្យវាចូលមកដល់ដំណាក់ខ្ញុំបាន!

ព្រះករុណាថ្លៃវិសេស ប៉ុន្តែ សូមទ្រង់ប្រយ័ត្នព្រះអង្គក្រាបទូល ព្រោះសឹកសត្រូវពេលនេះខ្លាំងណាស់!

លោកមហាមន្ត្រីត្រឡប់ចុះទៅវិញ ព្រះពញាអនច្ចេថ្លាបានបន្តិចស្ទុះចូលទៅក្នុងដំណាក់វិញ ចំណែកនាងទាវនាងរកច្រកចេញដែរ ប៉ុន្តែមកទើសត្រឹមទ្វារនេះ ព្រះពញាអនក៏ទាញនាងបញ្ចូលទៅវិញ ។ ព្រះពញាអនបិទទ្វារជិត ខ្ទាស់យ៉ាងម៉ឹង ហើយទុកតែចន្លោះបង្អួចមួយមើលទៅក្រៅ ។

ព្រះពញាអនរន្ធត់ញាប់ញ័រណាស់ ហើយទន្ទឹងដំណើរលោកកោធាខ្លាំងណាស់ផង លោកកោធាថាទៅកំចាត់អាកែវព្រះភ្លើង ឥឡូវកែវព្រះភ្លើងមកឯណេះសោះ! យីវីវរហើយគិតយ៉ាងណាអ៊ីចេះ?

គ្រានោះចលាចលច្របូកច្របល់ពេញបន្ទុក សម្លេងស្រីស្នំបានផ្ទុះឡើងនៅដំណាក់មួយនោះយ៉ាងរន្ធត់ញាប់ញ័រ ដោយភ័យភិតនិងកង់ទ័ពថ្មីសន្ធាប់ចូលមកដល់ ។ ព្រះពញាអនក្រឡេកឃើញស្រីស្នំទាំងអប្បាល

មាណនោះរត់ប្រញាប់ ព្រះពញាអនបិទព្រះនេត្រមិនចង់ឃើញការខ្មាត់ខ្មាយនេះទេ បានបន្តិច សម្លេងម៉ែវ៉ន នៅនឹងមាត់ទ្វារស្រែកទូលព្រះអង្គថា:

-ព្រះករុណា, ជួយផង ពួកចោរចូលដល់ដំណាក់ដាក់ស្រីស្នំហើយ! គិតយ៉ាងណាទៅព្រះអង្គ?

ស្ដេចពញាអនឆ្លើយពីក្នុងទៅវិញថា:

-អើ, ឱ្យពួកនាងស្នំរកផ្លូវដោះខ្លួនចេញទៅចុះ!

បន្ទាប់ពីនេះក៏ឮស្នូរមាត់ម៉ែវ៉នទៀតយ៉ាងស្លន់ថា:

-យី, មេសារិកា! ហាងឯងក្បត់អញឬ?

យី! អូយព្រះអង្គអើយ មេសារិកាចាក់សម្លាប់ខ្ញុំម្ចាស់ហើយ! ជួយខ្ញុំម្ចាស់ផង!

ស្ដេចពញាអនភ្ញាក់ព្រើត អើតចេញទតទៅក្បែរទ្វារឃើញនាងសារិកាកំពុងស្ទុះរត់ចុះទៅដីវិញ ហើយឃើញម៉ែវ៉នដេកវៀនក្បែរមាត់ជណ្ដើរ មានឈាមចេញមកលើក្ដារ មិនដឹងជាត្រូវមុខអាវុធត្រង់កន្លែងណា មើលមិនច្បាស់ព្រោះងងឹត ។ ព្រះចៅប្រុងបើកទ្វារចេញទៅមើលស្នំជំនិតនោះ ប៉ុន្តែបែរជាខានទៅវិញ ព្រោះគ្មានសេនាណាម្នាក់នៅលើដំណាក់នេះសោះ។

ស្តេចលាន់មាត់ម្នាក់ឯងថាៈ យីមេសារិកាវាក្បត់អញផងឬ?

ស្តេចក្រឡេកទៅក្រៅឯណោះទៀត ឃើញឃ្លាំងសព្វាវុធកំពុងត្រូវភ្លើងឆេះទ្រលោម ឱ្យពន្លឺក្រហមភ្លឺច្បាស់ ឃើញក្បាលទាហានវាំងនិងពួកកែវព្រះភ្លើងរងោករងល់ កាប់ចាក់គ្នាកោលាហល ហើយពន្លឺភ្លើងនោះក៏ឱ្យកំដៅមកដល់ដំណាក់ព្រះអង្គទៀតផង ។ ឃ្លាំងសព្វាវុធត្រូវរលាយហើយ! ព្រះពញាអនស្ទើរនឹងស្រុតស្រុញរួញព្រះកាយតែម្តង។ ភាពទ្រហឹងអឹងអាប់នេះបានមក អង្រួនបេះដូងព្រះអង្គឱ្យញាប់ញ័រកាន់តែខ្លាំង ។

ចំណែកនាងទាវ ពេលនោះនាងក៏រន្ធត់ណាស់ដែរ នាងភ័យណាស់ក៏ស្ទុះទៅអែបនឹងទូក្បែរនោះ, ព្រះពញាអនស្រែកថាៈ

_អើ, ពួនកន្លែងនោះទៅ ! ហ៊ឺះ នាងឯងនេះចង្រៃណាស់ អញគ្រាន់តែយកមកដាក់ក្នុងវាំងមិនទាំងបានមួយឆ្នាំផង ក៏ស្រាប់តែចលាចល!

ពេលដែលព្រះពញាអនកំពុងបន្ទោសនាងទាវនេះ ឃ្លាំងមួយទៀតដែលនៅក្បែរដំណាក់ ក៏ស្រាប់តែឆេះក្រហមឡើងដែរ ជះកំដៅភាយមកដល់ព្រះពញាអនអន្ទះសាខ្លាំងឡើង ហើយមើលទៅឃើញសេនាទាហានវាំងខ្លះរត់របាត់របាយទៅផង ព្រះពញាអនច្លេច្លាបង់បើក

ទ្វារចេញដោះព្រះអង្គ ស្រាប់តែសម្លេងគួរឱ្យកក់ក្ដៅមកពីក្រៅទ្វារថា:

-ព្រះករុណា, ព្រះករុណា, បើកទ្វារ ! ទូលបង្គំមកវិញហើយ ស្ដាប់សម្លេងទូលបង្គំបានទេ?

ច្បាស់លោកកោធា ព្រះពញាអនស្ទុះទៅបើកឃ្លាំង លោកកោធាឱនក្បាលបន្តិចមិនបាច់ថ្វាយបង្គំឱ្យចប់ទេ ទូលដោយហាបហត់ប៉ផ្សេះថា:

-ទ័ពសត្រូវមានជ័យជំនះហើយ ទ័ពយើងបែកខ្ញែកគ្នាហើយ ! សូមព្រះអង្គដោះព្រះកាយចេញពីដំណាក់នេះទៅ! ទូលបង្គំខំមកឱ្យទាន់ជួយការពារព្រះអង្គ!

-អើ ចុះក្រែងលោកថាទៅកំចាត់វាឯណាឬ ? ម៉េចក៏វាមកឯណេះវិញ?

-ព្រះករុណាថ្លៃវិសេស យើងចាញ់កលវា វាឱ្យយើងនាំទ័ពទៅឯណោះឯវាក៏នាំគ្នាមកឯណេះ!

ឥឡូវនេះ សូមទ្រង់កុំរារង់ ប្រញាប់ចេញចុះពីដំណាក់នេះភ្លាមទៅ!

ព្រះពញាអនក៏ចេញពីដំណាក់ ប៉ុន្តែមិនទាន់បានពីរបីជំហានផង បុរសមាឌមាំ និង បក្សពួកពញាចី នាយសុខបានមកដល់ល្មម ។ ហើយនៅជាមួយពួកនោះ គឺនាងសារិកាផង ។ ពញាអនឃើញនាង

សារិកាក៏គំហកថា:

-យី មេសារិកា! មេក្បត់

ប៉ុន្តែគ្មាននរណាតអ្វីទេ ។ ពញ្ញាថីប្រាប់គ្រូកែវព្រះភ្លើងដោយចង្អុលទៅព្រះពញ្ញាអន :

-លោកគ្រូ នេះហើយស្ដេចពាល! ចាត់ការទៅ!

ព្រះពញ្ញាអនពេលនេះអស់ផ្លូវរត់ហើយ ក៏ចូលទៅក្នុងដំណាក់វិញ ទាញទ្វារបិទជាប់ ។ ឯលោកកោធាក៏កាប់រ៉ាប់ទៅលើពញ្ញាថី ពញ្ញាថីកាប់រងសងទៅវិញយ៉ាងរហ័ស ពេលនោះលោកមហាមន្ត្រីក៏ឡើងមកដល់ដែរ ជួយការពារលោកកោធា ប៉ុន្តែលោកមហាមន្ត្រីនេះត្រូវនាយសេកដែលទើបនឹងមកដល់ដែរ និងសិស្សរបស់គ្រូកែវព្រះភ្លើងព្រួតគ្នាវាយប្រានទៅវិញ ហើយទីបំផុត លោកមហាមន្ត្រីក៏ស្រែកយ៉ាងស្លន់ថា:

- អួយ! ខ្ញុំត្រូវអាវុធគេហើយ! ជួយផង!

សម្លេងនេះរលត់ឈឹងទៅ លោកកោធាអស់សង្ឃឹម ព្រោះគ្នាលោកគ្មានសោះ លោកត្រូវតែដោះដៃទៅសិនទើបស្រែកប្រាប់ទៅស្ដេចខាងក្នុង:

-ព្រះអង្គ ខ្ទាស់ទ្វារនេះឱ្យជាប់, ទូលបង្គំទៅក្រៅវាំងសិន ប្រមូល

ទ័ពមកទៀត!

ប៉ុន្តែគ្រាន់តែងាកខ្លួនមកវិញបន្តិចនោះ ដាវពញាចីចាក់ព្រួក ចំទ្រូងលោកមហាសេនានេះ ផ្ងារស្រទាងទៅ ហើយស្រែកពាក្យជាថ្មីថា:

_ព្រះករុណា! ទូលបង្គំត្រូវរបស់គេហើយ! គេចទៅ!

សម្លេងប្តូរផ្តាស់នេះ ធ្វើឱ្យព្រះពញាអននៅពីក្នុងនោះ តក់ស្លុត ត្រជាក់ព្រះកាយស្រើត អស់សង្ឃឹមជាចុងក្រោយ ឯទ្វារដែលទ្រង់ខ្ទាស់ ជាប់ម៉ឺងនោះ ក៏រំភើបៗ ចង់ធ្លាយដោយសារការវាយបុកនៃពួកអ្នកខាង ក្រៅ មើលទៅទ្វារនេះនឹងបើកឥឡូវហើយ គ្មានអ្វីការពារទេ ! ប៉ុន្តែ ព្រះពញាអននឹកឃើញគ្រឿងការពារមួយនៅនាទីចុងចប់នេះ.... ព្រះ ពញាអនស្ទុះទៅឱបនាងទាវជាប់ ហើយទាញកាំបិតខ្លីដ៏ស្រួចក៏បើក មុខជាស្រេច... ពេលនោះទ្វារក៏របើកយ៉ាំង គ្រូកែវព្រះភ្លើង ពញាចី ចូល ដល់មុនគេ ព្រះពញាអនថយក្រោយ កែវព្រះភ្លើងឈានចូល ព្រះពញា អនរហ័សដាក់កាំបិតផ្ទាប់កនាងទាវ ទាញយកទៅជិតជញ្ជាំង ស្រែក គម្រាមអ្នកទាំងអស់គ្នាថា:

_កុំចូល, អញសម្លាប់នាងនេះឥឡូវ!

នាងទាវរន្ធត់ណាស់ នាងស្រែកហៅប្តី:

_បង, បងជួយប្អូនផង!

កែវព្រះភ្លើងគំហកទៅពញ្ញាអន:

_ស្តេចកំសាក, លែងនាងនេះភ្លាមទៅ!

ទាំងអស់គ្នាទាល់គំនិត ប៉ុន្តែ គ្រានោះនាយសេកស្ទុះធ្លាចូលមករួចនាយសេកសរសៀទៅជិតពញ្ញាអន ពញ្ញាអនពុំបានដឹងថានាយសេកក្បត់ទេ ព្រោះពុំបានដឹងថា សកម្មភាពនាយសេកជួយគ្រូកែវព្រះភ្លើងឡើយ ម្យ៉ាងទៀតលោកកោធាក៏ពុំបានចូលឱ្យជ្រាបផង ម្ល៉ោះហើយឃើញនាយសេកចូលមក ពញ្ញាអននឹកអរបន្តិចដោយយល់ថា នាយសេកជាអាមាត្យរបស់ខ្លួន ក៏បញ្ជាថា:

_អើអាសេក, មកខាងណេះភ្លាម ! បើកទ្វារខាងក្រោយឱ្យអញភ្លាម! លឿន!

នាយសេកស្ទុះភ្លែតតាមបញ្ជា ទៅនៅពីក្រោយធ្វើជាទៅរកទ្វារ ប៉ុន្តែព្រឹប ! នាយសេកចាប់ដៃបុគ្គលកំសាកនេះម្ខាងទាញបត់មកក្រោយ ពញ្ញាអនភ្ញាក់លែងខ្លួននាងទាវ បែរជាងាកទៅចាក់នាយសេកព្រួកចំដើមទ្រូង ដោយទាំងពាក្យថា:

_យឺះអាសេកក្បត់!

នាយសេកដួលចុះទៅ.. ពញ្ញាអនរហ័សភ្នែកទៅរកទ្វារក្រោយ ប៉ុន្តែបានតែពីរបីជំហានប៉ុណ្ណោះដីដួលព្រឹប ! ស្រែកអូយ ... ដាវគ្រូកែវ

ព្រះភ្លើងដោតទម្លុះពីខ្នងធ្លាយចុងដាវដល់ទ្រូង ! ស្តេចពាលនេះបម្រះខ្ញើកៗបន្តិចក៏នៅស្ងៀម, ជនល្មោភកាមនេះដាច់ខ្យល់ស្រេច!

គ្រូកែវព្រះភ្លើងដកដាវមកវិញ ឈាមហូរកក្លាក់ចាំងផ្លេកៗនៅនឹងភ្លើងចន្លុះ ទើបគាត់មករកនាយសេក នាយសេកដេកគងលើដៃនាងសារិកាដែលកំពុងថ្នាក់ថ្នម, ឯពញាថី និង នាងទាវ ក៏នៅអង្គុយពិនិត្យរបួសនាយសេកដោយព្រួយបារម្ភដែរ ។ គ្រូកែវព្រះភ្លើងសួរទៅស្រីដែលទ្រខ្លួននាយសេកថា:

_នាងជាភរិយានាយសេកឬ? នាងឈ្មោះសារិកាឬ?

_ចាសលោកគ្រូ, នាងខ្ញុំនេះហើយ, សូមលោកគ្រូមេត្តាជួយមើលប្ដីខ្ញុំផង!

_មិនអីទេនាង!

គ្រូកែវព្រះភ្លើងក៏តាំងលូកថ្នាំ ក្នុងហោប៉ៅមកទំពាបិទមុខរបួសនោះភ្លាម ។

សូមបញ្ជាក់ថានាងសារិកាបានឆ្លៀតឱកាសវឹកវរនេះ ជួយដុតបំផ្លាញកន្លែងស្រីស្នំអស់ ហើយបានទាំងសម្លាប់ម៉ែវិនស្រីជំនួញឈាមនោះផង ។ សកម្មភាពរបស់នាងសារិកា មិនកំបាំងពីភ្នែកពួកកែវព្រះភ្លើងឡើយ ។ គ្រូកែវព្រះភ្លើងមានអំណរនឹងសកម្មភាពនាងណាស់ គាត់

សរសើរថា:

-នាង, នាងជាស្រីបដិវត្តន៍ម្នាក់គួរសរសើរ, នាងចេះមានស្មារតីភ្ញាក់រលឹក កំចាត់ពួកពាលអប្រិយនេះទាន់កាលវេលា ! ខ្ញុំសុំសរសើរនាង!

-ចាសលោកគ្រូ, មកពីនាងខ្ញុំមានការឈឺចាប់ណាស់, ស្តេចចង្រៃនេះបញ្ឆោតប្តីនាងខ្ញុំ និង នាងខ្ញុំឱ្យចូលមករាំង រួចចាប់បង្ខំនាងខ្ញុំទាំងអំណាច ឯប្តីនាងខ្ញុំក៏ត្រូវបង្ខំឱ្យធ្វើទាហាននៅកន្លែងផ្សេងពីនាងខ្ញុំ, នាងខ្ញុំបែកពីប្តីរហូត! នាងខ្ញុំឈឺចាប់ណាស់ នឹកបន់ស្រន់ឱ្យតែមានការបះបោរឡើងដូច្នេះទេ នឹងអាលបានសងសឹកចំពោះពួកពាល ព្រមទាំងបានរំដោះខ្លួនផង ! ឥឡូវនាងខ្ញុំបានសម្រេចបំណងមែន ! នាងខ្ញុំបានសងសឹកពួកវា និង បានដោះខ្លួនបានដូចប្រាថ្នា, ហើយការណ៍ទាំងនេះក៏សម្រេចបានព្រោះតែលោកគ្រូដែរ, នាងខ្ញុំសូមដឹងគុណលោកគ្រូណាស់!

គ្រូកែវព្រះភ្លើងញញឹមតបឡើង:

-ណ្ហើយនាងអើយ, គ្មានគុណស្រាយអ្វីទេ នេះជាករណីយកិច្ចរបស់ខ្ញុំទេ, អើឥឡូវនេះចូលនាងនាំនាយសេកទៅរកកន្លែងសម្រាកទៅមិនអីទេ, ចាប់ៗនេះនាយសេកនឹងបានជាស្រួលវិញមិនខាន!

ហើយគាត់បញ្ជាទៅអ្នកឯទៀត:

-នែ, អូសខ្មោចស្ដេចចង្រៃនេះយកទៅដាក់នៅផ្លូវបំបែកទៅ, ឱ្យប្រជារាស្ត្រឃើញគ្រប់គ្នា រួចសឹមយកទៅកប់ចោល ឯខ្មោចមហាសេនាមហាមន្ត្រីក៏អ៊ីចឹងដែរ!

រាល់គ្នាប្រតិបត្តិតាមបញ្ជាគ្រូកែវព្រះភ្លើងឥតបង្អង់។

គេយកខ្មោចស្ដេចពញាអន និង ខ្មោចមហាសេនា មហាមន្ត្រីយង់ឃ្នង់ដាក់ទន្ទឹមគ្នានៅផ្លូវបំបែក។

ព្រឹកឡើង យើងឃើញប្រជាជនទាំងជិតទាំងឆ្ងាយដឹកកូន ជញ្ជូនចៅចូលមករាជធានីទូលបាសាណ គគ្រឹកគគ្រេងមើលខ្មោចមនុស្សអកុសល ដែលជាសត្រូវវាតត្បាតលើខ្លួនទាំងអស់គ្នា សឹងតែពោលពាក្យផ្ដន្ទាទោសស្រប ៗគ្នាថា:

-អើ ឱ្យវាងាប់ស្រឡះសាធុអ៊ីចឹងទៅចុះ, កុំឱ្យវាដើរវាតត្បាតចាប់កូនប្រពន្ធគេតទៅទៀត!

ខ្លះទៀតក៏ថា:

ចាប់ពីពេលនេះទៅ ប្រជាពលរដ្ឋយើងបានសុខហើយ, មនុស្សពាលសាហាវយង់ឃ្នង ល្មោភកាមនេះបានស្លាប់តៃហោងទៅហើយ ដោយសារស្នាដៃ គ្រូកែវព្រះភ្លើង!

រួចគេនាំគ្នាឈូចរគោរពអរគុណចំពោះគ្រូកែវព្រះភ្លើង ។ បុរសចាស់ម្នាក់និយាយជាតំណាងប្រជាពលរដ្ឋថា:

-ខ្ញុំសូមអរគុណចំពោះគ្រូកែវព្រះភ្លើងខ្លាំងណាស់ ដែលបានដឹកនាំកងទ័ពប្រជារាស្ត្រមកទម្លាក់ស្ដេចអន្ធពាលនេះបាន ! គ្រូកែវព្រះភ្លើងជាអ្នកមានគុណណាស់ ចំពោះមករាស្ត្រតូចតាច រាល់គ្នាសូមលើក

គ្រូកែវព្រះភ្លើងជាវីរៈបុរសនៅសម័យនេះ, ជយោ! គ្រូកែវព្រះភ្លើង!

សម្លេងហ៊ោរកញ្ជៀវ និង ទះដៃក៏លាន់ឡើងដូចរន្ទះ ហើយបន្ទាប់ និង ពេលនោះគេឃើញរទេះមួយដាក់សង្ឃពីរបីអង្គបរចូលមកបុរសចាស់នេះក៏ថា:

-ឱ ហ្ន៎ លោកគ្រូធំយើង វត្តទួលបាសាណលោកនិមន្តដែរហើយ!

លោកគ្រូចៅអធិការវត្តទួលបាសាណបានជាព្រះអង្គ ហើយលោកនិមន្តមកដែរ ដោយមានលោកនេនពីរអង្គដង្ហែមកផង ។ គ្រូកែវព្រះភ្លើង និង សិស្សគណទាំងប៉ុន្មាន បាននាំគ្នាក្រាបថ្វាយបង្គំព្រះអង្គយ៉ាងរាក់ទាក់ ។ ព្រះគ្រូចៅអធិការ មានព្រះពុទ្ធដីកាទៅកាន់គ្រូកែវព្រះភ្លើងថា:

-អើ អញបានតាមស្តាប់រឿងរ៉ាវកែវឯងយ៉ាងជាប់ប្រកិត អញដឹងថាកងទ័ពកែវឯងយកជ័យជំនះលើស្តេចពាលនេះបាន ! អញអរណាស់!

គ្រូកែវព្រះភ្លើង ក៏ទូលលោកគ្រូ ជម្រាបអ្នកស្រុកថា:

-ខ្ញុំព្រះករុណា ខ្ញុំបាទដែលធ្វើការណ៍ដ៏ធំប៉ុណ្ណឹង កើតក៏អាស្រ័យលើសាមគ្គីរបស់បងប្អូនទាំងអស់គ្នាដែរ ដែលមានការឈឺចាប់ចំពោះស្តេចនេះ និង បក្សពួក ដែលបានប្រព្រឹត្តអំពើព្រៃផ្សៃថោកទាបមកលើ

បងប្អូន!

ឥឡូវនេះ យើងរំដោះខ្លួនចេញផុតពីរបបព្រៃនៃស្ដេចនេះហើយ, យើងត្រូវចាត់ការរៀបចំស្រុកទេសឱ្យមានរបបល្អឡើង!

រាល់គ្នាក៏ស្រែកជយឃោសនាជាថ្មីយ៉ាងខ្ទរខ្ទារ។

យើងមើលទៅជ្រុងមួយនៃកំពែងវាំងឯណោះវិញ។

ពញ្ញាថី និង នាងទាវពុំបានជួយស្រែកជយឃោសនាជាមួយគេទេ រវល់តែសាសងរឿងដើមប្រាប់គ្នាទៅវិញទៅមក។

ពញ្ញាថីបានរៀបរាប់ពីខ្លួនព្រាត់អំពីភរិយាទៅហូរហែ:

-អូនអើយ គ្រាដែលបងបែកពីអូនទៅនោះ លោកមហាសេនាយកបងទៅសណ្ដូនថ្មទម្លាក់ទឹក ប៉ុន្តែបងបានគ្រូកែវព្រះភ្លើងជួយ ហើយបងក៏ទៅជាមួយគ្រូកែវព្រះភ្លើងរហូតមក ជួយកងទ័ពវាយកំចាត់ស្ដេចអប្រិយ៍នេះ!

អូនអើយ បងនឹកអូនណាស់ ហើយបងស្រមៃឃើញជាស្រេចទៅហើយថាអូនទៅជាមហេសីនៃស្ដេចនេះទៅហើយ!

ប៉ុន្តែនាងទាវប្រញាប់បដិសេធថា:

-អ្នកបង, ខ្ញុំប្ដូរជីវិតការពារសេចក្ដីបរិសុទ្ធ មិនឱ្យប្រុសណាកន្ទង់ខ្លួនខ្ញុំជាពីរទេ! ស្ដេចនោះប្រុងរំលោភលើរូបកាយខ្ញុំនៅលើកទី១

នោះ ខ្ញុំតស៊ូរត់ ចេញមកក្រៅជួបនឹងបងដូចបងឃើញស្រាប់...

ហើយតាំងពីនោះមក ខ្ញុំក៏មានជំងឺរហូត ព្រោះតែខ្ញុំព្រួយចិត្តគិតទៅអ្នកបងខ្លាំងពេក! ស្តេចនោះពុំបានឱ្យគេនាំយកទៅគាល់ទេ ! ទើបតែយប់មិញនេះឯង ដែលខ្ញុំបានស្រួលខ្លួនបន្តិច ហើយស្តេចនេះឱ្យគេនាំខ្ញុំចូលគាល់ ខ្ញុំឥត មានមន្ទិលសៅហ្មងអ្វីនឹងស្តេចអប្បលក្ខណ៍នេះទេបង !

ពញ្ញាថីញញឹមតបនឹងភរិយា:

_បងជឿអូនហើយ, អូនសារិកាប្រពន្ធបងសេកបាននិយាយប្រាប់បងហើយ កាលពីបងបាននាំទ័ពចូលមកដល់ក្នុងវាំងនេះភ្លាមនោះ អូននៅបរិសុទ្ធល្អណាស់ អ្នកសារិកាជាសាក្សីក្នុងរឿងនេះ បងគ្មានវង្វេងចិត្តសោះឡើយ បងរិតតែស្រឡាញ់អូនទ្វេឡើងទៀត !

គេត្រកងកាយភរិយាមកឱបនែបនិត្យ បន្តវាចាទៀតថា:

_ទាវមាសបង តាំងពីពេលនេះទៅ គ្មានណាមកបំបែកយើងទៀតទេ យើងផុតទុក្ខរហូតហើយ !

នាងទាវញញឹមមើលមុខប្តីយ៉ាងចំ:

_ពិតមែនហើយបង, យើងនឹងបាននៅនិត្យជិតគ្នាជាដរាប, យើងត្រឡប់ទៅស្រុកវិញណាបង !

ដំណាលគ្នានឹងពេលចប់ពាក្យសន្ទនានេះ គ្រូកែវព្រះភ្លើង

អញ្ជើញមកដល់ ។ ទាំងពីរនាក់ស្វាមីភរិយាឱនក្បាលលើកដៃប្រណម្យដោយសេចក្ដីគោរព:

-ខ្ញុំទាំងពីរនាក់ប្ដីប្រពន្ធ សំដែងកតញ្ញូចំពោះលោកគ្រូជាដរាប, យើងខ្ញុំទាំងពីរនាក់ពុំអាចភ្លេចគុណលោកគ្រូបានឡើយ!

គ្រូកែវព្រះភ្លើងញញឹមលើកដៃឡើងវា:

-អើក្មួយប្រុស ក្មួយស្រីកុំគិតគុណស្រាយអ្វី, យើសមគ្នាណាស់ ! អើយើងសុខសប្បាយហើយ ត្រឡប់ទៅស្រុកភូមិវិញចុះ!

-បាទទាន, លោកគ្រូគិតអញ្ជើញទៅភ្នំដូនពេញវិញថ្ងៃណា ? ខ្ញុំបាទ និង ភរិយាសុំជូនដំណើរលោកគ្រូទៅផង!

-អើ ទៅឥឡូវនេះហើយ ប៉ុន្តែក្មួយឯងកុំគិតគួរសមច្រើនពេក, គ្រូទៅតែជាមួយគ្នីគ្នាពីមុននោះបានហើយ មិនបាច់ឯងទៅទេ ឯងប្រញាប់នាំភរិយាទៅ ស្រុកវិញប្រកបរបររកស៊ីសុខសប្បាយទៅចុះ!

ពោលតែប៉ុណ្ណោះ គ្រូកែវព្រះភ្លើង ក៏នាំសិស្សគណជយចេញទៅទុកឱ្យពញាថី នាងទាវព្រមទាំងមនុស្សម្នាទាំងអស់ មើលដោយអាល័យ។

យើងសូមបញ្ចប់រឿងកែវព្រះភ្លើងត្រឹមប៉ុណ្ណោះ ! ហើយយើងសូមបញ្ជាក់ថា : ឈ្មោះតួនៅក្នុងរឿងនេះគឺពញាថី នាងទាវ ស្ដេចពញាអនគ្រូកែវ ព្រះភ្លើង ទាំងនេះជាឈ្មោះពិត។ ដែលព្រះរាជពង្សាវតារបាន

ចារមក យើងពុំមែនប្រតិស្ឋដាក់ដោយខ្លួនឯងឡើយ ។ លើកលែងតែត្អូរង ខ្លះដែលយើងពុំឃើញមានឈ្មោះ ទើបដាក់ដោយកំណត់ទៅ ដើម្បី ស្រណុកហៅក្នុងការនិយាយរឿងនេះ ។

ចំពោះនាមដ៏ឧត្តមនៃលោកគ្រូកែវព្រះភ្លើង អ្នកមេបដិវត្តន៍ ជំនាន់នោះឯង ពុំបានសាបសូន្យរលត់រលាយទៅតាមកាលវេលាទេ គេបានសាងវត្តមួយចារជាឈ្មោះគាត់ គឺ "កែវព្រះភ្លើង" នៅរដ្ឋធានី ភ្នំពេញសព្វថ្ងៃនេះឯង ។

ដូច្នេះ គុណសម្បត្តិ និង គុណធម៌ដ៏វិសេសរបស់រដ្ឋបុរសនេះ នៅ គង់វង្សដរាប ហើយបានមកតភ្ជាប់នឹងសម័យបដិវត្តន៍ថ្ងៃទី១៨ មីនា ឆ្នាំ ១៩៧០ នេះផងទៀត ដែលសម័យក្រោយនេះសន្មតថាចប់ ឯវិ អស់មាន កំពូជស្ដេចតទៅទៀតហើយ ។

ប្រទេសខ្មែរត្រូវទៅជាសាធារណរដ្ឋ ដើរទាន់អារ្យប្រទេសនា ក្នុងលោក សមតាមបំណងនៃប្រជាជនខ្មែរទូទៅ ។

## សេចក្ដីជម្រាប

ក្រោយពីការបោះពុម្ពផ្សាយឡើងវិញនូវរឿងមួយចំនួនកន្លងមកនេះ បណ្ណាគារយើងខ្ញុំ បានទទួលមតិរិះគន់កែលំអយ៉ាងផុលផុសពីសំណាក់លោក–អ្នកដែលស្រឡាញ់វិស័យនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិភាគទានដ៏ថ្លៃថ្លាទាំងអស់នេះ ហើយខិតខំកែលំអឲ្យអស់ពីលទ្ធភាព ដើម្បីឈានទៅរកសុក្រិតភាពជាលំដាប់ ។ យើងខ្ញុំសូមប្រសិទ្ធិពរជ័យបវរដល់លោក–អ្នក សូមបានគពប្រសព្វតែសេចក្ដីសុខក្សេមក្សាន្ត គ្រប់ទិនទិវារាត្រីកុំបីឃ្លៀងឃ្លាត។

សូមអរគុណ៕ អង្គរធំ



សូមអញ្ជើញរកជាវនៅតាមបណ្ណាគារ
និងបញ្ជរលក់សៀវភៅគ្រប់ខេត្ត-ក្រុង

ISBN-9789995076146
9 789995 076146

8